**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

# ផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន
# ២០១៨-២០២៥

បានទទួលការអនុម័តពីរាជរដ្ឋាភិបាលកម្ពុជា

ថ្ងៃទី ៩រោច ខែ មិគសិរ ឆ្នាំ រកា ព.ស. ២៥៦១

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៧

# មាតិកា

**អក្សរកាត់**..........ii
**អារម្ភកថា**..........iii
**សេចក្តីសង្ខេប**..........v
**១. សេចក្តីផ្តើម**..........១
**២. ចក្ខុវិស័យ**..........៧
**៣. បេសកកម្ម**..........៧
**៤. គោលបំណង និងគោលដៅ**..........៨
**៥. ក្របខ័ណ្ឌយុទ្ធសាស្ត្រ**..........១១
**៥.១ ការវិភាគជាយុទ្ធសាស្ត្រ**..........១១
**៥.២ យុទ្ធសាស្ត្រ**..........១៥
**៦. សកម្មភាពការងារ**..........២២
**៧. ក្របខ័ណ្ឌស្ថាប័ន**..........២៣
**៨. ក្របខ័ណ្ឌប្រតិបត្តិការ**..........២៥
**៩. យន្តការសម្របសម្រួល**..........៣២
**១០. និរន្តរភាព**..........៣៣
**១១. ធនធានហិរញ្ញវត្ថុ**..........៣៤
**១២. ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ**..........៣៧
**១៣. ការសន្និដ្ឋាន**..........៣៩
**ឧបសម្ព័ន្ធ**..........៤០
*ឧបសម្ព័ន្ធ កៈ ស្តង់ដារចាត់ថ្នាក់ប្រភេទដី*..........៤១
*ឧបសម្ព័ន្ធ ខៈ ការព្យាករអំពីការរំដោះផ្ទៃដី និងថវិកា ២០១៨-២០២៥*..........៤២
*ឧបសម្ព័ន្ធ គៈ តារាងសូចនាករសកម្មភាព*..........៤៣

# អក្សរកាត់

| | |
|---|---|
| អ.ហ.ផ.ម. | អនុសញ្ញាអន្តរជាតិស្តីពីការហាមការប្រើប្រាស់ ការរក្សាទុក ការផលិត និងការផ្ទេរគ្រាប់មីនប្រឆាំងមនុស្ស និងការបំផ្លាញគ្រាប់មីន |
| ស.ក.ម.ក. | ស្ថង់ដារកម្ចាត់មីនកម្ពុជា |
| ក.ប.ម. | ក្រុមការងារបច្ចេកទេសចម្រុះរាជរដ្ឋាភិបាល-ដៃគូអភិវឌ្ឍន៍លើវិស័យមីន |
| ស.ផ.ស. | សំណល់ជាតិផ្ទុះពីសង្គ្រាម |
| ហ.ត. | ហិចតា |
| គម២ | គីឡូម៉ែត្រការ៉េ |
| ម២ | ម៉ែត្រការ៉េ |
| អ.យ.ក. | ក្រសួងអប់រំ យុវជន និងកីឡា |
| អ.ស.ប. | អង្គការសហប្រជាជាតិ |
| ស.អ.យ. | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| ប.ព.ជ.ម.ក. | ប្រព័ន្ធព័ត៌មានជនរងគ្រោះដោយសារមីននិងស.ផ.ស.នៅកម្ពុជា |
| ផ.យ.ជ.ម. | ផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន |
| ផ.យ.អ.ជ. | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
## នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**អារម្ភកថា**

ការកាត់បន្ថយភាពក្រីក្រ គឺជាគោលដៅចម្បងមួយនៃកិច្ចអភិវឌ្ឍន៍ប្រទេសជាតិរបស់រាជរដ្ឋាភិបាលកម្ពុជា។ បញ្ហាមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាមបានបណ្តាលឱ្យមានមនុស្សស្លាប់ និងរបួសរាប់ម៉ឺននាក់ និងបានបង្កនូវសោកនាដកម្មដ៏ឈឺចាប់សម្រាប់ប្រទេសកម្ពុជា ព្រមទាំងបានរាំងស្ទះដល់ការអភិវឌ្ឍប្រទេសជាតិទៀតផង។ រហូតមកដល់បច្ចុប្បន្ននេះ រាជរដ្ឋាភិបាលកម្ពុជា រួមជាមួយនឹងដៃគូអភិវឌ្ឍន៍បានប្រឹងប្រែងឆ្លើយតបយ៉ាងសកម្មទៅនឹងតម្រូវការផ្នែកមនុស្សធម៌និងការអភិវឌ្ឍ ដោយធ្វើការបោសសម្អាតផ្ទៃដីមានមីនបានជាច្រើនម៉ឺនហិកតាជូនដល់សហគមន៍មូលដ្ឋាន។ ប៉ុន្តែផលប៉ះពាល់ជាអវិជ្ជមានដោយសារមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម ចំពោះការកាត់បន្ថយភាពក្រីក្រនិងការអភិវឌ្ឍសេដ្ឋកិច្ចនៅកម្ពុជា នៅតែជាបញ្ហាចម្បងនៅឡើយ ដែលនាំឱ្យរាជរដ្ឋាភិបាលកម្ពុជាចាត់ទុកសកម្មភាពមីនជាអាទិភាពមួយដ៏សំខាន់នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។

បន្ទាប់ពីប្រទេសកម្ពុជាបានចូលជាសមាជិកនៃតំបន់ពាណិជ្ជកម្មសេរីអាស៊ាន ផលិតកម្មកសិកម្ម ការកសាងហេដ្ឋារចនាសម្ព័ន្ធ ការអភិវឌ្ឍសេដ្ឋកិច្ច និងវិស័យទេសចរណ៍ ត្រូវបានព្យាករថានឹងមានកំណើនក្នុងអត្រាមួយដ៏ជាទីមោទនៈ។ ប្រការនេះទាមទារឱ្យមានកិច្ចខិតខំប្រឹងប្រែងក្នុងការបោសសម្អាតមីនកាន់តែខ្លាំងក្លាបន្ថែមទៀត ដើម្បីផ្តល់ដីដែលមានសុវត្ថិភាពនៅក្នុងរយៈពេលមួយដ៏ខ្លីជូនប្រជាពលរដ្ឋ។ កម្ពុជាជាប្រទេសមួយក្នុងចំណោមប្រទេសដែលមានកំណើនសេដ្ឋកិច្ចលូតលាស់យ៉ាងឆាប់រហ័សបំផុតនៅក្នុងតំបន់ អត្រាកំណើនប្រចាំឆ្នាំក្នុងរង្វង់ ៧% ដែលជាលទ្ធផលនៃការកើនឡើងនូវការវិនិយោគផ្ទាល់ពីបរទេស និងការរីកចម្រើននៃវិស័យទេសចរណ៍ ព្រមទាំងវិស័យផ្សេងៗទៀត។ ក្នុងន័យនេះ កម្ពុជាត្រូវបន្តខិតខំប្រឹងប្រែងបោសសម្អាតមីនឱ្យកាន់តែសកម្មបន្ថែមទៀត ដើម្បីផ្តល់ដីដែលមានសុវត្ថិភាពជូនដល់ប្រជាពលរដ្ឋដែលកំពុងតែកើនឡើងយ៉ាងឆាប់រហ័ស និងត្រូវការដីជាចាំបាច់សម្រាប់ប្រើប្រាស់ប្រចាំថ្ងៃរបស់ពួកគេ។

ផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន២០១៨-២០២៥ ឆ្លើយតបទៅនឹងបញ្ហាប្រឈមទាំងឡាយដែលតម្រូវឱ្យរាជរដ្ឋាភិបាលត្រូវដោះស្រាយ ដើម្បីអភិវឌ្ឍ និងផ្តល់សុវត្ថិភាពដល់ប្រជាជនគ្រប់រូប។ ការកសាងផែនការយុទ្ធសាស្ត្រ គឺផ្អែកលើយុទ្ធសាស្ត្រដែលមានពីមុន ក៏ដូចជាចំណេះដឹង និងបទពិសោធន៍ដែលកម្ពុជាបានឆ្លងកាត់អស់រយៈពេល២៥ឆ្នាំកន្លងមក លើការងារបោសសម្អាតមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម។ ផ្អែកតាមមាត្រា៥ នៃអនុសញ្ញាស្តីពីការហាមការប្រើប្រាស់ ការរក្សាទុក ការផលិត និងការផ្ទេរគ្រាប់មីនប្រឆាំងមនុស្ស និងការបំផ្លាញគ្រាប់មីន យុទ្ធសាស្ត្រនេះបានគាំទ្រដល់ការស្នើសុំពន្យារពេលបោសសម្អាតមីនរបស់កម្ពុជារយៈពេល ៦ឆ្នាំបន្ថែមទៀត ចាប់ពីឆ្នាំ២០២០ ដល់ឆ្នាំ២០២៥។ នៅសន្និសីទម៉ាពុយតូស្តីពី «ពិភពលោកគ្មានមីន» កាលពីឆ្នាំ២០១៤ កម្ពុជាបានគាំទ្រដល់ «សេចក្តីថ្លែងការណ៍ម៉ាពុយតូ+១៥» ដែលមានមហិច្ឆតាបង្កើនកិច្ចខិតខំប្រឹងប្រែងឱ្យបានកាន់តែខ្លាំងក្លាបន្ថែមទៀត ក្នុងការធ្វើការបោសសម្អាតមីនឱ្យរួចរាល់ទាំងស្រុងនៅទូទាំងប្រទេសយ៉ាងយូរបំផុតនៅត្រឹមឆ្នាំ២០២៥។ ផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីននេះត្រូវបានដឹកនាំ និងសម្របសម្រួលរៀបចំដោយអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកម្ចាត់មីន និងសង្គ្រោះជនពិការដោយសារមីនហៅកាត់ថា «អាជ្ញាធរមីន» ព្រមទាំងមានការចូលរួមពិគ្រោះយោបល់យ៉ាងទូលំទូលាយជាមួយភាគីពាក់ព័ន្ធទាំង

ផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីននេះ គឺជាការបោះជំហានឆ្ពោះទៅមុខដ៏រឹងមាំ និងប្រកបដោយមហិច្ឆតា។ ការងារនេះតម្រូវឱ្យមានការលើកទឹកចិត្តដល់ប្រតិបត្តិករទាំងអស់ ធ្វើយ៉ាងណាពង្រឹងផលិតភាពរបស់ខ្លួន តាមរយៈការរិះរកមធ្យោបាយក្នុងការដោះស្រាយចំណុចខ្វះខាត និងការពិនិត្យឡើងវិញ និងការកែលម្អប្រព័ន្ធប្រតិបត្តិការ សំដៅធ្វើឱ្យការងារបោសសម្អាតមីននៅកម្ពុជាកាន់តែមានភាពប្រសើរឡើង។ ផែនការយុទ្ធសាស្ត្រជាតិនេះត្រូវបានរៀបចំឡើងដោយមានធាតុចូលពីគ្រប់ភាគីពាក់ព័ន្ធ សំដៅប្រើប្រាស់ធនធានបោសសម្អាតមីនឱ្យចំគោលដៅ និងធានាឱ្យជនងាយរងគ្រោះជាងគេជាអ្នកទទួលផលពិតប្រាកដ ព្រមទាំងលើកកម្ពស់អភិបាលកិច្ចល្អរបស់រាជរដ្ឋាភិបាល តាមរយៈការពង្រឹងសមត្ថភាពថ្នាក់ជាតិ ដើម្បីចាត់ចែងការងារបោសសម្អាតមីនឱ្យមានប្រសិទ្ធភាពនិងស៊ីសង្វាក់គ្នា ស្របតាមការប្តេជ្ញារបស់កម្ពុជាក្នុងការអនុវត្តច្បាប់អន្តរជាតិ។ ទន្ទឹមនឹងនេះ យុទ្ធសាស្ត្រនេះក៏នឹងចូលរួមចំណែកយ៉ាងសំខាន់ ក្នុងការរក្សាឱ្យបាននូវនិរន្តរភាពស្ថាប័នក្នុងការដោះស្រាយបញ្ហាមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាមដែលនៅសេសសល់ក្នុងរយៈពេលវែង។

ផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីននឹងត្រូវប្រើប្រាស់ជាឯកសារយោងតែមួយគត់ សម្រាប់គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ទាំងអស់ដែលមានចំណាប់អារម្មណ៍ក្នុងការគាំទ្រសកម្មភាពមីននៅប្រទេសកម្ពុជា។ ផែនការយុទ្ធសាស្ត្រជាតិនេះបានរំលេចនូវវិធានការ និងការអនុវត្តសកម្មភាពមួយចំនួន ដើម្បីធានាសម្រេចឱ្យបាននូវគោលដៅជាយុទ្ធសាស្ត្រ។ ឯកសារនេះដាក់ចេញនូវសូចនាករ និងចំណុចដៅសំខាន់ៗ និងកំណត់ពេលវេលាយ៉ាងជាក់លាក់ដែលនឹងជួយដល់ដៃគូអភិវឌ្ឍន៍ ក្នុងការរៀបចំកម្មវិធី និងគម្រោងរបស់ខ្លួនសម្រាប់គាំទ្រយុទ្ធសាស្ត្រនេះ។ ដើម្បីឱ្យផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីនទទួលបានជោគជ័យ ភាគីពាក់ព័ន្ធទាំងអស់ត្រូវសហការគ្នាយ៉ាងស្អិតរមួត មិនត្រឹមតែក្នុងអំឡុងពេលអនុវត្តផែនការយុទ្ធសាស្ត្រនេះប៉ុណ្ណោះទេ ប៉ុន្តែក្នុងការប្រមូលទិន្នន័យ និងព័ត៌មានដើម្បីត្រួតពិនិត្យលើការអនុវត្តយុទ្ធសាស្ត្រនេះ និងវាយតម្លៃលើការរួមចំណែករបស់យុទ្ធសាស្ត្រនេះចំពោះគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់កម្ពុជា។

ក្នុងនាមខ្ញុំជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានអាជ្ញាធរមីន ខ្ញុំសង្ឃឹមយ៉ាងមុតមាំថាភាគីពាក់ព័ន្ធទាំងអស់ ទាំងក្នុងជួររាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ នឹងយកផែនការយុទ្ធសាស្ត្រនេះទៅប្រើប្រាស់ជាត្រីវិស័យ និងជាគោលការណ៍រួមមួយ ដើម្បីបង្កើនប្រសិទ្ធភាព និងប្រសិទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងរបស់យើងទាំងអស់គ្នា។ កាយវិការនេះនឹងបង្ហាញពីការប្តេជ្ញាចិត្តរបស់យើងចំពោះសេចក្តីប្រកាសរួមស្តីពីសុខដុមនីយកម្មការតម្រឹម និងលទ្ធផលដែលយើងទាំងអស់គ្នាបានព្រមព្រៀង។ រាជរដ្ឋាភិបាលត្រៀមជាស្រេចដើម្បីសហការជាមួយភាគីពាក់ព័ន្ធទាំងអស់ ក្នុងការប្រែក្លាយកម្ពុជាឱ្យទៅជាប្រទេសមួយ ដែលគ្មានគ្រាប់មីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម។

ថ្ងៃអង្គារ ៥ រោច ខែ មិគសិរ ឆ្នាំ រកា ព.ស. ២៥៦១
ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី១២ ខែ ធ្នូ ឆ្នាំ២០១៧

**ហ៊ុន សែន**

# សេចក្តីសង្ខេប

ប្រទេសកម្ពុជាប្រឈមនឹងបញ្ហាជាច្រើនពាក់ព័ន្ធនឹងមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម (ស.ផ.ស.) ដែលជាលទ្ធផលនៃសង្គ្រាមរ៉ាំរ៉ៃអូសបន្លាយនៅក្នុងប្រទេស ចាប់តាំងពីដើមទសវត្សរ៍ឆ្នាំ១៩៦០ រហូតមកដល់ចុងឆ្នាំ១៩៩៨។ ស្ថានភាពទូទៅនៃបញ្ហាមីននិងស.ផ.ស.នៅកម្ពុជាមានលក្ខណៈស្មុគស្មាញយ៉ាងខ្លាំង ដោយសារចរិតសង្គ្រាមស៊ីវិលនិងសង្គ្រាមឈ្លានពានជាសម្ងាត់និងជាចំហ និងបណ្តាលមកពីកង្វះខាតកំណត់ត្រាព័ត៌មានអំពីទីតាំងបង្កប់គ្រាប់មីន និងការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកនៅកម្ពុជា។ ជាលទ្ធផល ប្រទេសកម្ពុជាបានរងការខូចខាតទាំងផ្នែកសេដ្ឋកិច្ចនិងសង្គម ព្រមទាំងបានទទួលរងនូវផលវិបាកមនុស្សជាតិយ៉ាងធ្ងន់ធ្ងរ។

មីននិងស.ផ.ស. បានបណ្តាលឱ្យមានមនុស្សស្លាប់និងរបួសរាប់ម៉ឺននាក់ ព្រមទាំងបង្កនូវសោកនាដកម្មដ៏ឈឺចាប់ដែលមិនធ្លាប់កើតមានពីមុនមក និងរាំងស្ទះដល់ការអភិវឌ្ឍប្រទេស។ ចាប់តាំងពីឆ្នាំ១៩៧៩មកជនរងគ្រោះដោយសារមីននិងស.ផ.ស. មានចំនួនយ៉ាងច្រើនសន្ធឹកសន្ធាប់។ ផ្អែកលើរបាយការណ៍នៃប្រព័ន្ធព័ត៌មានជនរងគ្រោះដោយសារមីននិងស.ផ.ស.នៅកម្ពុជា (ប.ព.ជ.ម.ក.) មានអ្នកស្លាប់និងរបួសដោយសារមីននិងស.ផ.ស. ចំនួន ៦៤ ៦៨៨នាក់ គិតចាប់ពីឆ្នាំ១៩៧៩ ដល់ឆ្នាំ២០១៧។

កម្មវិធីសកម្មភាពបោសសម្អាតមីននៅកម្ពុជាលក្ខណៈមនុស្សធម៌និងគ្រប់ជ្រុងជ្រោយបានចាប់ផ្តើមឡើងនៅឆ្នាំ១៩៩២។ នៅឆ្នាំ២០០០ កម្ពុជាបានក្លាយជារដ្ឋភាគីនៃអនុសញ្ញាអន្តរជាតិស្តីពីការហាមការប្រើប្រាស់ការរក្សាទុក ការផលិត និងការផ្ទេរគ្រាប់មីនប្រឆាំងមនុស្ស និងការបំផ្លាញគ្រាប់មីន (អ.ហ.ផ.ម)។ មាត្រា៥ នៃអនុសញ្ញានេះ ចែងអំពីកាតព្វកិច្ចរបស់រដ្ឋភាគីដែលត្រូវបំផ្លាញមីនប្រឆាំងមនុស្សទាំងអស់ ក្នុងរយៈពេលយ៉ាងយូរ១០ឆ្នាំ។ នៅឆ្នាំ២០០៩ ប្រទេសកម្ពុជាបានស្នើសុំពន្យារពេល ១០ឆ្នាំបន្ថែមទៀត ដើម្បីធ្វើការបោសសម្អាតផ្ទៃដីដែលដឹងថាមានគ្រាប់មីនទាំងអស់ឱ្យរួចរាល់នៅត្រឹមឆ្នាំ២០១៩។ ប៉ុន្តែ ផ្អែកលើការវាយតម្លៃលទ្ធភាពដែលអាចសម្រេចបាន ប្រទេសកម្ពុជានៅតែមិនអាចសម្រេចបានក្នុងការបោសសម្អាតមីនឱ្យរួចរាល់ជាស្ថាពរនៅឆ្នាំ២០១៩ ដោយសារកត្តាមួយចំនួន ដូចជាឧបសគ្គប្រតិបត្តិការដែលបង្កដោយបម្រែបម្រួលអាកាសធាតុ លក្ខណៈបច្ចេកទេស និងស្ថានភាពភូមិសាស្ត្រចម្ការមីន រួមទាំងការធ្លាក់ចុះនៃថវិកាជំនួយ។

នៅក្នុងសន្និសីទនៃការត្រួតពិនិត្យឡើងវិញ ស្តីពី «ពិភពលោកគ្មានមីន» កាលពីឆ្នាំ២០១៤ នៅទីក្រុងម៉ាពុយតូ ប្រទេសម៉ូសំប៊ិក ប្រទេសកម្ពុជាបានគាំទ្រដល់ «សេចក្តីថ្លែងការណ៍ម៉ាពុយតូ+១៥» ដែលមានមហិច្ឆិតាក្នុងការបង្កើនកិច្ចខិតខំប្រឹងប្រែងឱ្យបានកាន់តែខ្លាំងក្លាបន្ថែមទៀត សំដៅធ្វើការបោសសម្អាតមីនប្រឆាំងមនុស្សឱ្យរួចរាល់ទាំងស្រុងនៅត្រឹមឆ្នាំ២០២៥។ យោងតាមការសិក្សាវាយតម្លៃឯករាជ្យមួយលើវិស័យសកម្មភាពមីននៅកម្ពុជា ដែលបានធ្វើឡើងនៅឆ្នាំ២០១៦ ដោយមជ្ឈមណ្ឌលអន្តរជាតិទីក្រុងហ្សឺណែវសម្រាប់បោសសម្អាតមីនមនុស្សធម៌(GICHD) វិស័យសកម្មភាពមីននៅកម្ពុជាគួរត្រូវបានកែសម្រួលបន្ថែមទៀត និងកសាងផែនការយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយថ្មីមួយ ដើម្បីដាក់ចេញនូវទិសដៅអនាគតសម្រាប់កម្មវិធីសកម្មភាពមីននៅកម្ពុជាស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិនិងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣។ បន្ទាប់ពីមានការពិនិត្យឡើងវិញលើផ្នែកបច្ចេកទេសនិងការពិគ្រោះយោបល់ជាមួយគ្រប់ភាគីពាក់ព័ន្ធ រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចបង្កើតផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន ២០១៨-២០២៥ (ផ.យ.ជ.ម.) ថ្មីនេះឡើង ដោយផ្អែកលើ

បទពិសោធន៍ជាក់ស្តែង និងស្របតាមសក្តានុពលនាពេលបច្ចុប្បន្ន និងសុទិដ្ឋិនិយមចំពោះកិច្ចសហប្រតិបត្តិការនាពេលអនាគត។

ស្របតាមស្មារតីនៃ «សេចក្តីថ្លែងការណ៍ម៉ាពុយតូ+១៥» គោលបំណងមួយក្នុងចំណោមគោលបំណងចម្បងនានា គឺត្រូវរំដោះតំបន់ដែលដឹងថាមានមីនប្រឆាំងមនុស្សទាំងអស់នៅត្រឹមឆ្នាំ២០២៥។ ទន្ទឹមនឹងនេះ កម្ពុជាក៏ត្រូវខិតខំប្រឹងប្រែងឱ្យកាន់តែខ្លាំងក្លាបន្ថែមទៀត ដើម្បីធ្វើការបោសសម្អាតតំបន់ដែលមានគ្រាប់បែកចង្កោមជាអាទិភាពផងដែរ។ ទោះជាយ៉ាងណា នៅក្រោយឆ្នាំ២០២៥ អ្វីដែលនៅសេសសល់និងចាត់ទុកថាជាការគំរាមកំហែង ចាំបាច់ត្រូវមានយុទ្ធសាស្ត្រជាក់លាក់មួយដោយឡែក ដែលនឹងត្រូវរៀបចំឡើងដើម្បីបន្តដោះស្រាយការគំរាមកំហែងទាំងនោះ។

បន្ទាប់ពីកិច្ចខិតខំប្រឹងប្រែងក្នុងការបោសសម្អាតមីននិងស.ផ.ស អស់រយៈពេល ២៥ឆ្នាំកន្លងមកនេះ ផ្ទៃដីទំហំ **១ ៥៤៥គីឡូម៉ែត្រការ៉េ** ត្រូវបានបោសសម្អាតសម្រាប់យកទៅប្រើប្រាស់និងបង្កបង្កើនផល។ មីនប្រឆាំងមនុស្សចំនួន **១ ០៣៦ ៣៧៦គ្រាប់** និងមីនប្រឆាំងរថក្រោះ ចំនួន **២៤ ២៥១គ្រាប់** ព្រមទាំងស.ផ.ស.ចំនួន **២ ៦៦០ ៦៣៨គ្រាប់** ត្រូវបានរកឃើញនិងបំផ្លាញចោល។ ចំនួនអ្នកស្លាប់និងរបួសដោយសារមីននិងស.ផ.ស. ត្រូវបានកាត់បន្ថយពីចំនួន ៤ ៣២០នាក់ នៅឆ្នាំ១៩៩៦ មកត្រឹមប្រមាណ ១០០នាក់ ជាមធ្យមក្នុងមួយឆ្នាំ ក្នុងរយៈពេល ៥ឆ្នាំចុងក្រោយនេះ។ ទោះជាយ៉ាងណាក៏ដោយ ចំនួនអ្នករងរបួសនិងស្លាប់នាពេលបច្ចុប្បន្ននេះ នៅតែខ្ពស់ខ្លាំង ហើយផលប៉ះពាល់អវិជ្ជមានខាងផ្នែកសេដ្ឋកិច្ចសង្គម ផ្លូវចិត្ត និងរាងកាយមានកម្រិតយ៉ាងធំធេង ដែលមិនអាចទទួលយកបាន និងជាបន្ទុកផ្នែកសង្គមកិច្ចដ៏ធ្ងន់ធ្ងរសម្រាប់ប្រជាជននិងរាជរដ្ឋាភិបាល។ ដើម្បីទ្រទ្រង់ដល់ជំនួយគាំទ្រជនរងគ្រោះដោយសារមីននិងស.ផ.ស. អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកម្ចាត់មីន និងសង្គ្រោះជនពិការដោយសារមីន (ហៅកាត់ថា អាជ្ញាធរមីន) គឺជាយន្តការសម្របសម្រួលមួយ ស្ថិតក្រោមការដឹកនាំរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ធ្វើការកៀរគរធនធាននានារួមមានជំនួយបច្ចេកទេសនិងហិរញ្ញវត្ថុ ក៏ដូចជាការគាំទ្រផ្លូវចិត្តដល់គ្រួសារជនរងគ្រោះផងដែរ។ យន្តការនេះមានការចូលរួមពីក្រសួង ស្ថាប័នពាក់ព័ន្ធ ដូចជាក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងសុខាភិបាល និងក្រសួងពាក់ព័ន្ធផ្សេងទៀត អាជ្ញាធរថ្នាក់ក្រោមជាតិ កាកបាទក្រហមកម្ពុជា អង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជនផងដែរ។

សមិទ្ធផលនៃសកម្មភាពកម្ចាត់មីននិងគំនិតផ្តួចផ្តើមផ្សេងៗដូចរៀបរាប់ខាងលើនេះ អាចសម្រេចទៅបានអាស្រ័យដោយសារមានការរួមចំណែកដ៏សំខាន់ពីសហគមន៍អន្តរជាតិ និងកិច្ចខិតខំប្រឹងប្រែងយ៉ាងសកម្មរបស់រាជរដ្ឋាភិបាលកម្ពុជា។ ទោះបីជារាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍បានទទួលស្គាល់វឌ្ឍនភាពគួរឱ្យកត់សម្គាល់ក្នុងការដោះស្រាយបញ្ហាមីននិងស.ផ.ស.នៅកម្ពុជាក៏ដោយ បច្ចុប្បន្ននេះ មីននិងស.ផ.ស.នៅតែជាការគំរាមកំហែងនិងឧបសគ្គចម្បងចំពោះការអភិវឌ្ឍ។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលបានកំណត់គោលដៅសេដ្ឋកិច្ចក្នុងការប្រែក្លាយប្រទេសកម្ពុជា ទៅជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅត្រឹមឆ្នាំ២០៣០។ ដូច្នេះ បញ្ហាមីននិងស.ផ.ស. ត្រូវតែដោះស្រាយឱ្យបានទាន់ពេលវេលា។ យោងតាមរបាយការណ៍អំពីការស្រាវជ្រាវចម្ការមីនមូលដ្ឋាន ដែលធ្វើឡើងក្នុងពេលថ្មីៗកន្លងទៅនេះ បានបង្ហាញថា ផ្ទៃដីប្រមាណ **១ ៩៧០គីឡូម៉ែត្រការ៉េ** នៅមានមីននិងស.ផ.ស.នៅឡើយ។

បន្ទាប់ពីប្រទេសកម្ពុជាបានចូលជាសមាជិកនៃតំបន់ពាណិជ្ជកម្មសេរីអាស៊ាន ការកសាងហេដ្ឋារចនាសម្ព័ន្ធ ការអភិវឌ្ឍសេដ្ឋកិច្ច វិស័យទេសចរណ៍ និងផលិតកម្មកសិកម្ម ត្រូវបានព្យាករថានឹងមានកំណើនក្នុងអត្រាមួយដ៏ខ្ពស់ ដែលប្រការនេះទាមទារឱ្យមានកិច្ចខិតខំប្រឹងប្រែងក្នុងការដោះមីនកាន់តែខ្លាំងក្លាបន្ថែមទៀត ដើម្បីផ្តល់ដីដែលមានសុវត្ថិភាពនៅក្នុងរយៈពេលមួយដ៏ខ្លី។ កម្ពុជាជាប្រទេសមួយក្នុងចំណោមប្រទេសដែលមានសេដ្ឋកិច្ចលូតលាស់យ៉ាងឆាប់រហ័សបំផុតនៅក្នុងតំបន់ ក្នុងអត្រាកំណើនក្នុងរង្វង់ ៧% ដែលជាលទ្ធផលនៃការកើនឡើងនូវការវិនិយោគផ្ទាល់ពីបរទេស និងការរីកចម្រើននៃវិស័យទេសចរណ៍ ព្រមទាំងវិស័យផ្សេងៗទៀត។ លើសពីនេះទៀត ដើម្បីជួយសម្រួលដល់ពាណិជ្ជកម្មអន្តរតំបន់ កម្ពុជាបានបង្កើតតំបន់សេដ្ឋកិច្ចពិសេសជាច្រើននៅក្បែរព្រំដែនរបស់ប្រទេសកម្ពុជា ជាមួយប្រទេសជិតខាង ដែលនាំឱ្យមានកំណើនប្រជាជននិងការពង្រីកសហគមន៍នៅតាមតំបន់បណ្តោយព្រំដែន។ តំបន់ភាគច្រើននៅតាមបណ្តោយព្រំដែនភាគពាយព្យនៃប្រទេស ត្រូវបានរកឃើញថាជាតំបន់សម្បូរទៅដោយមីននិងស.ផ.ស. ដែលជាហេតុបណ្តាលឱ្យការរស់នៅរបស់ប្រជាជន និងការអភិវឌ្ឍនៅតំបន់ទាំងនោះប្រឈមនឹងហានិភ័យគ្រោះថ្នាក់ខ្ពស់។ ដើម្បីដោះស្រាយបញ្ហានេះ ភាគីពាក់ព័ន្ធទាំងអស់នៃវិស័យនេះ ត្រូវសហការគ្នាធ្វើការដោយឈរលើគោលការណ៍ភាពជាដៃគូ ដោយត្រូវទទួលស្គាល់អំពីតួនាទីរបស់រាជរដ្ឋាភិបាលក្នុងភាពជាម្ចាស់ ក្នុងការរំដោះផ្ទៃដីដែលមានមីននិងស.ផ.ស.ទាំងនេះ ប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធផល និងសុវត្ថិភាព សំដៅបញ្ចប់សោកនាដកម្មដ៏សែនឈឺចាប់ និងជំរុញការអភិវឌ្ឍនៅកម្ពុជា។

ផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន២០១៨-២០២៥ បានគូសបង្ហាញអំពីវិធីសាស្ត្រដែលកម្ពុជាត្រូវដោះស្រាយបញ្ហាមីននិងស.ផ.ស. ជាពិសេសដើម្បីបំផ្លាញចោលមីនប្រឆាំងមនុស្សទាំងអស់ឱ្យរួចរាល់នៅត្រឹមឆ្នាំ២០២៥។ ផែនការយុទ្ធសាស្ត្រនេះក៏បង្ហាញផងដែរអំពីការត្រៀមខ្លួនសម្រាប់ដោះស្រាយបញ្ហាគំរាមកំហែងទាំងឡាយដែលបន្សល់ទុកដោយសារមីននិងស.ផ.ស.នៅក្រោយឆ្នាំ២០២៥។ នៅក្នុងយុទ្ធសាស្ត្រនេះ កម្ពុជាបានកំណត់ចក្ខុវិស័យយ៉ាងច្បាស់លាស់ថា **«ប្រទេសកម្ពុជាគឺជាប្រទេសដែលគ្មានមីន ការគំរាមកំហែងដោយស.ផ.ស. ត្រូវបានកាត់បន្ថយឱ្យនៅកម្រិតអប្បបរមា ហើយការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងការអភិវឌ្ឍមនុស្សអាចប្រព្រឹត្តទៅដោយសុវត្ថិភាព»**។ ដើម្បីសម្រេចចក្ខុវិស័យនេះ ភាគីពាក់ព័ន្ធទាំងអស់ត្រូវចូលរួមក្នុងបេសកកម្មរំដោះរាល់តំបន់ដែលដឹងថាមានមីនទាំងអស់និងគ្រាប់បែកចង្កោមជាអាទិភាព និងកាត់បន្ថយហានិភ័យដែលនៅសេសសល់បណ្តាលមកពីស.ផ.ស.ផ្សេងទៀតនៅកម្ពុជា និងស្វែងរកការគាំទ្រមតិលើសិទ្ធិនិងផ្តល់សេវាកម្មសម្រាប់អ្នករស់រានមានជីវិតពីគ្រោះថ្នាក់ដោយសារមីននិងស.ផ.ស. ក៏ដូចជាជនរងគ្រោះដោយប្រយោល។ គោលបំណងចំនួន៨ និងគោលដៅយុទ្ធសាស្ត្រចំនួន២៧ ត្រូវបានដាក់ចេញឱ្យអនុវត្តដើម្បីសម្រេចឱ្យបាននូវចក្ខុវិស័យដែលបានកំណត់។ គោលបំណងចំនួន៨ មានដូចខាងក្រោម៖

គោលបំណងទី១ ៖ រំដោះផ្ទៃដីដែលដឹងថាមានមីនទាំងអស់នៅត្រឹមឆ្នាំ២០២៥។

គោលបំណងទី២ ៖ រំដោះផ្ទៃដីដែលដឹងថាមានគ្រាប់បែកចង្កោមជាអាទិភាពនៅត្រឹមឆ្នាំ២០២៥។

គោលបំណងទី៣ ៖ ដោះស្រាយរាល់ការគំរាមកំហែងពីស.ផ.ស.ផ្សេងទៀត។

គោលបំណងទី៤ ៖ កាត់បន្ថយចំនួនគ្រោះថ្នាក់ដោយសារមីននិងស.ផ.ស. ឱ្យនៅកម្រិតអប្បបរមា ព្រមទាំងលើកកម្ពស់ជីវភាពរស់នៅរបស់អ្នករស់រានមានជីវិត និងសហគមន៍ដែលរងផលប៉ះពាល់ដោយសារមីននិងស.ផ.ស.។

គោលបំណងទី៥ ៖ រួមចំណែកដល់កំណើនសេដ្ឋកិច្ចនិងការកាត់បន្ថយភាពក្រីក្រ។

គោលបំណងទី៦ ៖ ជំរុញនិសញ្ញាវុធការក្នុងតំបន់និងអន្តរជាតិ និងកិច្ចសហប្រតិបត្តិការនៅក្នុងសកម្មភាពមីន។

គោលបំណងទី៧ ៖ បង្កើតសមត្ថភាពជាតិប្រកបដោយនិរន្តរភាព សម្រាប់ដោះស្រាយបញ្ហាគំរាមគំហែងនានាដែលនៅសេសសល់ក្រោយឆ្នាំ២០២៥។

គោលបំណងទី៨ ៖ ធានាថារាល់សកម្មភាពបោសសម្អាតមីន ត្រូវបានគាំទ្រដោយប្រព័ន្ធគ្រប់គ្រងគុណភាពកម្រិតខ្ពស់ និងការគ្រប់គ្រងព័ត៌មានប្រកបដោយប្រសិទ្ធភាព ហើយត្រូវយកចិត្តទុកដាក់ខ្ពស់ដល់បញ្ហាយេនឌ័រ និងបរិស្ថាន។

កម្ពុជាមានសុទិដ្ឋិនិយមខ្ពស់ចំពោះវិស័យសកម្មភាពមីននៅកម្ពុជា ក្នុងគោលដៅបោសសម្អាតមីនប្រឆាំងមនុស្សឱ្យអស់ពីតំបន់ដែលបានកំណត់រួចហើយនៅត្រឹមឆ្នាំ២០២៥។ ប្រការនេះនឹងតម្រូវឱ្យមានការពង្រឹងកិច្ចខិតខំប្រឹងប្រែងក្នុងការសម្របសម្រួលដំណើរការធ្វើផែនការ និងការចាត់អាទិភាពដើម្បីឱ្យធនធានដែលខ្សត់ខ្សោយត្រូវបានប្រើប្រាស់ចំគោលដៅយ៉ាងប្រសើរបំផុត ការពង្រឹងវិធីសាស្ត្ររំដោះផ្ទៃដី ឧបករណ៍និងបច្ចេកទេសបោសសម្អាត និងការជំរុញការការស្រាវជ្រាវឱ្យបានជាប់លាប់ ពិសេសជាងនេះទៅទៀត គឺការគាំទ្រហិរញ្ញវត្ថុឱ្យបានគ្រប់គ្រាន់។

ស្ថានភាពកម្ពុជានៅតែមានការវិវត្តប្រែប្រួល ហេតុដូច្នេះ វិស័យនេះក៏ត្រូវតែស្ថិតក្នុងស្ថានភាពប្រុងប្រយ័ត្ននិងឆ្លើយតបទៅនឹងកាលៈទេសៈប្រែប្រួលនានាដែរ ដើម្បីធានាថាកម្មវិធីសកម្មភាពមីនមានប្រសិទ្ធភាពជានិច្ចដោយស្ថិតលើមាគ៌ាមួយដ៏ត្រឹមត្រូវ ហើយត្រូវស្របតាមយុទ្ធសាស្ត្រ និងគោលនយោបាយជាតិផ្សេងទៀតផងដែរ។ ដើម្បីគ្រប់គ្រងការអនុវត្តផ.យ.ជ.ម.២០១៨-២០២៥ ឱ្យមានប្រសិទ្ធភាព ការអនុវត្តផែនការយុទ្ធសាស្ត្រនេះត្រូវបានបែងចែកជាពីរដំណាក់កាល ដោយដំណាក់កាលទី១ ចាប់ផ្តើមពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២២ និងដំណាក់កាលទី២ ចាប់ពីឆ្នាំ២០២៣ ដល់ឆ្នាំ២០២៥។ នៅក្នុងក្របខ័ណ្ឌនៃយុទ្ធសាស្ត្រជាតិនេះ វិស័យសកម្មភាពមីននឹងនៅតែបន្តអនុវត្តតាមក្របខ័ណ្ឌស្ថាប័នបច្ចុប្បន្ន ដោយធ្វើការបែងចែកមុខងារនិយ័តកម្ម សម្របសម្រួលនិងតាមដានត្រួតពិនិត្យ ឱ្យដាច់ពីប្រតិបត្តិការដោះមីននិងប្រតិបត្តិការនានាដែលពាក់ព័ន្ធនឹងសកម្មភាពមីន ដែលមានបណ្តាប្រតិបត្តិករបច្ចុប្បន្ននៅបន្តសកម្មភាពតទៅមុខទៀត។ វិធានការប្រតិបត្តិដែលមានប្រសិទ្ធភាពនាពេលបច្ចុប្បន្ននឹងត្រូវបន្តអនុវត្ត ហើយធ្វើការកែលម្អឱ្យកាន់ប្រសើរឡើងបន្ថែមទៀត ក្នុងនោះរួមមានការស្រាវជ្រាវចម្ការមីនមូលដ្ឋាន ការធ្វើផែនការនិងការចាត់អាទិភាព ការរំដោះផ្ទៃដីចម្ការមីន ការអប់រំកាត់បន្ថយគ្រោះថ្នាក់មីននិងស.ផ.ស. កិច្ចជួយសង្គ្រោះជនរងគ្រោះ ប្រព័ន្ធគ្រប់គ្រងព័ត៌មាន ការបញ្ជ្រាបយេនឌ័រ និរន្តរភាពបរិស្ថានការអភិវឌ្ឍសមត្ថភាព និសញ្ញាវុធការក្នុងតំបន់និងអន្តរជាតិ និងកិច្ចខិតខំប្រឹងប្រែងដើម្បីរក្សាសមត្ថភាពឱ្យមាននិរន្តរភាពសម្រាប់ក្រោយឆ្នាំ២០២៥។

ភាពជាដៃគូក្នុងសកម្មភាពមីនលក្ខណៈមនុស្សធម៌នៅកម្ពុជា ពិតជាមានសារៈសំខាន់ណាស់សម្រាប់ការអនុវត្តកម្មវិធីជួយសង្គ្រោះជីវិតមនុស្ស និងគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ក្នុងការដោះស្រាយបញ្ហាមីននិងស.ផ.ស.នៅក្នុងប្រទេស ចាប់តាំងពីឆ្នាំ១៩៩២មក។ ភ្នាក់ងារផ្តល់ជំនួយអន្តរជាតិ ទាំងពហុភាគីនិងទ្វេភាគីបានជួយថវិកាជាច្រើនសម្រាប់ការចំណាយលើកម្មវិធីសកម្មភាពមីន។ ដើម្បីសម្រេចគោលបំណងបោសសម្អាតមីននិងស.ផ.ស.ឱ្យអស់ត្រឹមឆ្នាំ២០២៥ កម្ពុជាត្រូវការថវិកាប្រមាណ **៣៥៤លានដុល្លារអាមេរិក** សម្រាប់ធ្វើការបោសសម្អាតរំដោះផ្ទៃដី និងថវិកាប្រមាណ **០,៦លានដុល្លារអាមេរិក** សម្រាប់ការស្រាវជ្រាវចម្ការមីន

មូលដ្ឋាន ព្រមទាំង **៥២លានដុល្លារអាមេរិក**ទៀត សម្រាប់ការអប់រំកាត់បន្ថយគ្រោះថ្នាក់មីន/ស.ផ.ស កិច្ចជួយសង្គ្រោះជនរងគ្រោះ ការស្វែងរកការគាំទ្រមតិ និងការគ្រប់គ្រងវិស័យសកម្មភាពមីន។ វិស័យសកម្មភាពមីនកម្ពុជាបានព្យាករថា កម្ពុជាត្រូវការថវិកាសរុបប្រមាណ **៤០៦លានដុល្លារអាមេរិក** ដើម្បីគាំទ្រសកម្មភាពដែលមានចែងក្នុងផែនការយុទ្ធសាស្ត្រនេះ។

ការប្រែប្រួលនៃការផ្តល់ជំនួយអន្តរជាតិសម្រាប់សកម្មភាពមីន មានការពាក់ព័ន្ធទៅនឹងភាពមិនប្រាកដប្រជារបស់ពិភពលោក ដែលបណ្តាលមកពីកត្តាសេដ្ឋកិច្ចនិងនយោបាយ ហើយនៅក្នុងស្ថានភាពបែបនេះ កម្ពុជាចាំបាច់ត្រូវមានវិធានការសមស្រប ដើម្បីធ្វើការកៀរគរធនធានប្រកបដោយប្រសិទ្ធភាពខ្ពស់។ កំណើនផលិតផលក្នុងស្រុកសរុបបានកើនឡើងជាលំដាប់គួរឱ្យកត់សម្គាល់ បានធ្វើឱ្យប្រទេសកម្ពុជាក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាប ដែលនេះធ្វើឱ្យភាពអំណោយផលសម្រាប់ការទទួលបានថវិកាជំនួយសង្គ្រោះបន្ទាន់ នឹងត្រូវថយចុះជាងមុន។ ធនធានត្រូវបានកៀរគរដោយមានយុទ្ធសាស្ត្រត្រឹមត្រូវ ដើម្បីទាក់ទាញឱ្យមានការចូលរួមពីសំណាក់ម្ចាស់ជំនួយដែលមានស្រាប់និងម្ចាស់ជំនួយថ្មីបន្ថែមទៀត។ វិស័យសកម្មភាពមីននៅកម្ពុជានឹងត្រូវបន្តដោយភាពច្នៃប្រឌិតបន្ថែមទៀត ដើម្បីរិះរកវិធីថ្មីៗដែលមានប្រសិទ្ធភាពបំផុត ក្នុងការរំដោះផ្ទៃដីនិងធ្វើការអំពាវនាវប្រកបដោយភាពទាក់ទាញដល់ម្ចាស់ជំនួយនានា សំដៅជំរុញគម្រោងដោះមីនលក្ខណៈមនុស្សធម៌នៅកម្ពុជា។ វិស័យសកម្មភាពមីននៅកម្ពុជា បានឈានដល់ចំណុចរបត់មួយនៃការផ្លាស់ប្តូរពីការផ្តល់ថវិកាពីប្រភពខាងក្រៅប្រទេស មកជាការផ្តល់ថវិកាពីប្រភពនៅក្នុងប្រទេសវិញ ដែលប្រការនេះនឹងធ្វើឱ្យជំនួយអន្តរជាតិមានថយចុះជាបណ្តើរៗ ហើយរាជរដ្ឋាភិបាលនឹងត្រូវទទួលបន្ទុកកាន់តែច្រើនជាងមុន ក្នុងការដោះស្រាយបញ្ហាមីននិងស.ផ.ស. នៅត្រឹមឆ្នាំ២០២៥ ព្រមទាំងត្រូវពង្រឹងសមត្ថភាពរបស់ខ្លួនដើម្បីត្រៀមដោះស្រាយការគំរាមកំហែងនានាដែលនៅសេសសល់នៅក្រោយឆ្នាំ២០២៥ផងដែរ។

ផ.យ.ជ.ម.២០១៨-២០២៥ គឺជាមាគ៌ាឆ្ពោះទៅមុខសំដៅបំពេញបេសកកម្មដែលបានចែងខាងលើ ស្របតាមអាណត្តិដែលបានកំណត់។ យុទ្ធសាស្ត្រនេះបានយកបណ្តាយុទ្ធសាស្ត្រនិងផែនការជាតិ ដែលទាក់ទិននឹងសកម្មភាពមីននិងវិស័យពាក់ព័ន្ធផ្សេងៗ មកធ្វើការពិចារណាដើម្បីធានាបានការរួមចំណែកដល់គំនិតផ្តួចផ្តើមថ្នាក់ជាតិ។ វាក៏ឆ្លុះបញ្ចាំងអំពីបរិយាកាសទូទៅនៃសកម្មភាពមីនជាសកលផងដែរ។ ផែនការយុទ្ធសាស្ត្រនេះដើរតួនាទីជាផែនទីបង្ហាញផ្លូវសម្រាប់ធ្វើការវាស់ស្ទង់សកម្មភាពរបស់វិស័យនេះ ព្រមទាំងកំណត់គោលដៅនិងគោលបំណងជាក់លាក់ដែលត្រូវសម្រេចឱ្យបាននៅក្នុងរយៈពេលនៃការអនុវត្តយុទ្ធសាស្ត្រនេះ។

# ១. សេចក្តីផ្តើម

ជម្លោះក្នុងប្រទេស ដែលបានអូសបន្លាយអស់រយៈពេលយ៉ាងយូរ ចាប់ពីដើមទសវត្សរ៍ឆ្នាំ១៩៦០ រហូតដល់ចុងឆ្នាំ១៩៩៨ បានធ្វើឱ្យកម្ពុជាក្លាយជាប្រទេសមួយក្នុងចំណោមប្រទេសដែលមានមីននិងស.ផ.សច្រើនជាងគេនៅលើពិភពលោក។ ខេត្តភាគខាងកើតនៃប្រទេសកម្ពុជាមានគ្រាប់បែកចង្កោមនិងស.ផ.ស.ផ្សេងៗទៀតជាច្រើន ដែលជាលទ្ធផលនៃការទម្លាក់គ្រាប់បែកយ៉ាងសន្ធឹកសន្ធាប់ក្នុងអំឡុងសង្គ្រាមវៀតណាម។ យោងតាមព័ត៌មានរបស់ក្រសួងការបរទេសសហរដ្ឋអាមេរិកបានឱ្យដឹងថា ចាប់ពីឆ្នាំ១៩៦៥ ដល់ឆ្នាំ១៩៧៣ សហរដ្ឋអាមេរិកបានទម្លាក់គ្រាប់បែកចំនួន ២,៧៥លានតោនមកលើប្រទេសកម្ពុជា ក្នុងនោះមានគ្រាប់បែកចង្កោមមានប្រមាណ ២៧,៩លានគ្រាប់។ ជាមួយគ្នានេះ យើងបានរកឃើញគ្រាប់បែកគីមីដែលត្រូវបានទម្លាក់ដោយសហរដ្ឋអាមេរិកនៅលើទឹកដីកម្ពុជាផងដែរ។ ប្រមាណ ៣០%[1] នៃគ្រាប់បែកដែលបានទម្លាក់ មិនបានផ្ទុះនៅពេលប៉ះទង្គិចដូចដែលបានរំពឹងទុកឡើយ ដែលប្រការនេះបានបន្សល់ទុកនូវគ្រាប់យុទ្ធភណ្ឌមិនទាន់ផ្ទុះនិងស.ផ.ស.ដ៏គ្រោះថ្នាក់ផ្សេងទៀតរហូតមកដល់សព្វថ្ងៃនេះ។ ជាមួយគ្នានេះដែរ សង្គ្រាមស៊ីវិលនិងសង្គ្រាមឈ្លានពានជាសម្ងាត់និងជាចំហចាប់ពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៩៨ បានបន្សល់នូវស.ផ.ស.រាយប៉ាយពាសពេញផ្ទៃប្រទេស ទាំងនៅលើដីនិងក្រោមទឹកផងដែរ។

នៅខែមេសា ឆ្នាំ១៩៧៥ ក្រោមរបបខ្មែរក្រហម មនុស្សប្រមាណ ២លាននាក់បានបាត់បង់ជីវិត ដោយសារការកាប់សម្លាប់ ពលកម្មដោយបង្ខំ ភាពអត់ឃ្លាន និងកង្វះការថែទាំសុខភាព។ បន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហមនៅខែមករា ឆ្នាំ១៩៧៩ ជម្លោះប្រដាប់អាវុធផ្ទៃក្នុងបានបន្តរហូតដល់ចុងឆ្នាំ១៩៩៨។ ក្នុងអំឡុងពេលនៃសង្គ្រាមនោះ ភាគីជម្លោះទាំងអស់សុទ្ធតែបានដាក់ពង្រាយមីន ដែលតាមការប៉ាន់ស្មានមានចំនួនប្រមាណ ៤លានគ្រាប់។ ភាគីប្រដាប់អាវុធទាំងអស់បានប្រើប្រាស់គ្រាប់មីនដែលផលិតនៅប្រទេសផ្សេងគ្នា ហើយគ្រាប់មីនដែលបានរកឃើញភាគច្រើនគឺផលិតនៅប្រទេសប៊ែលហ្ស៊ិក អតីតអាល្លឺម៉ង់ខាងកើត ប្រទេសចិន អតីតឆេកូស្លូវ៉ាគី សហរដ្ឋអាមេរិក អតីតសហភាពសូវៀត និងប្រទេសវៀតណាម។ តំបន់ដែលមានមីនច្រើនបំផុតនិងដែលត្រូវបានកត់ត្រាទុកគឺតំបន់ដែលស្ថិតនៅតាមបណ្តោយព្រំដែនភាគពាយព្យនៃប្រទេស ដែលត្រូវបានចាត់ទុកថាជាតំបន់សម្បូរទៅដោយចម្ការមីនមួយក្នុងចំណោមតំបន់នានា ដែលមានដង់ស៊ីតេមីនខ្ពស់ជាងគេបំផុតនៅក្នុងពិភពលោក។ សមរភូមិជើងគោកក្នុងអំឡុងសង្គ្រាមបណ្តាលឱ្យមានគ្រាប់យុទ្ធភណ្ឌមិនទាន់ផ្ទុះ និងគ្រាប់កាំភ្លើងរាយប៉ាយនៅទូទាំងប្រទេសកម្ពុជា។

មីននិងស.ផ.ស. ដែលត្រូវបានប្រើប្រាស់ក្នុងអំឡុងពេលមានសង្គ្រាមនៅតែបន្តបង្កសោកនាដកម្មដល់មនុស្សនិងសេដ្ឋកិច្ចសង្គមនៅតាមបណ្តាប្រទេសដែលទទួលរងផលប៉ះពាល់ បើទោះបីជាសង្គ្រាមបានបញ្ចប់ទៅយូរហើយក៏ដោយ។ វាបានរាំងដល់កិច្ចខិតខំប្រឹងប្រែងក្នុងការស្តារសមត្ថភាពប្រកបរបរចិញ្ចឹមជីវិត និងធ្វើឱ្យចុះខ្សោយនៃការកសាងភាពធន់របស់សហគមន៍នៅក្នុងប្រទេសដែលរងផលប៉ះពាល់។ ការលុបបំបាត់មីនក៏ដូចជាការលុបបំបាត់ទុក្ខវេទនាដែលបណ្តាលមកពីមីន គឺជាកាតព្វកិច្ចរបស់ប្រទេសនីមួយៗ និងប្រជាពលរដ្ឋគ្រប់រូបរបស់ខ្លួន ព្រមទាំងត្រូវមានការចូលរួមជាសកលផងដែរ។ កម្ពុជាគឺជាប្រទេសមួយក្នុងចំណោមប្រទេសជាច្រើន

[1] គ្រាប់បែកចង្កោម៖ http://legaciesofwar.org/about-laos/cluster-munitions/

ដែលមានមីននិងស.ផ.ស.ដ៏ច្រើនលើសលប់នៅលើពិភពលោក។ ទោះបីជាមានកិច្ចប្រឹងប្រែងបោសសម្អាតមីនចាប់តាំងពីឆ្នាំ១៩៩២ កម្ពុជានៅតែទទួលរងផលប៉ះពាល់ដោយសារមីននិងស.ផ.ស.នៅឡើយ។

នៅកម្ពុជា វត្តមានមីននិងស.ផ.ស.មានសភាពស្មុគស្មាញជាខ្លាំង។ ខេត្តភាគពាយព្យបានទទួលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយសារមីននិងស.ផ.ស. ហើយខេត្តភាគកណ្តាលបានទទួលរងផលប៉ះពាល់ក្នុងកម្រិតមធ្យមដោយសារមីននិងស.ផ.ស. ខណៈដែលខេត្តភាគខាងកើតបានទទួលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយសារស.ផ.ស. រួមទាំងគ្រាប់បែកចង្កោមផងដែរ។ ការស្រាវជ្រាវអំពីមីននិងស.ផ.ស.កម្រិត១ (L1S) ដែលត្រូវបានធ្វើឡើងចាប់ពីចុងឆ្នាំ២០០០ ដល់ខែមេសា ឆ្នាំ២០០២ បានបង្ហាញថា ៤៦% នៃចំនួនភូមិសរុបក្នុងប្រទេសកម្ពុជា (៦ ៤១៦ភូមិ) បានទទួលរងផលប៉ះល់ដោយសារមីននិងស.ផ.ស. និងត្រូវបានពិនិត្យឃើញថាវត្តមានគ្រាប់មីនបានធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់លទ្ធភាពក្នុងការប្រកបរបរចិញ្ចឹមជីវិតរបស់ប្រជាជន។ យោងតាមការសន្និដ្ឋានបឋម ដីទំហំ **៤ ៥៤៤គីឡូម៉ែត្រការ៉េ** ត្រូវបានសង្ស័យថាមានមីននិងស.ផ.ស.។ ក្នុងឆ្នាំ២០០៩ ដោយសារតែមានភាពចាំបាច់ក្នុងការកំណត់ទំហំបញ្ហាមីនដែលនៅសេសសល់ក្នុងប្រទេសកម្ពុជា និងកំណត់ឡើងវិញឱ្យបានច្បាស់លាស់អំពីលក្ខណៈទូទៅនៃស្ថានភាពមីន ដើម្បីគាំទ្រដល់សំណើសុំបន្តការអនុវត្តមាត្រា៥ នៃអ.ហ.ផ.ម. ការស្រាវជ្រាវចម្ការមីនមូលដ្ឋាននៅទូទាំងប្រទេសត្រូវបានផ្តួចផ្តើមនិងអនុវត្តក្រោមការសម្របសម្រួលរបស់អាជ្ញាធរមីន។ បច្ចុប្បន្ននេះ លទ្ធផលពីការស្រាវជ្រាវចម្ការមីនមូលដ្ឋានបានបង្ហាញថា ផ្ទៃដីទំហំ **១ ៩៧០ គីឡូម៉ែតការ៉េ** នៅតែស្ថិតក្នុងបញ្ជីដីមានមីន ដែលធ្វើឱ្យកម្ពុជានៅតែជាប្រទេសមួយក្នុងចំណោមប្រទេសនានាដែលរងគ្រោះដោយសារមីននិងស.ផ.ស. ក្នុងកម្រិតខ្ពស់បំផុតនៅលើពិភពលោក។

ដើម្បីដោះស្រាយផលប៉ះពាល់ជាអវិជ្ជមានដោយសារមីននិងស.ផ.ស. រាជរដ្ឋាភិបាលកម្ពុជាបានខិតខំយ៉ាងសកម្មប្រកបដោយភាពម្ចាស់ការក្នុងការដោះស្រាយបញ្ហាមីននិងស.ផ.ស.។ សកម្មភាពបោសសម្អាតមីនលក្ខណៈមនុស្សធម៌បានចាប់ផ្តើមជាផ្លូវការនៅក្នុងប្រទេសកម្ពុជានៅឆ្នាំ១៩៩២។

នៅថ្ងៃទី១ ខែមករា ឆ្នាំ២០០០ កម្ពុជាបានក្លាយជារដ្ឋភាគីនៃអនុសញ្ញាអន្តរជាតិស្តីពីការហាម ការប្រើប្រាស់ ការលុបបំបាត់ ការរក្សាទុក ការផលិត និងការផ្ទេរគ្រាប់មីនប្រឆាំងមនុស្ស និងការបំផ្លាញគ្រាប់មីន (អ.ហ.ផ.ម.)។ មាត្រា៥ នៃអនុសញ្ញានេះ បានចែងអំពីកាតព្វកិច្ចរបស់រដ្ឋភាគីទាំងអស់ដែលត្រូវបំផ្លាញមីនប្រឆាំងមនុស្សឱ្យអស់ក្នុងរយៈពេល ១០ឆ្នាំ។ ដោយទំហំនៃបញ្ហាមីននៅកម្ពុជាមានភាពស្មុគស្មាញនិងធំធេងពេក ទើបកម្ពុជាមិនអាចបញ្ចប់ការបោសសម្អាតតំបន់ដែលដឹងថាមានមីនទាំងអស់ឱ្យសម្រេចបានតាមការគ្រោងទុក។ កម្ពុជាបានស្នើសុំពន្យារពេលបន្ថែមទៀត ហើយនៅខែធ្នូ ឆ្នាំ២០០៩ កម្ពុជាទទួលបានការយល់ព្រមឱ្យពន្យារពេល១០ឆ្នាំបន្ថែមទៀត (រហូតដល់ ថ្ងៃទី១ ខែមករា ឆ្នាំ២០២០)។ ក្រោយពីទទួលបានការយល់ព្រមឱ្យពន្យារពេល ផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន២០១០-២០១៩ ត្រូវបានរៀបចំឡើងជាគោលការណ៍ណែនាំយុទ្ធសាស្ត្រ ដើម្បីធ្វើការបោសសម្អាតមីនទាំងអស់ដែលបានដឹងនៅត្រឹមឆ្នាំ២០១៩។

កម្ពុជាបានចូលរួមផងដែរជាសមាជិកនៃបណ្តាកិច្ចព្រមព្រៀងអន្តរជាតិនៃមនុស្សធម៌ និងនិសព្វាវុធការអន្តរជាតិនានា រួមមានដូចជាអនុសញ្ញាសព្វាវុធធម្មតាមួយចំនួន(CCW) (ពិធីសារទី១ ទី២ ទី៣ និងទី៤)[២]

---

[២] ពិធីសារ I៖ Non-detectable fragments; ពិធីសារ II៖ មីន booby-traps, ឧបករណ៍ផ្សេងៗទៀត ពិធីសារ III៖ Incendiary weapons; ពិធីសារ IV៖ Blinding Laser Weapons.

អនុសញ្ញាហាមប្រាមការប្រើប្រាស់មីនប្រឆាំងមនុស្ស (អ.ហ.ផ.ម.) អនុសញ្ញាស្តីពីសិទ្ធិជនពិការ ព្រមទាំងចូលរួមក្នុងគំនិតផ្តួចផ្តើមសហប្រតិបត្តិការផ្សេងៗទៀតទាក់ទងនឹងសកម្មភាពមីន។ ទោះបីជាកម្ពុជាមិនទាន់បានក្លាយជាប្រទេសហត្ថលេខីនៃអនុសញ្ញាស្តីពីគ្រាប់បែកចង្កោម(CCM) ក៏ដោយ កម្ពុជាបានចូលរួមស្ទើរតែគ្រប់កិច្ចប្រជុំពាក់ព័ន្ធនឹងអនុសញ្ញានេះ ក្នុងនាមជាអ្នកសង្កេតការណ៍។ កម្ពុជាបានបង្ហាញអំពីគោលជំហរគាំទ្ររបស់ខ្លួនចំពោះអនុសញ្ញានេះ ហើយបានពិនិត្យឡើងវិញជាប្រចាំអំពីលទ្ធភាពរបស់ខ្លួនក្នុងការអនុលោមតាមកាតព្វកិច្ចនានាដែលជាលក្ខខណ្ឌតម្រូវនៃអនុសញ្ញានេះ។ ប្រទេសកម្ពុជាគឺជាប្រទេសមួយក្នុងតំបន់ដែលមិនធ្លាប់បានផលិតប្រើប្រាស់ ឬនាំចេញគ្រាប់បែកចង្កោមនោះឡើយ។

ផ្អែកតាមការវាយតម្លៃទៅលើលទ្ធភាពដែលអាចសម្រេចគោលដៅនៃវិស័យនេះ បានពិនិត្យឃើញថាឧបសគ្គប្រតិបត្តិការនិងហិរញ្ញវត្ថុ គឺជាបញ្ហាប្រឈមសម្រាប់កិច្ចការបោសសម្អាតមីននៅកម្ពុជា។ ជាក់ស្តែង ចំពោះឧបសគ្គប្រតិបត្តិការ ការប្រែប្រួលអាកាសធាតុបានបង្កជាការពិបាកដល់ការព្យាករអាកាសធាតុ ពេលគឺរដូវភ្លៀងមានរយៈពេលវែងជាងមុន។ ទន្ទឹមនឹងនេះ ស្ថានភាពភូមិសាស្ត្រចម្ការមីនកាន់តែមានភាពស្មុគស្មាញច្រើន និងពិបាកធ្វើប្រតិបត្តិការបោសសម្អាត។ ចំណែកឧបសគ្គហិរញ្ញវត្ថុ គេសង្កេតឃើញថា ដោយសារមានការផ្លាស់ប្តូរនៃការចាត់អាទិភាពថវិការបស់ម្ចាស់ជំនួយមួយចំនួន ជំនួយហិរញ្ញវត្ថុសម្រាប់វិស័យសកម្មភាពមីននៅកម្ពុជាបានធ្លាក់ចុះគួរឱ្យកត់សម្គាល់។ កត្តាទាំងនេះ គឺជាមូលហេតុដែលធ្វើឱ្យផែនការបោសសម្អាតមីននិងស.ផ.ស.ទាំងស្រុងនៅត្រឹមឆ្នាំ២០១៩ មិនអាចសម្រេចបានតាមការគ្រោងទុកឡើយ និងតម្រូវឱ្យកម្ពុជាត្រូវដាក់ពាក្យស្នើសុំពន្យារពេលជាថ្មីម្តងទៀត។

នៅសន្និសីទម៉ាពុយតូស្តីពី «ពិភពលោកគ្មានមីន» កាលពីឆ្នាំ២០១៤ ប្រទេសកម្ពុជាបានគាំទ្រដល់«សេចក្តីថ្លែងការណ៍ម៉ាពុយតូ+១៥» ដោយមានមហិច្ឆតាបង្កើនកិច្ចខិតខំប្រឹងប្រែងឱ្យបានកាន់តែខ្លាំងក្លាបន្ថែមទៀតសំដៅធ្វើការបោសសម្អាតមីនទាំងស្រុងឱ្យបានសម្រេចជាស្ថាពរយ៉ាងយូរបំផុតនៅត្រឹមឆ្នាំ២០២៥។ នៅខែកញ្ញាឆ្នាំ២០១៥ កម្ពុជាបានចាប់ផ្តើមដំណើរការនៃការត្រួតពិនិត្យឡើងវិញនូវផែនការយុទ្ធសាស្ត្រ ២០១០-២០១៩ និងសម្រេចកសាងផែនការយុទ្ធសាស្ត្រថ្មីរបស់ខ្លួន។ នៅឆ្នាំ២០១៦ ការសិក្សាវាយតម្លៃឯករាជ្យមួយលើវិស័យសកម្មភាពមីននៅកម្ពុជា ដែលបានធ្វើឡើងដោយមជ្ឈមណ្ឌលអន្តរជាតិទីក្រុងហ្សឺណែវសម្រាប់បោសសម្អាតមីនមនុស្សធម៌ បានផ្តល់ជាអនុសាសន៍ថា វិស័យសកម្មភាពមីននៅកម្ពុជាគួរតែត្រូវបានកែសម្រួលបន្ថែមទៀត និងត្រូវកសាងផែនការយុទ្ធសាស្ត្រមួយថ្មីដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ដើម្បីកំណត់ទិសដៅអនាគតសម្រាប់កម្មវិធីសកម្មភាពមីនលក្ខណៈមនុស្សធម៌នៅកម្ពុជា។

កម្ពុជាបានចាប់ផ្តើមរៀបចំផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន ២០១៨-២០២៥នេះឡើង ចាប់តាំងពីចុងឆ្នាំ២០១៥មក។ អាជ្ញាធរមីនទទួលភារកិច្ចដឹកនាំការងារនេះ ដោយអនុម័តយកវិធីសាស្ត្របែបពិគ្រោះយោបល់និងមានការចូលរួមពីភាគីពាក់ព័ន្ធ។ គណៈកម្មាធិការតម្រង់ទិសត្រូវបានបង្កើតឡើងដើម្បីផ្តល់ទិសដៅជាយុទ្ធសាស្ត្រដល់ការរៀបចំផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីននេះ។ ក្រុមការងារបច្ចេកទេសចំនួន៥ (ផ្នែកបោសសម្អាតមីន/ស.ផ.ស. កិច្ចជួយសង្គ្រោះជនរងគ្រោះ ការអប់រំកាត់បន្ថយគ្រោះថ្នាក់មីន/ស.ផ.ស. ការគ្រប់គ្រងព័ត៌មាននិងយេនឌ័រ) ត្រូវបានបង្កើតឡើងដើម្បីផ្តល់ជាតុចូលបច្ចេកទេសដែលពាក់ព័ន្ធ ហើយក្រុមការងារស្នូលមួយទៀតក៏ត្រូវបានបង្កើតឡើងផងដែរ ដើម្បីគ្រប់គ្រងដំណើរការរៀបចំនិងតាក់តែងសេចក្តីព្រាងផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីននេះ ក្រោមការណែនាំពីគណៈកម្មាធិការតម្រង់ទិស។ លើសពីនេះទៅទៀត

សិក្ខាសាលាពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធនានា ត្រូវបានរៀបចំឡើងដើម្បីប្រមូលមតិយោបល់និងធាតុចូលពីម្ចាស់ជំនួយនានានៅក្នុងវិស័យសកម្មភាពមីន ដៃគូអភិវឌ្ឍន៍ និងស្ថាប័នរដ្ឋាភិបាលដែលពាក់ព័ន្ធ ព្រមទាំងប្រតិបត្តិករនានា ដើម្បីធានាថា ផ.យ.ជ.ម. ២០១៨-២០២៥នេះ មានលក្ខណៈគ្រប់ជ្រុងជ្រោយ និងអាចអនុវត្តបាន។ ផ.យ.ជ.ម. ២០១៨-២០២៥នេះ ត្រូវបានបង្កើតឡើងដោយផ្អែកលើបទពិសោធន៍ជាក់ស្តែងដ៏សម្បូរបែបដែលទទួលបានពីការអនុវត្តយុទ្ធសាស្ត្រវិស័យសកម្មភាពមីនមុនៗ និងយុទ្ធសាស្ត្រនៃវិស័យពាក់ព័ន្ធនានា ព្រមទាំងរបាយការណ៍និងការពិនិត្យឡើងវិញ និងលទ្ធផលនៃការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធជាច្រើន។ ផែនការយុទ្ធសាស្ត្រនេះក៏មានតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់ជាគោលការណ៍ណែនាំជាយុទ្ធសាស្ត្រសម្រាប់ផែនការអនុវត្តដែលត្រូវរៀបចំឡើងជាបន្តបន្ទាប់ទៀត ដោយបង្ហាញអំពីវិធីសាស្ត្រដែលកម្ពុជាប្រើប្រាស់សម្រាប់ដោះស្រាយបញ្ហាមីននិងស.ផ.ស. សំដៅគាំទ្រដល់ផែនការអភិវឌ្ឍជាតិ ដើម្បីកាត់បន្ថយភាពក្រីក្រ និងពន្លឿនការអភិវឌ្ឍសេដ្ឋកិច្ចព្រមទាំងធានាសម្រេចឱ្យបាននូវកាតព្វកិច្ចអន្តរជាតិ និងត្រៀមខ្លួនក្នុងការដោះស្រាយរាល់បញ្ហាដែលនៅសេសសល់ដែលបង្កដោយមីននិងស.ផ.ស. ជាបន្តទៀតនាពេលអនាគត។

ដើម្បីធានាបាននូវការគ្រប់គ្រងវិស័យសកម្មភាពមីនប្រកបដោយប្រសិទ្ធភាព និងគណនេយ្យភាព រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតអាជ្ញាធរមីន ដោយមាន**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ជាប្រធាន។ អាជ្ញាធរមីនមានតួនាទីនិងភារកិច្ចធ្វើនិយ័តកម្ម សម្របសម្រួល និងតាមដានត្រួតពិនិត្យការអនុវត្តនៅក្នុងវិស័យសកម្មភាពមីននៅទូទាំងប្រទេសកម្ពុជា។ វិស័យនេះមានប្រតិបត្តិករជាតិចំនួនពីរ គឺមជ្ឈមណ្ឌលសកម្មភាពកម្ចាត់មីនកម្ពុជា(CMAC) និងមជ្ឈមណ្ឌលជាតិសម្រាប់ការគ្រប់គ្រងកងកម្លាំងរក្សាសន្តិសុខ បោសសម្អាតមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម (NPMEC) និងប្រតិបត្តិករអន្តរជាតិ រួមមានអង្គការ MAG អង្គការ HALO Trust អង្គការ JMAS អង្គការ NPA និងអង្គការ APOPO ព្រមទាំងមានអង្គការដោះមីន CSHD ដែលជាប្រតិបត្តិករក្នុងនាមអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយ ហើយក៏មានស្ថាប័នជាច្រើនទៀតដែលផ្តល់ការអប់រំអំពីហានិភ័យដោយសារមីននិងជំនួយគាំទ្រដល់ជនរងគ្រោះដោយសារមីន។ លើសពីនេះទៀតកម្ពុជាបានបញ្ជូនអ្នកជំនាញដោះមីនរបស់ខ្លួន ទៅបំពេញបេសកកម្មនៅតាមបណ្តាប្រទេសដែលរងគ្រោះដោយសារមីន ដែលជាផ្នែកមួយនៃប្រតិបត្តិការរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ ហើយក៏បានចូលរួមចំណែកក្នុងការជួយដល់បណ្តាប្រទេសផ្សេងៗទៀត ដែលបានរងគ្រោះដោយសារមីននិងស.ផ.ស.ផងដែរ។

កម្ពុជាបានកំណត់សកម្មភាពមីនជាគោលដៅមួយ ក្នុងចំណោមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (CSDGs) របស់ខ្លួន ពោលគឺគោលដៅទី១៨ (CSDG 18)។ លើសពីនេះទៅទៀត ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៤-២០១៨ បានគូសបញ្ជាក់ថា ការធ្វើផែនការនិងការចាត់អាទិភាពប្រកបដោយប្រសិទ្ធភាពនៃការបោសសម្អាតមីន មានសារៈសំខាន់ណាស់សម្រាប់ធានាដល់ការប្រើប្រាស់ធនធានដែលមានកម្រិតប្រកបដោយប្រសិទ្ធផល និងការកាត់បន្ថយគ្រោះថ្នាក់ដោយសារមីន។ ប្រការនេះបានជំរុញលើកទឹកចិត្តឱ្យអាជ្ញាធរមីនបន្តធ្វើការកែលម្អដំណើរការធ្វើផែនការនិងការចាត់អាទិភាពនាពេលបច្ចុប្បន្ន ដែលត្រូវបានបញ្ចូលទៅក្នុងកម្មវិធីវិនិយោគឃុំសង្កាត់។ អាជ្ញាធរមីនក៏នឹងធានាឱ្យមានការពិគ្រោះយោបល់យ៉ាងជិតស្និទ្ធរវាងវិស័យសកម្មភាពមីន និងវិស័យពាក់ព័ន្ធផ្សេងទៀតនៅគ្រប់កម្រិតទាំងអស់ ដើម្បីបង្កើតឱ្យមានភាពប្រទាក់ក្រឡាជាវិជ្ជមាន និងកិច្ចសហការរវាងវិស័យផ្សេងៗ។ ទន្ទឹមនឹងនេះ អាជ្ញាធរមីននឹងបន្តកែលម្អការអនុវត្តវិធីសាស្ត្ររំដោះផ្ទៃដីចម្ការមីន ដើម្បីរំដោះដីដែលមានមីនប្រកបដោយប្រសិទ្ធភាពខ្ពស់។

ដើម្បីបំពេញតម្រូវការនៃការបោសសម្អាតមីនប្រកបដោយគុណភាព និងធានាថាដីដែលត្រូវបានរំដោះហើយមានសុវត្ថិភាពសម្រាប់ការប្រើប្រាស់ ប្រតិបត្តិការបោសសម្អាតមីនត្រូវបានធ្វើឡើងដោយផ្អែកលើយន្តការសំខាន់ៗមួយចំនួន ដូចជាដំណើរការរៀបចំផែនការនិងការចាត់អាទិភាពប្រកបដោយប្រសិទ្ធភាព ទាំងតាមវិធីសាស្ត្រ «ពីលើចុះក្រោម» និងតាមវិធីសាស្ត្រ «ពីក្រោមឡើងលើ» ការសម្របសម្រួលប្រកបដោយប្រសិទ្ធភាពក្នុងចំណោមភាគីពាក់ព័ន្ធទាំងអស់ ការគ្រប់គ្រងប្រព័ន្ធគ្រប់គ្រងព័ត៌មានសម្រាប់សកម្មភាពបោសសម្អាតមីន និងប្រព័ន្ធគ្រប់គ្រងគុណភាពប្រកបដោយប្រសិទ្ធភាព ដើម្បីធានាបាននូវទំនុកចិត្តពីបណ្ដាភាគីពាក់ព័ន្ធទាំងអស់។

ការគ្រប់គ្រងសកម្មភាពមីននាពេលបច្ចុប្បន្ននេះ នៅតែបង្ហាញអំពីប្រសិទ្ធភាពការងារ និងសបញ្ជាក់យ៉ាងច្បាស់អំពីភាពជាម្ចាស់របស់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងវិស័យសកម្មភាពមីននៅកម្ពុជា។ ទោះបីជាវិស័យនេះមានការអភិវឌ្ឍជាវិជ្ជមាន ផ្នែកមួយចំនួននៃវិស័យនេះចាំបាច់ត្រូវធ្វើការកែលម្អ តាមរយៈការប្រើប្រាស់យុទ្ធសាស្ត្រនេះ។

ចាប់តាំងពីឆ្នាំ១៩៧៩មក មីននិងស.ផ.ស.បានបង្កឱ្យមានជនរងគ្រោះកើនឡើងយ៉ាងច្រើនលើសលប់។ តាមរយៈរបាយការណ៍របស់ ប.ព.ជ.ម.ក. បានបង្ហាញថា កម្ពុជាមានអ្នកស្លាប់និងរបួសចំនួន ៦៤ ៦៦២នាក់ នៅចន្លោះឆ្នាំ១៩៧៩ និងឆ្នាំ២០១៦។ ចំនួនអ្នកស្លាប់និងរបួសបណ្ដាលមកពីមីននិងស.ផ.ស. បានថយចុះពី ៤ ៣២០នាក់នៅក្នុងឆ្នាំ១៩៩៦ មកនៅត្រឹមប្រមាណ ១០០នាក់ជាមធ្យមក្នុងមួយឆ្នាំ សម្រាប់រយៈពេល ៥ឆ្នាំចុងក្រោយនេះ។ ចំនួនគ្រោះថ្នាក់ដោយសារមីននិងស.ផ.ស. ត្រូវបានថយចុះយ៉ាងខ្លាំងដោយសារការធ្វើផែនការ និងការចាត់អាទិភាពប្រកបដោយប្រសិទ្ធភាព ការបោសសម្អាតមីននិងយុទ្ធភណ្ឌមិនទាន់ផ្ទុះទ្រង់ទ្រាយធំនៅក្នុងរយៈពេលជាង ២៥ឆ្នាំមកនេះ ការបង្កើនការយល់ដឹងអំពីមីនតាមរយៈកិច្ចខិតខំប្រឹងប្រែងអប់រំកាត់បន្ថយគ្រោះថ្នាក់មីននិងស.ផ.ស. ការលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងការអនុវត្តច្បាប់ស្ដីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវ។

នៅត្រឹមដំណាច់ឆ្នាំ២០១៦ ប្រទេសកម្ពុជាបានរំដោះដីដែលមានមីនទំហំ **១ ៥៤៤ ៩៥៨ ៥២៣ម៉ែត្រការ៉េ** សម្រាប់ប្រើប្រាស់ជាដីកសិកម្ម និងបានរកឃើញនិងបំផ្លាញចោលនូវមីនប្រឆាំងមនុស្សចំនួន **១ ០៣៦ ៣៧៦គ្រាប់** និងមីនប្រឆាំងរថក្រោះចំនួន **២៤ ២៥១គ្រាប់** ព្រមទាំងសំណល់ជាតិផ្ទុះក្រោយសង្គ្រាមចំនួន **២ ៦៦០ ៦៣៨គ្រាប់** ផ្សេងទៀត។

សមិទ្ធផលទាំងនេះអាចសម្រេចបានគួរជាទីមោទនៈ ក៏ដោយសារមានការចូលរួមចំណែកដ៏សំខាន់របស់សហគមន៍អន្តរជាតិនិងរាជរដ្ឋាភិបាលកម្ពុជា។ ទោះជាយ៉ាងណា ជំនួយថវិកាពីសហគមន៍អន្តរជាតិសម្រាប់ការងារបោសសម្អាតមីនបានបន្តធ្លាក់ចុះបន្តិចម្ដងៗ។ ដូច្នេះ វិស័យនេះត្រូវតែពង្រឹងកម្លាំងឡើងវិញ និងត្រូវពង្រីកការស្វែងរកការគាំទ្រថវិកាទាំងនៅក្នុងប្រទេសនិងក្រៅប្រទេស ដើម្បីឈានទៅសម្រេចឱ្យបាននូវគោលបំណងនៃយុទ្ធសាស្ត្រនេះ។ គោលបំណងចម្បងរបស់រាជរដ្ឋាភិបាលកម្ពុជា គឺការប្រែក្លាយកម្ពុជាឱ្យទៅជាប្រទេសដែលគ្មានមីននៅឆ្នាំ២០២៥ ហើយដើម្បីសម្រេចគោលបំណងនេះ កម្ពុជាត្រូវការអ្នកដោះមីនចំនួនប្រមាណ ១ ០០០នាក់បន្ថែមទៀត។

*រូបភាពទី១៖* ផែនទីបង្ហាញអំពីទីតាំងគ្រោះថ្នាក់ដោយសារមីននៅកម្ពុជា ចាប់ពីឆ្នាំ១៩៩៧ ដល់ឆ្នាំ២០១៦



## ២. ចក្ខុវិស័យ

ចក្ខុវិស័យរបស់រាជរដ្ឋាភិបាល គឺប្រទេសកម្ពុជាដែលគ្មានមីន ហើយការគំរាមកំហែងពីស.ផ.ស. ត្រូវបានកាត់បន្ថយឱ្យនៅកម្រិតអប្បបរមា ហើយការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងការអភិវឌ្ឍមនុស្សប្រព្រឹត្តទៅប្រកបដោយសុវត្ថិភាព។

## ៣. បេសកកម្ម

បេសកកម្មរបស់រាជរដ្ឋាភិបាល គឺធ្វើការរំដោះផ្ទៃដីដែលដឹងថាមានមីនទាំងអស់ និងគ្រាប់បែកចង្កោមជាអាទិភាព ហើយកាត់បន្ថយឱ្យនៅកម្រិតអប្បបរមារាល់ហានិភ័យដែលបណ្តាលមកពីស.ផ.ស.ផ្សេងទៀតនៅកម្ពុជា និងស្វែងរកការគាំទ្រមតិលើសិទ្ធិ និងផ្តល់សេវាសម្រាប់អ្នករស់រានមានជីវិតពីការគ្រោះថ្នាក់ដោយសារមីននិង ស.ផ.ស. ក៏ដូចជាជនរងគ្រោះដោយប្រយោល។

គោលការណ៍ណែនាំ និងគុណតម្លៃ មានដូចខាងក្រោម៖

- ការឆ្លើយតបនឹងតម្រូវការ និងយកកត្តាមនុស្សជាស្នូល
- រាល់សកម្មភាពមីនត្រូវស្របតាមស្តង់ដារគុណភាពខ្ពស់និងសុវត្ថិភាពខ្ពស់
- រាល់សកម្មភាពមីនត្រូវមានប្រសិទ្ធភាព ប្រសិទ្ធផល និងមានលក្ខណៈសន្សំសំចៃបំផុត
- ការគ្រប់គ្រងព័ត៌មានស្តីពីសកម្មភាពមីន ត្រូវឈរលើគោលការណ៍សុចរិត ត្រឹមត្រូវ និងងាយស្រួលប្រើប្រាស់បាន
- រាល់ក្រសួងស្ថាប័នដែលពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ត្រូវមានភាពម្ចាស់ការលើផែនការយុទ្ធសាស្ត្រនេះ និងព្រមទាំងផែនការសកម្មភាព
- ការធ្វើសេចក្តីសម្រេចចិត្ត និងការគ្រប់គ្រងហិរញ្ញវត្ថុ ត្រូវមានតម្លាភាព និងគណនេយ្យភាព
- ភាពយុត្តិធម៌ និងសមធម៌ ត្រូវរក្សាឱ្យបានខ្ជាប់ខ្ជួននៅគ្រប់ពេលវេលា
- ភាពចម្រុះនៃយេនឌ័រ ត្រូវទទួលបានការគោរពឱ្យតម្លៃនៅគ្រប់ពេលវេលា
- ការកែលម្អជាប្រចាំ និងការច្នៃប្រឌិតថ្មីត្រូវបានលើកទឹកចិត្ត
- វិធីសាស្ត្រពិគ្រោះយោបល់ និងដោយមានការចូលរួម ត្រូវបានអនុវត្ត ជាពិសេសសម្រាប់អ្នកប្រើប្រាស់ចុងក្រោយ
- ឱកាសសម្រាប់អ្នករស់រានមានជីវិត ត្រូវមានអាទិភាពខ្ពស់។

# ៤. គោលបំណង និងគោលដៅ

**គោលបំណងទី១៖ រំដោះផ្ទៃដីដែលដឹងថាមានមីនឱ្យអស់នៅត្រឹមឆ្នាំ២០២៥**

**គោលដៅ៖**

១. បញ្ចប់ការស្រាវជ្រាវចម្ការមីនមូលដ្ឋានថ្នាក់ជាតិ សម្រាប់បណ្តាស្រុកដែលនៅសេសសល់ទាំងអស់ត្រឹមឆ្នាំ២០២០។

២. អនុវត្តការរំដោះផ្ទៃដីតាមរយៈការស្រាវជ្រាវមិនបច្ចេកទេសលើដីត្រូវបានទន្ទ្រានយកមកប្រើប្រាស់ និងលុបចោលតំបន់សង្ស័យនិងធ្វើការស្រាវជ្រាវឡើងវិញដើម្បីធ្វើបច្ចុប្បន្នភាពទិន្នន័យផ្ទៃដីដែលមានមីន។

៣. រំដោះភូមិអាទិភាពដែលដឹងថាមានមីនទាំងអស់ត្រឹមឆ្នាំ២០២១ និងភូមិនៅសេសសល់ផ្សេងៗទៀតនៅត្រឹមឆ្នាំ២០២៥។

៤. ពិនិត្យឡើងវិញនិងកែលម្អប្រព័ន្ធប្រតិបត្តិការ និងសមត្ថភាពដែលមានស្រាប់។

**គោលបំណងទី២៖ រំដោះផ្ទៃដីដែលដឹងថាមានគ្រាប់បែកចង្កោមជាអាទិភាពនៅត្រឹមឆ្នាំ២០២៥**

**គោលដៅ៖**

១. រៀបចំផែនការនិងចាត់អាទិភាពតំបន់ដែលមានគ្រាប់បែកចង្កោម។

២. ធ្វើការស្រាវជ្រាវនិងរំដោះផ្ទៃដីដែលដឹងថាមានគ្រាប់បែកចង្កោម។

**គោលបំណងទី៣៖ ដោះស្រាយបញ្ហាគំរាមកំហែងបណ្តាលមកពីស.ផ.ស.ផ្សេងទៀត**

**គោលដៅ៖**

១. ស្រាវជ្រាវ និងរំដោះផ្ទៃដីដែលដឹងថាមានស.ផ.ស.។

២. ផ្តល់ការឆ្លើយតបទាន់ពេលវេលានៅពេលមានសំណើសុំជំនួយអន្តរាគមន៍ផ្នែកប្រតិបត្តិការកំទេចគ្រឿងផ្ទុះពីសំណាក់សហគមន៍និងអាជ្ញាធរ។

**គោលបំណងទី៤៖ កាត់បន្ថយចំនួនគ្រោះថ្នាក់ដោយសារមីន និងស.ផ.ស.ផ្សេងទៀត ឱ្យនៅកម្រិតអប្បបរមា ព្រមទាំងលើកកម្ពស់ជីវភាពរស់នៅរបស់អ្នករស់រានមានជីវិត និងសហគមន៍ដែលរងផលប៉ះពាល់ដោយសារគ្រាប់មីន និងស.ផ.ស.**

**គោលដៅ៖**

១. ផ្តល់ការអប់រំកាត់បន្ថយគ្រោះថ្នាក់មីននិងស.ផ.ស. ប្រកបដោយប្រសិទ្ធភាពដល់ប្រជាជននៅតាមតំបន់ដែលមានហានិភ័យនាពេលបច្ចុប្បន្ន និងតំបន់ដែលមានហានិភ័យកើតឡើងថ្មី ឱ្យបានសមស្របទៅតាមយេនឌ័រ និងអាយុ និងពង្រឹងការផ្តួចផ្តើមបណ្តាញមូលដ្ឋាន។

២. ផ្តល់ការគាំទ្រដល់ជនរងគ្រោះដោយសារមីននិងស.ផ.ស. និងជនរងគ្រោះដោយប្រយោល ឱ្យទទួលបាននូវសេវាថែទាំសុខភាព និងផ្លូវចិត្តគ្រប់គ្រាន់ និងសមស្របទៅតាមយេនឌ័រ ព្រមទាំងការស្តារលទ្ធភាពពលកម្មកាយសម្បទាផងដែរ។
៣. លើកកម្ពស់សមត្ថភាពប្រកបរបរចិញ្ចឹមជីវិត សម្រាប់អ្នករស់រានមានជីវិតដោយសារគ្រោះថ្នាក់ពីមីននិង ស.ផ.ស. ព្រមទាំងជនរងគ្រោះដោយប្រយោល ដើម្បីលើកកម្ពស់ការចូលរួមពេញលេញនៅក្នុងសង្គម។

**គោលបំណងទី៥៖ រួមចំណែកដល់កំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ**

**គោលដៅ៖**

១. គាំទ្រដល់អាទិភាពនៃការអភិវឌ្ឍមូលដ្ឋាននៅក្នុងសហគមន៍ដែលរងផលប៉ះពាល់ពីមីនគ្រាប់បែកចង្កោម និងស.ផ.ស.ផ្សេងទៀត។
២. គាំទ្រដល់អាទិភាពនៃការអភិវឌ្ឍនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

**គោលបំណងទី៦៖ ជំរុញនិសព្វវុធការនិងកិច្ចសហប្រតិបត្តិការនៅក្នុងតំបន់និងអន្តរជាតិក្នុងសកម្មភាពមីន**

**គោលដៅ៖**

១. ជំរុញការអនុវត្តកាតព្វកិច្ចនៃអ.ហ.ផ.ម.។
២. ជំរុញការអនុវត្តកាតព្វកិច្ចនៃអនុសញ្ញាសព្វាវុធធម្មតាមួយចំនួន និងគាំទ្រដល់វឌ្ឍនភាពឆ្ពោះទៅរកការចូលរួមក្នុងពិធីសារទី៥។
៣. គាំទ្រការចូលរួមជារដ្ឋភាគីនៃអនុសញ្ញាស្តីពីគ្រាប់បែកចង្កោមត្រឹមឆ្នាំ២០២០។
៤. គាំទ្រប្រតិបត្តិការបោសសម្អាតមីនក្នុងក្របខ័ណ្ឌនៃប្រតិបត្តិការរក្សាសន្តិសុខនៃអង្គការសហប្រជាជាតិ។
៥. លើកកម្ពស់កិច្ចសហប្រតិបត្តិការ និងជំនួយអន្តរជាតិក្នុងសកម្មភាពមីនរួមមានកិច្ចសហប្រតិបត្តិការត្បូង-ត្បូង។

**គោលបំណងទី៧៖ បង្កើតសមត្ថភាពជាតិប្រកបដោយនិរន្តរភាព ដើម្បីដោះស្រាយបញ្ហាគំរាមកំហែងដែលនៅសេសសល់ក្រោយឆ្នាំ២០២៥**

**គោលដៅ៖**

១. ពង្រឹងសមត្ថភាពជាតិដើម្បីគ្រប់គ្រងនិងអនុវត្តកម្មវិធីសកម្មភាពមីនឱ្យមានប្រសិទ្ធភាពនិងប្រសិទ្ធផល។
២. ថែរក្សា កែលម្អ និងចែករំលែកចំណេះដឹងអំពីសកម្មភាពមីន នៅក្នុងវិស័យនេះនិងដល់វិស័យផ្សេងៗទៀត។
៣. ធ្វើការពិនិត្យឡើងវិញនៅត្រឹមឆ្នាំ២០២០ ទៅលើក្របខ័ណ្ឌច្បាប់ ស្ថាប័ន និងប្រតិបត្តិការ ព្រមទាំងយុទ្ធសាស្ត្រ និងសមត្ថភាព ដែលត្រូវការចាំបាច់សម្រាប់ដោះស្រាយរាល់បញ្ហាគំរាមកំហែងដែលនៅសេសសល់។
៤. កសាង ពង្រឹង និងថែរក្សាសមត្ថភាពជាតិប្រកបដោយនិរន្តរភាព ដើម្បីដោះស្រាយប្រកបដោយប្រសិទ្ធភាពរាល់បញ្ហាគំរាមកំហែងដែលនៅសេសសល់ក្រោយឆ្នាំ២០២៥។

គោលបំណងទី៨៖ ធានាថាសកម្មភាពមីនត្រូវបានគាំទ្រដោយប្រព័ន្ធគ្រប់គ្រងគុណភាពដែលមានភាពល្អប្រសើ ការគ្រប់គ្រងព័ត៌មានដែលមានប្រសិទ្ធភាព ប្រកបដោយការយកចិត្តទុកដាក់ខ្ពស់អំពីយេនឌ័រ និងការការពារបរិស្ថាន

គោលដៅ៖

១. ពង្រឹងប្រព័ន្ធគ្រប់គ្រងគុណភាព។
២. ពង្រឹងប្រព័ន្ធគ្រប់គ្រងព័ត៌មានថ្នាក់ជាតិសម្រាប់សកម្មភាពមីន។
៣. ជំរុញការបញ្ជ្រាបយេនឌ័រនៅក្នុងសកម្មភាពមីន។
៤. ធ្វើការបញ្ជ្រាបការការពារបរិស្ថានក្នុងសកម្មភាពមីន។
៥. អនុវត្តប្រព័ន្ធត្រួតពិនិត្យសកម្មភាពមីន។

# ៥. ក្របខណ្ឌយុទ្ធសាស្ត្រ

## ៥.១ ការវិភាគជាយុទ្ធសាស្ត្រ

លក្ខណៈទូទៅនៃបញ្ហាមីននិងស.ផ.ស.នៅតែមានភាពស្មុគស្មាញ។ ទោះបីជាមានវិធីសាស្ត្រស្រាវជ្រាវប្រកបដោយប្រសិទ្ធភាពបំផុតក៏ដោយ នៅតែមានទីតាំងមីននិងស.ផ.ស. ដែលស្ថិតនៅក្រៅពហុកោណនៃការស្រាវជ្រាវចម្ការមីនមូលដ្ឋាន។ ដោយឈរលើហេតុផលនេះ ទើបចាំបាច់ត្រូវមានការស្រាវជ្រាវកាន់តែហ្មត់ចត់ ដើម្បីអាចក្តាប់បានព័ត៌មានបានកាន់តែច្បាស់ ដែលព័ត៌មានទាំងនេះមិនធ្លាប់ទទួលបានពីមុនមក ដោយសារតែកង្វះព័ត៌មាននៅថ្នាក់មូលដ្ឋាននៅពេលចុះស្រាវជ្រាវ។ ទន្ទឹមនឹងនេះ ការស្រាវជ្រាវនេះគឺដើម្បីធ្វើការរំដោះផ្ទៃដីដែលបានទន្ទ្រានយកមកប្រើប្រាស់រួចហើយដោយសហគមន៍ ដែលនៅទីតាំងទាំងនោះ ការងារបោសសម្អាតមីនពុំសូវមានសកម្មភាពនោះទេ។

បន្ទាប់ពីការរៀបចំផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន ២០១៨-២០២៥នេះ រួចរាល់ជាស្ថាពរ ផែនការសកម្មភាពសម្រាប់អនុវត្តរយៈពេល ៣ឆ្នាំ នឹងត្រូវបានកសាងឡើងក្រោមកិច្ចសម្របសម្រួលពីអាជ្ញាធរមីន ដោយមានការចូលរួមពីគ្រប់ប្រតិបត្តិករ។ គោលដៅបោសសម្អាតប្រចាំឆ្នាំទៅតាមចំណាត់ថ្នាក់ប្រភេទដីនឹងត្រូវបានលើកយកមកពិភាក្សាដើម្បីស្វែងរកការឯកភាពគ្នា និងដាក់បញ្ចូលទៅក្នុងម៉ាទ្រីសសូចនាករនៃការអនុវត្ត (ឧបសម្ព័ន្ធ គ) និងគោលបំណងនានា ដូចមានក្នុងការព្យាករអំពីការរំដោះផ្ទៃដី ២០១៨-២០២៥ (ឧបសម្ព័ន្ធ ខ)។

កម្ពុជាមានសុទិដ្ឋិនិយមខ្ពស់ចំពោះវិស័យសកម្មភាពមីន ក៏ព្រោះតែកម្ពុជាមានសមត្ថភាពគ្រប់គ្រាន់ក្នុងការដោះមីនឱ្យអស់ពីតំបន់ដែលដឹងថាមានមីននៅត្រឹមឆ្នាំ២០២៥។ ប្រការនេះនឹងតម្រូវឱ្យមានការពង្រឹងកិច្ចខិតខំប្រឹងប្រែងសម្របសម្រួលក្នុងដំណើរការធ្វើផែនការនិងចាត់អាទិភាព ដើម្បីឱ្យការប្រើប្រាស់ធនធានបានល្អប្រសើរបំផុត តាមរយៈការកែលម្អវិធីសាស្ត្រនៃការរំដោះផ្ទៃដីចម្ការមីន ការពង្រឹងការប្រើប្រាស់ឧបករណ៍និងបច្ចេកទេសបោសសម្អាតមីន ព្រមទាំងការស្រាវជ្រាវជាបន្តបន្ទាប់។

កត្តាមួយចំនួនបានជះឥទ្ធិពលដល់ការអនុវត្តសកម្មភាពនៅក្នុងវិស័យនេះ ទៅតាមសសរស្តម្ភសកម្មភាពមីននីមួយៗ ដូចជាកាតព្វកិច្ចចំពោះសន្ធិសញ្ញាអន្តរជាតិ ព័ត៌មានគ្រោះថ្នាក់ដែលបានរាយការណ៍ របាយការណ៍ត្រួតពិនិត្យបន្ទាប់ពីការបោសសម្អាតរួច ទិន្នន័យប្រតិបត្តិការ និងសេចក្តីណែនាំរបស់រាជរដ្ឋាភិបាល។

ទី១. ក្នុងនាមជារដ្ឋភាគីនៃអនុសញ្ញាអន្តរជាតិនានា កម្ពុជាត្រូវតែរក្សាការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការបំពេញកាតព្វកិច្ចចំពោះអនុសញ្ញាទាំងនោះ និងផែនការសកម្មភាពនីមួយៗ។

ទី២. ដោយសារមានរបាយការណ៍អំពីករណីគ្រោះថ្នាក់នានា ដែលបានកើតមានឡើងនៅលើដីគ្រប់ប្រភេទដែលមានមីន ប្រតិបត្តិការបោសសម្អាតមីននាពេលអនាគតនឹងត្រូវយកចិត្តទុកដាក់ដោះស្រាយបញ្ហាសម្រាប់គ្រប់ប្រភេទដីដែលមានមីនទាំងអស់។ ទោះជាយ៉ាងណាក៏ដោយ ដោយសារតែឧប្បត្តិហេតុមីននិងស.ផ.ស. កើតមាននៅក្រៅតំបន់ដីដែលបានស្រាវជ្រាវរួចហើយ ដូចនេះ ជំរុញឱ្យមានការស្រាវជ្រាវបន្ថែមដែលមានលក្ខណៈស៊ីជម្រៅ ហើយកម្មវិធីអប់រំផ្សព្វផ្សាយកាត់បន្ថយគ្រោះថ្នាក់មីននិងស.ផ.ស. គួរតែបន្តទៅទៀត។

ទី៣. យោងតាមរបាយការណ៍បូកសរុប ស្តីពីការពិនិត្យផ្ទៃដីចម្ការមីន/ស.ផ.ស.បោសសម្អាតរួចឆ្នាំ២០១៦ ប្រមាណ៦០%នៃផ្ទៃដីដែលបានរំដោះត្រូវបានប្រើប្រាស់សម្រាប់សកម្មភាពកសិកម្ម ៣០% ប្រើប្រាស់សម្រាប់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ហើយ ៧%ទៀតសម្រាប់ការសង់លំនៅដ្ឋានរបស់សហគមន៍ដែលរងផលប៉ះពាល់។ មានតែ ៣% នៃផ្ទៃដីបានរំដោះរួចតែប៉ុណ្ណោះ ដែលមិនទាន់ត្រូវបានយកមកប្រើប្រាស់នៅឡើយ ខណៈដែលរបាយការណ៍ស្តីពីការពិនិត្យផ្ទៃដីចម្ការមីន/ស.ផ.ស.បោសសម្អាតរួចនេះត្រូវបានចេញផ្សាយ។ ប្រការនេះបង្ហាញឱ្យឃើញអំពីប្រសិទ្ធភាពនៃការអនុវត្តនៅក្នុងការធ្វើផែនការនិងការចាត់អាទិភាពនាពេលកន្លងមក។ ការធ្វើផែនការនិងការចាត់អាទិភាពនាពេលបច្ចុប្បន្ននេះ បើទោះបីជាចាត់ទុកថាមានប្រសិទ្ធភាពខ្ពស់ហើយក៏ដោយ ក៏នៅតែត្រូវបន្តពង្រឹងថែមទៀតសម្រាប់ការងារទៅខាងមុខ។

ទី៤. ស្ថិតិប្រតិបត្តិការដែលត្រូវបានធ្វើឡើងដោយអាជ្ញាធរមីន បានបង្ហាញថា ក្នុងអំឡុងពេលប្រតិបត្តិការរំដោះផ្ទៃដី ជាមធ្យម ផ្ទៃដីមួយចំនួននៃពហុកោណចម្ការមីនក្នុងចំនួនភាគរយណាមួយ ត្រូវបានរំដោះតាមរយៈការស្រាវជ្រាវមិនបច្ចេកទេស។ ឧទាហរណ៍ ជាមធ្យមមាន ៣២%នៃផ្ទៃដីពហុកោណចម្ការមីនសរុបស្ថិតក្នុងចំណាត់ថ្នាក់ប្រភេទ A1 (ដីដែលមានដង់ស៊ីតេមីនប្រឆាំងមនុស្សច្រើន) និង ៥១% នៃដីស្ថិតក្នុងចំណាត់ថ្នាក់ A4 (ដីដែលមានមីនប្រឆាំងមនុស្សនៅរាយប៉ាយមិនអាចកំណត់ទីតាំងមីនបាន) ត្រូវបានរំដោះចេញមកវិញ។ នេះមានន័យថា ពុំមានការចាំបាច់ត្រូវការពង្រាយធនធានបោសសម្អាតមីនទេ ដែលនេះគឺជាការសន្សំសំចៃធនធានយ៉ាងច្រើន ហើយការងារដោះមីនក៏មានល្បឿនលឿនជាងមុន។ វាជាការចាំបាច់ណាស់ដែលធនធានបោសសម្អាតមីន ត្រូវបានដាក់ពង្រាយតែនៅក្នុងតំបន់ណាដែលមានភស្តុតាងច្បាស់លាស់ថាមានមីនប៉ុណ្ណោះ។ ដូចនេះ ភារកិច្ចបោសសម្អាតមីននាពេលអនាគត គួរតែត្រូវបានចាត់អាទិភាពដោយផ្អែកលើមូលដ្ឋាននៃការស្រាវជ្រាវឡើងវិញដែលមានប្រសិទ្ធភាព (ការស្រាវជ្រាវមិនបច្ចេកទេស)។

ទី៥. ស្ថានភាពសេដ្ឋកិច្ច សង្គម មនុស្សធម៌ ការអភិវឌ្ឍ និងការបោះបង្គោលព្រំដែននៅកម្ពុជានៅតែមានការវិវត្តប្រែប្រួលនៅឡើយ។ ការបោសសម្អាតមីនត្រូវតែឆ្លើយតបទៅនឹងតម្រូវការទាំងនេះ ដោយប្រើប្រាស់គោលការណ៍ណែនាំសម្រាប់ការធ្វើផែនការនិងការចាត់អាទិភាព និងសារាចររបស់រាជរដ្ឋាភិបាលពាក់ព័ន្ធនឹងការបោសសម្អាតមីននៅតាមតំបន់ព្រំដែន។

ជាមួយនឹងវិធីសាស្ត្រដែលកាន់តែមានលក្ខណៈជាប្រព័ន្ធ និងការស្រាវជ្រាវចម្ការមីនមូលដ្ឋានដែលកាន់តែច្បាស់លាស់ជាងមុន រួមទាំងការរំដោះដីដែលកំពុងអនុវត្ត (តាមរយៈការស្រាវជ្រាវមិនបច្ចេកទេស ការស្រាវជ្រាវបច្ចេកទេស និងការបោសសម្អាតពេញលេញ) ដីដែលមានមីននិងស.ផ.ស. ប្រមាណ ១ ៩៧០គីឡូម៉ែត្រការ៉េ រំពឹងថានឹងត្រូវបានរំដោះ។ ដើម្បីឆ្លើយតបជាយុទ្ធសាស្ត្រចំពោះបញ្ហានីមួយៗ បញ្ហាមីនត្រូវបានបែងចែកជាបីប្រភេទដាច់ដោយឡែកពីគ្នាគឺៈ មីន គ្រាប់បែកចង្កោម និងស.ផ.ស.ផ្សេងទៀត។ ចំណែកការដោះស្រាយបញ្ហាគ្រាប់បែកគឺមីនឹងត្រូវឆ្លើយតបក្នុងយុទ្ធសាស្ត្រមួយដោយឡែក។

## ១. មីនៈ

ផ្ទៃដីដែលដឹងថាមានមីននៅសេសសល់ត្រូវរំដោះ មានចំនួនសរុបប្រមាណ ៩៤៦គីឡូម៉ែត្រការ៉េ។ ក្នុងរយៈពេលបីឆ្នាំចុងក្រោយនេះ(២០១៤-២០១៦) កម្ពុជាបានរំដោះផ្ទៃដីដែលមានមីនជាមធ្យម ៩៤គីឡូម៉ែត្រការ៉េក្នុងមួយឆ្នាំ។ តាមអត្រានេះ កម្ពុជាត្រូវចំណាយពេលប្រហែល ១០ឆ្នាំ ដើម្បីរំដោះដីដែលដឹងថាមានមីនទាំងអស់។ ទោះបីជាបែបនេះក្តី អនុលោមតាមសេចក្តីថ្លែងការណ៍ម៉ាពុយតូ+១៥ កម្ពុជាបានប្តេជ្ញាចិត្តថានឹងធ្វើការបោសសម្អាតតំបន់ដែលដឹងថាមានមីនទាំងអស់នៅត្រឹមឆ្នាំ២០២៥។ ដើម្បីឆ្លើយតបនឹងការប្តេជ្ញាចិត្តនេះឱ្យបាននៅក្នុងរយៈពេល ៨ឆ្នាំនោះ កម្ពុជានឹងត្រូវបង្កើនផលិតភាពនៃការរំដោះដីមានមីនឱ្យបាន១៧% មានន័យថា ត្រូវរំដោះផ្ទៃដីទំហំ ១១០គីឡូម៉ែត្រការ៉េក្នុងមួយឆ្នាំ។

ការវិភាគទៅលើទិន្នន័យរយៈពេល ៣ឆ្នាំកន្លងមក ដែលបានមកពីមូលដ្ឋានទិន្នន័យជាតិរបស់អាជ្ញាធរមីនបង្ហាញថា ក្នុងចំណោមតំបន់ដែលមានមីនៈ

ក- ៤០% ត្រូវបានរំដោះតាមរយៈការស្រាវជ្រាវមិនបច្ចេកទេស និងបានកំណត់ថាជាដីទន្ទ្រានយកមកប្រើប្រាស់និងលុបចោលជាតំបន់សង្ស័យ

ខ- ៦០% ត្រូវបានរំដោះតាមរយៈការស្រាវជ្រាវបច្ចេកទេសនិងបោសសម្អាតទាំងស្រុង។

ដើម្បីបង្កើនផលិតភាពឆ្ពោះទៅសម្រេចទិសដៅដែលបានកំណត់ កម្ពុជានឹងពន្លឿនដំណើរការនេះ ដោយធ្វើការកែលម្អវិធីសាស្ត្រប្រើប្រាស់សម្រាប់ការរំដោះផ្ទីដី បច្ចេកវិទ្យាថ្មៃប្រឌិតថ្មីៗ និងប្រព័ន្ធរាវរកដោយប្រើសត្វសម្រាប់ការរំដោះផ្ទៃដីប្រកបដោយប្រសិទ្ធភាពនិងប្រសិទ្ធផល។ ប្រព័ន្ធគ្រប់គ្រងគុណភាពដ៏រឹងមាំមួយក៏ត្រូវបានរក្សានិងពង្រឹងផងដែរ ដើម្បីឱ្យអ្នកទទួលផល ប្រតិបត្តិករ និងអាជ្ញាធរមីនមានទំនុកចិត្តថា លក្ខខណ្ឌតម្រូវនៃគុណភាពនិងការបោសសម្អាតត្រូវបានបំពេញ ហើយផ្ទៃដីដែលបានរំដោះនោះពិតជាមានសុវត្ថិភាពសម្រាប់ការប្រើប្រាស់។ ដូចនេះ កត្តានេះតម្រូវឱ្យមានធនធានហិរញ្ញវត្ថុ សម្ភារបរិក្ខារ និងធនធានមនុស្សដែលមានសមត្ថភាពបន្ថែមទៀត។

## ២. គ្រាប់បែកចង្កោមៈ

ក្រៅពីការប្តេជ្ញាចិត្តចំពោះការរំដោះផ្ទៃដីដែលដឹងថាមានមីនទាំងអស់នៅត្រឹមឆ្នាំ២០២៥ កម្ពុជានឹងបន្តដោះស្រាយបញ្ហាគ្រាប់បែកចង្កោមដែលនៅសេសសល់និងស.ផ.ស.ផ្សេងៗទៀត។ ផ្ទៃដីសរុបដែលមានគ្រាប់បែកចង្កោមត្រូវធ្វើការរំដោះមានទំហំ ៦៤៥គីឡូម៉ែត្រការ៉េ ហើយអាចនឹងកើនឡើង បន្ទាប់ពីការបញ្ចប់ការស្រាវជ្រាវ។

ក្នុងរយៈពេលបីឆ្នាំចុងក្រោយនេះ (២០១៤-២០១៦) កម្ពុជាបានរំដោះផ្ទៃដីជាមធ្យម ១១គីឡូម៉ែត្រការ៉េក្នុងមួយឆ្នាំ។ ផ្អែកតាមសកម្មភាពអភិវឌ្ឍន៍និងយោបល់របស់អ្នកជំនាញ កម្ពុជាបានចាត់អាទិភាពនិងប្តេជ្ញាចិត្តក្នុងការដោះស្រាយបញ្ហានេះឱ្យបាន៨០% នៃផ្ទៃដីដែលមានគ្រាប់បែកចង្កោម ឬស្មើនឹង ៤៩៩គីឡូម៉ែត្រការ៉េ នៅត្រឹមឆ្នាំ២០២៥។ អ្វីដែលមិនទាន់បានដោះស្រាយ នឹងត្រូវចាត់ទុកជាការគំរាមគំហែងដែលនៅសេសសល់។

ដើម្បីអាចសម្រេចបានគោលបំណងក្នុងការរំដោះដីឱ្យបាន ៤៩៩គីឡូម៉ែត្រការ៉េនៃដីដែលមានគ្រាប់បែកចង្កោមជាអាទិភាពនៅក្នុងរយៈពេល ៨ឆ្នាំ វិស័យនេះនឹងត្រូវពន្លឿនដំណើរការ តាមរយៈការប្រើប្រាស់វិធីសាស្ត្រដែលត្រូវបានកែលម្អរួច ដូចជាការស្រាវជ្រាវគ្រាប់បែកចង្កោមតាមរយៈការរួមបញ្ចូលគ្នានូវវិធីសាស្ត្រស្រាវជ្រាវមិន

បច្ចេកទេសនិងវិធីសាស្ត្រស្រាវជ្រាវបច្ចេកទេស ដើម្បីកំណត់ឱ្យបានច្បាស់លាស់នូវតំបន់ដែលមានគ្រោះថ្នាក់ បច្ចេកវិទ្យាថ្មីប្រឌិតថ្មី និងប្រព័ន្ធរាវគ្រាប់ដោយប្រើសត្វសម្រាប់ការរំដោះផ្ទៃដីប្រកបដោយប្រសិទ្ធភាពនិងប្រសិទ្ធផល។

កម្ពុជាមានទំនុកចិត្តថា ខ្លួនអាចរំដោះដីបានប្រមាណ៣០% តាមរយៈការស្រាវជ្រាវមិនបច្ចេកទេស ដើម្បីកំណត់ដីដែលត្រូវបានទន្ទ្រានយកមកប្រើប្រាស់និងលុបចោលដីសង្ស័យនិង ៧០% ទៀតដែលនៅសេសសល់តាមរយៈវិធីសាស្ត្រកាត់បន្ថយផ្ទៃដី។ ផ្អែកលើការវិភាគនេះ ដីប្រមាណ ៤៤គីឡូម៉ែត្រការ៉េនឹងត្រូវបានរំដោះក្នុងមួយឆ្នាំ ដោយប្រើប្រាស់ការស្រាវជ្រាវបច្ចេកទេស និងការបោសសម្អាតពេញលេញ។ ដូចនេះ តម្រូវឱ្យមានធនធានបន្ថែម ទាំងផ្នែកហិរញ្ញវត្ថុ ឧបករណ៍សម្ភារ និងសមត្ថភាពធនធានមនុស្ស។

## ៣. សំណល់ជាតិផ្ទុះពីសង្គ្រាម(ស.ផ.ស.) ផ្សេងទៀត

ដោយសារការស្រាវជ្រាវស.ផ.ស.នៅមានកម្រិតនៅឡើយ ផ្ទៃដីដែលដឹងថាមានស.ផ.ស.ផ្សេងទៀត មានទំហំ ៣៧៩គីឡូម៉ែត្រការ៉េ ហើយត្រូវបានព្យាករថានៅត្រឹមដំណាច់ឆ្នាំ២០១៧ ផ្ទៃដីដែលនៅសេសសល់មានទំហំ ៣៣៣គីឡូម៉ែត្រការ៉េ។ ទោះជាយ៉ាងណាក៏ដោយ ស.ផ.ស.ស្ថិតនៅរាយប៉ាយនៅគ្រប់តំបន់ទូទាំងប្រទេស ដែលបង្កជាការលំបាកក្នុងការកំណត់តំបន់រងផលប៉ះពាល់ ដែលតម្រូវឱ្យមានការស្រាវជ្រាវបន្ថែមមួយមានលក្ខណៈស៊ីជម្រៅ។

យោងតាមស្ថិតិក្នុងមូលដ្ឋានទិន្នន័យជាតិ ផ្អែកលើមធ្យមភាគប្រចាំឆ្នាំក្នុងរយៈពេល ៣ឆ្នាំ ពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៦ ផ្ទៃដីប្រមាណ ៤៦គីឡូម៉ែត្រការ៉េនៃដីដែលមានសំណល់ជាតិផ្ទុះក្រោយសង្គ្រាម ត្រូវបានរំដោះក្នុងមួយឆ្នាំៗ។ ដូចនេះ ក្នុងមួយឆ្នាំ កម្ពុជាត្រូវធ្វើការរំដោះផ្ទៃដីឱ្យបាន ៤២គីឡូម៉ែត្រការ៉េ ទើបអាចឈានដល់ទិសដៅនៃការបោសសម្អាតសំណល់ជាតិផ្ទុះក្រោយសង្គ្រាម ១០០% នៅត្រឹមឆ្នាំ២០២៥។ តាមរបាយការណ៍របស់ប្រតិបត្តិករនានា បានឱ្យដឹងថា ក្នុងរយៈពេល ៣ឆ្នាំចុងក្រោយនេះ ការងារអន្តរាគមន៍ប្រតិបត្តិការកំទេចគ្រឿងផ្ទុះ មានចំនួនសរុប ២១ ២១២លើក ដោយជាមធ្យមមានចំនួន ៧ ០៧១ លើកក្នុងមួយឆ្នាំ។ ដោយសារតែកំណើនប្រជាជននិងល្បឿននៃសកម្មភាពអភិវឌ្ឍន៍ ចំនួនប្រតិបត្តិការនេះត្រូវបានរំពឹងថានឹងមានការកើនឡើងនាពេលអនាគតដ៏ខ្លីខាងមុខ។

ការបោសសម្អាតស.ផ.ស.តម្រូវឱ្យមានការខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្លា ដោយហេតុថាស.ផ.ស.មាននៅរាយប៉ាយនៅគ្រប់តំបន់ទូទាំងប្រទេស។ បទពិសោធន៍ជាសកលបង្ហាញថា ការគំរាមកំហែងពីស.ផ.ស.ដែលនៅសេសសល់នឹងត្រូវដោះស្រាយយូរអង្វែងបន្តទៀត បន្ទាប់ពីអន្តរាគមន៍ដំបូងត្រូវបានបញ្ចប់។ ក្នុងន័យនេះ កម្ពុជាត្រូវពង្រឹងសមត្ថភាពថ្នាក់ជាតិលើផ្នែកប្រតិបត្តិការកំទេចគ្រឿងផ្ទុះប្រកបដោយនិរន្តរភាព ដើម្បីឆ្លើយតបជាប្រចាំចំពោះហានិភ័យដែលនៅសេសសល់ ។

## ៥.២ យុទ្ធសាស្ត្រ

ការដោះស្រាយបញ្ហាមីននិងស.ផ.ស. មិនមែនត្រឹមតែជាការបោសសម្អាតមីននិងស.ផ.ស.ប៉ុណ្ណោះទេ ប៉ុន្តែត្រូវមានសកម្មភាពជាច្រើនទៀតដែលវិស័យនេះត្រូវអនុវត្ត ទាំងតាមរយៈសកម្មភាពបង្ការទុកជាមុន និងតាមរយៈសកម្មភាពប្រត្តិកម្មតប ដូចជាការផ្តល់ការអប់រំកាត់បន្ថយគ្រោះថ្នាក់មីននិងស.ផ.ស. ការផ្តល់ជំនួយគាំទ្រដល់ជនរងគ្រោះដោយសារមីននិងស.ផ.ស. ការតស៊ូមតិនិងការបំផ្លាញការស្តុកទុក ការបញ្ជ្រាបបញ្ហាយេនឌ័រនៅក្នុងសកម្មភាពមីន ការបង្ការការពារបរិស្ថានឱ្យរួចផុតពីផលប៉ះពាល់ជាអវិជ្ជមានដោយការបោសសម្អាតនិងបំផ្លាញមីន ការស្រាវជ្រាវនិងការអភិវឌ្ឍវិធីសាស្ត្រនិងបច្ចេកវិទ្យាប្រកបដោយភាពច្នៃប្រឌិតថ្មីៗ និងការគ្រប់គ្រងវិស័យនេះប្រកបដោយប្រសិទ្ធភាពជាដើម។ វិស័យនេះក៏ត្រូវផ្សារភ្ជាប់សកម្មភាពបោសសម្អាតមីនជាមួយនឹងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមប្រកបដោយប្រសិទ្ធភាពនិងប្រសិទ្ធផលខ្ពស់ នៅក្នុងដំណើរការកសាងផែនការនិងចាត់អាទិភាពជាលក្ខណៈប្រព័ន្ធ[៣]។ ដើម្បីឱ្យកម្ពុជាក្លាយជាប្រទេសដែលគ្មានមីន ហើយការគំរាមកំហែងពីស.ផ.ស. ត្រូវបានកាត់បន្ថយដល់កម្រិតអប្បបរមា សំដៅធ្វើឱ្យការអភិវឌ្ឍមនុស្សនិងសេដ្ឋកិច្ចសង្គមអាចប្រព្រឹត្តទៅដោយសុវត្ថិភាព គោលដៅជាយុទ្ធសាស្ត្រដែលប្រទាក់ក្រឡាគ្នា និងមានគោលបំណងជាក់លាក់នីមួយៗ ត្រូវបានដាក់ឱ្យអនុវត្តដើម្បីធ្វើឱ្យសម្រេចបាននូវយុទ្ធសាស្ត្រនីមួយៗដូចខាងក្រោម៖

**គោលបំណងទី១៖ រំដោះផ្ទៃដីដែលដឹងថាមានមីនទាំងអស់ត្រឹមឆ្នាំ២០២៥**

- **គោលដៅទី១៖ បញ្ចប់ការស្រាវជ្រាវចម្ការមីនមូលដ្ឋាន នៅតាមបណ្តាស្រុកដែលនៅសេសសល់ទាំងអស់នៅត្រឹមឆ្នាំ២០២០**
  - **យុទ្ធសាស្ត្រ**
    ១. រៀបចំផែនការសម្រាប់ស្រាវជ្រាវចម្ការមីនមូលដ្ឋាននៅតាមស្រុកសេសសល់ដែលមានមីន និងស.ផ.ស.។
    ២. កៀរគរធនធានសម្រាប់គាំទ្រការស្រាវជ្រាវចម្ការមីនមូលដ្ឋាន។
    ៣. ធ្វើការស្រាវជ្រាវចម្ការមីនមូលដ្ឋាននៅគ្រប់ស្រុកដែលនៅសេសសល់ទាំងអស់ត្រឹមឆ្នាំ២០២០។
- **គោលដៅទី២៖ អនុវត្តការរំដោះផ្ទៃដីតាមរយៈការស្រាវជ្រាវមិនបច្ចេកទេស លើដីត្រូវបានទន្ទ្រានយកមកប្រើប្រាស់ និងលុបចោលតំបន់សង្ស័យ និងធ្វើការស្រាវជ្រាវឡើងវិញដើម្បីធ្វើបច្ចុប្បន្នភាពទិន្នន័យដីដែលមានមីន**
  - **យុទ្ធសាស្ត្រ**
    ១. ចងក្រងឯកសារទស្សនាទាន និងការសិក្សាវិភាគករណីអំពីការស្រាវជ្រាវមិនបច្ចេកទេសលើដីត្រូវបានទន្ទ្រានយកមកប្រើប្រាស់ និងលុបចោលតំបន់សង្ស័យ និងការស្រាវជ្រាវឡើងវិញ។
    ២. លើកកម្ពស់និងពង្រីកការអនុវត្តគំនិតផ្តួចផ្តើមអំពីការស្រាវជ្រាវមិនបច្ចេកទេសលើដីត្រូវបានទន្ទ្រានយកមកប្រើប្រាស់ និងលុបចោលតំបន់សង្ស័យ និងការស្រាវជ្រាវឡើងវិញ។
    ៣. ពង្រឹងសមត្ថភាពក្នុងការអនុវត្តការស្រាវជ្រាវមិនបច្ចេកទេសលើដី ត្រូវបានទន្ទ្រានយកមកប្រើប្រាស់ និងលុបចោលតំបន់សង្ស័យ និងការស្រាវជ្រាវឡើងវិញ។

---

[៣] ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨, ទំ.១៣៣

- គោលដៅទី៣៖ រំដោះភូមិដែលដឹងថាមានមីនទាំងអស់ជាអាទិភាពនៅត្រឹមឆ្នាំ២០២១ ហើយភូមិនៅសេសសល់នៅត្រឹមឆ្នាំ២០២៥
  - យុទ្ធសាស្ត្រ
    ១. កសាងផែនការប្រតិបត្តិការរយៈពេល ៣ឆ្នាំ ដោយមានការពិនិត្យមើលឡើងវិញប្រចាំឆ្នាំ ផ្អែកលើដំណើរការកំណត់អាទិភាព។
    ២. ដាក់ពង្រាយធនធានបោសសម្អាតនៅតាមភូមិអាទិភាពនានា ដោយគិតគូអំពីតម្រូវការជាអាទិភាពនៅមូលដ្ឋាននៅត្រឹមឆ្នាំ២០២១ ហើយភូមិមានមីនដែលនៅសល់ត្រឹមឆ្នាំ២០២៥។
    ៣. ពង្រឹងការអនុលោមតាមប្រព័ន្ធគ្រប់គ្រងគុណភាព ក្នុងសកម្មភាពបោសសម្អាតមីន។
- គោលដៅទី៤៖ ពិនិត្យឡើងវិញ និងកែលម្អប្រព័ន្ធប្រតិបត្តិការ និងសមត្ថភាពដែលមានស្រាប់
  - យុទ្ធសាស្ត្រ
    ១. ពិនិត្យឡើងវិញ និងកែលម្អប្រព័ន្ធធ្វើផែនការនិងចាត់អាទិភាព។
    ២. ពិនិត្យឡើងវិញ និងកែលម្អវិធីសាស្ត្ររំដោះផ្ទៃដី។
    ៣. ធ្វើពិពិធកម្មការប្រើបច្ចេកវិទ្យាច្នៃប្រឌិតថ្មីក្នុងសកម្មភាពបោសសម្អាតមីន។

**គោលបំណងទី២៖ រំដោះផ្ទៃដីដែលដឹងថាមានគ្រាប់បែកចង្កោមជាអាទិភាពនៅត្រឹមឆ្នាំ២០២៥**

- គោលដៅទី១៖ រៀបចំផែនការ និងចាត់អាទិភាពតំបន់ដែលដឹងថាមានគ្រាប់បែកចង្កោម
  - យុទ្ធសាស្ត្រ
    ១. ពិនិត្យឡើងវិញនូវគោលការណ៍ណែនាំនានា ស្តីពីការធ្វើផែនការនិងការចាត់អាទិភាពនាពេលបច្ចុប្បន្ន សម្រាប់អនុវត្តនៅតំបន់ដែលមានគ្រាប់បែកចង្កោម។
    ២. រៀបចំផែនការ និងចាត់អាទិភាពតំបន់ដែលមានគ្រាប់បែកចង្កោម។
- គោលដៅទី២៖ ធ្វើការស្រាវជ្រាវ និងរំដោះផ្ទៃដីដែលដឹងថាមានគ្រាប់បែកចង្កោម
  - យុទ្ធសាស្ត្រ
    ១. កសាងស្តង់ដារជាតិស្តីពីការស្រាវជ្រាវគ្រាប់បែកចង្កោម និងការរំដោះផ្ទៃដី។
    ២. បង្កើនសមត្ថភាពក្នុងការស្រាវជ្រាវ និងការបោសសម្អាត។
    ៣. ធ្វើការស្រាវជ្រាវរកសំណល់គ្រាប់បែកចង្កោម។
    ៤. រំដោះផ្ទៃដីដែលដឹងថាមានគ្រាប់បែកចង្កោមជាអាទិភាព។

**គោលបំណងទី៣៖ ដោះស្រាយបញ្ហាគំរាមកំហែងពីស.ផ.ស.ផ្សេងទៀត**

- គោលដៅទី១៖ ធ្វើការស្រាវជ្រាវ និងរំដោះផ្ទៃដីដែលដឹងថាមានស.ផ.ស.
  - យុទ្ធសាស្ត្រ
    ១. ពិនិត្យឡើងវិញលើស្តង់ដារសកម្មភាពកម្ចាត់មីនកម្ពុជា ស្តីពីការកាត់រំដោះផ្ទៃដី ដែលមានស.ផ.ស.។
    ២. កំណត់អត្តសញ្ញាណ និងធ្វើការរំដោះផ្ទៃដែលដឹងថាមានស.ផ.ស.នោះ។

- គោលដៅទី២៖ ផ្ដល់ការឆ្លើយតបឱ្យទាន់ពេលវេលាចំពោះសំណើសុំជំនួយអន្តរាគមន៍ផ្នែកប្រតិបត្តិការកំទេចគ្រឿងផ្ទុះពីសហគមន៍ ឬអាជ្ញាធរ
    - យុទ្ធសាស្ត្រ
        ១. ពិនិត្យឡើងវិញ និងពង្រឹងសមត្ថភាពបច្ចុប្បន្នផ្នែកប្រតិបត្តិការកំទេចគ្រឿងផ្ទុះ។
        ២. បង្កើតឱ្យមានប្រព័ន្ធថ្នាក់ជាតិសម្រាប់កត់ត្រានិងរាយការណ៍អំពីស.ផ.ស. ប្រកបដោយនិរន្តរភាព។

**គោលបំណងទី៤៖** កាត់បន្ថយចំនួនគ្រោះថ្នាក់ដោយសារមីននិងស.ផ.ស. ឱ្យនៅកម្រិតអប្បបរមា និងលើកកម្ពស់ជីវភាពរស់នៅរបស់អ្នកនៅរស់រានមានជីវិត និងសហគមន៍ដែលរងផលប៉ះពាល់ដោយសារមីននិងស.ផ.ស.

- គោលដៅទី១៖ ផ្ដល់ការអប់រំកាត់បន្ថយគ្រោះថ្នាក់មីននិងស.ផ.ស. ប្រកបដោយប្រសិទ្ធភាពដល់ប្រជាជននៅតាមតំបន់មានហានិភ័យខ្ពស់ដែលមានស្រាប់ និងតំបន់ដែលហានិភ័យកើតឡើងថ្មីសមស្របទៅតាមភេទ និងអាយុ
    - យុទ្ធសាស្ត្រ
        ១. ពង្រឹងសមត្ថភាពរបស់ប្រតិបត្តិករដើម្បីផ្ដល់ការអប់រំកាត់បន្ថយគ្រោះថ្នាក់មីននិងស.ផ.ស. ប្រកបដោយប្រសិទ្ធភាព។
        ២. សម្របសម្រួលការផ្ដល់សេវាអប់រំកាត់បន្ថយគ្រោះថ្នាក់មីននិងស.ផ.ស. ទៅដល់តំបន់ដែលមានហានិភ័យខ្ពស់ទើបកើតឡើងថ្មី។
        ៣. ធានាថាការអប់រំកាត់បន្ថយគ្រោះថ្នាក់មីននិងស.ផ.ស. ត្រូវបានបញ្ជ្រាបទៅក្នុងកម្មវិធីសិក្សារបស់សាលារៀន។
        ៤. វាយតម្លៃ និងពង្រឹងការអប់រំអំពីហានិភ័យនេះ នៅតាមសហគមន៍។
        ៥. ពង្រឹងផ្នែកអប់រំកាត់បន្ថយគ្រោះថ្នាក់មីននិងស.ផ.ស. នៅក្នុងគោលនយោបាយភូមិឃុំមានសុវត្ថិភាព។
- គោលដៅទី២៖ ផ្ដល់ការគាំទ្រដល់អ្នករស់រានមានជីវិតពីគ្រោះថ្នាក់ដោយសារមីន និងស.ផ.ស. និងជនរងគ្រោះដោយប្រយោល ដើម្បីទទួលបានការថែទាំផ្នែកវេជ្ជសាស្ត្រ និងផ្លូវចិត្តឱ្យបានគ្រប់គ្រាន់និងសមស្របទៅនឹងយេនឌ័រ និងការស្ដារលទ្ធភាពពលកម្មកាយសម្បទា
    - យុទ្ធសាស្ត្រ
        ១. ធានាឱ្យមានការចងក្រងជាឯកសារស្ដីពីអ្នករស់រានពីមីននិងស.ផ.ស. ព្រមទាំងជនរងគ្រោះដោយប្រយោល និងធ្វើការចែករំលែកព័ត៌មាននេះដល់ក្រសួងស្ថាប័ន របស់រដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរាជរដ្ឋាភិបាលដែលមានការពាក់ព័ន្ធសម្រាប់ការប្រើប្រាស់ផ្សេងៗ។
        ២. ពង្រឹងយន្តការសម្របសម្រួលថ្នាក់ជាតិស្ដីពីពិការភាព ដើម្បីធានាថា តម្រូវការនិងសិទ្ធិរបស់អ្នកនៅរស់រានមានជីវិតពីគ្រោះថ្នាក់មីននិងស.ផ.ស. ព្រមទាំងជនរងគ្រោះដោយប្រយោលត្រូវបានដោះស្រាយទាន់ពេលវេលា និងសមស្រប។

- គោលដៅទី៣៖ លើកកម្ពស់សមត្ថភាពប្រកបរបរចិញ្ចឹមជីវិតសម្រាប់អ្នករស់រានមានជីវិត ដោយសារគ្រោះថ្នាក់ពីមីននិងស.ផ.ស. ព្រមទាំងជនរងគ្រោះដោយប្រយោល ដើម្បីលើកកម្ពស់ការចូលរួមពេញលេញក្នុងសង្គម
  - យុទ្ធសាស្ត្រ
    ១. ជំរុញការធ្វើសមាហរណកម្មអ្នករស់រានមានជីវិតដោយសារគ្រោះថ្នាក់ពីមីន និងស.ផ.ស.ទៅក្នុងសង្គម តាមរយៈការផ្តល់នូវការបណ្តុះបណ្តាលវិជ្ជាជីវៈ និងសកម្មភាពប្រកបរបរចិញ្ចឹមជីវិត។

**គោលបំណងទី៥៖ រួមចំណែកដល់កំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ**

- គោលដៅទី១៖ គាំទ្រដល់អាទិភាពនៃការអភិវឌ្ឍមូលដ្ឋានក្នុងសហគមន៍ ដែលរងផលប៉ះពាល់ដោយសារមីន គ្រាប់បែកចង្កោម និងស.ផ.ស.ផ្សេងទៀត
  - យុទ្ធសាស្ត្រ
    ១. ធានាថាការធ្វើផែនការនិងការកំណត់អាទិភាពនៃសកម្មភាពមីន ដើរស្របគ្នាជាមួយនឹងអាទិភាពនិងផែនការអភិវឌ្ឍន៍មូលដ្ឋាន។
- គោលដៅទី២៖ គាំទ្រដល់អាទិភាពនៃការអភិវឌ្ឍថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
  - យុទ្ធសាស្ត្រ
    ១. ជំរុញគម្រោងអភិវឌ្ឍន៍នៅតាមតំបន់ដែលរងផលប៉ះពាល់ដោយសារមីន គ្រាប់បែកចង្កោម និងស.ផ.ស.ផ្សេងទៀត។
    ២. តស៊ូមតិឱ្យមានការបែងចែកថវិកាសម្រាប់សកម្មភាពកម្ចាត់មីននៅក្នុងគម្រោងអភិវឌ្ឍន៍ជាតិ។

**គោលបំណងទី៦៖ ជំរុញនិសព្វាវុធការក្នុងតំបន់និងអន្តរជាតិ និងកិច្ចសហប្រតិបត្តិការក្នុងសកម្មភាពមីន**

- គោលដៅទី១ ៖ ជំរុញការអនុវត្តកាតព្វកិច្ចដែលមានចែងក្នុងអ.ហ.ផ.ម.
  - យុទ្ធសាស្ត្រ
    ១. ធានាការអនុវត្តយ៉ាងពេញលេញនូវកាតព្វកិច្ចដែលមានចែងក្នុងអ.ហ.ផ.ម. ជាពិសេសមាត្រា៧ ស្តីពីវិធានការតម្លាភាព និងមាត្រា៥ ស្តីពីការបំផ្លាញមីនប្រឆាំងមនុស្ស។
    ២. ធានាការចូលរួមយ៉ាងពេញលេញរបស់កម្ពុជា នៅក្នុងយន្តការអន្តរជាតិដើម្បីលើកកម្ពស់កិច្ចសហប្រតិបត្តិការតំបន់ និងអន្តរជាតិ(ក្របខ័ណ្ឌអ.ហ.ផ.ម. ២០២៥)។
- គោលដៅទី២៖ ជំរុញការអនុវត្តកាតព្វកិច្ចដែលមានចែងក្នុងអនុសញ្ញាសព្វាវុធធម្មតាមួយចំនួន និងគាំទ្រដល់ដល់វឌ្ឍនភាពឆ្ពោះទៅរកការចូលរួមក្នុងពិធីសារទី៥
  - យុទ្ធសាស្ត្រ
    ១. ធានាការអនុវត្តយ៉ាងពេញលេញនូវកាតព្វកិច្ច ដែលមានចែងក្នុងអនុសញ្ញាសព្វាវុធធម្មតាមួយចំនួន។

២. រួមចំណែកក្នុងការកសាងកុងសង់ស៊ុសក្នុងចំណោមភាគីជាតិពាក់ព័ន្ធ ដើម្បីជានាការចូលរួមក្នុងពិធីសារទី៥ នៃអនុសញ្ញាសព្វាវុធជម្ពូតាមួយចំនួន។

- **គោលដៅទី៣៖ គាំទ្រដល់ការចូលជារដ្ឋភាគីនៃអនុសញ្ញាស្តីពីគ្រាប់បែកចង្កោមត្រឹមឆ្នាំ២០២០**
  - **យុទ្ធសាស្ត្រ**

    ១. រួមចំណែកក្នុងការកសាងកុងសង់ស៊ុសក្នុងចំណោមភាគីជាតិពាក់ព័ន្ធ ដើម្បីធានាបានថាកម្ពុជាក្លាយជារដ្ឋភាគីនៃអនុសញ្ញាហាមប្រាមការប្រើប្រាស់គ្រាប់បែកចង្កោម។

- **គោលដៅទី៤៖ គាំទ្រដល់ប្រតិបត្តិការបោសសម្អាតមីនក្នុងក្របខ័ណ្ឌនៃប្រតិបត្តិការរក្សាសន្តិភាព នៃអង្គការសហប្រជាជាតិ**
  - **យុទ្ធសាស្ត្រ**

    ១. ធានាថាប្រតិបត្តិការនៃសកម្មភាពបោសសម្អាតមីន ដែលស្ថិតនៅក្នុងប្រតិបត្តិការរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ ត្រូវបានទទួលស្គាល់ស្របតាមស្តង់ដារសកម្មភាពមីនអន្តរជាតិ។

    ២. ដាក់ពង្រាយក្រុមបោសសម្អាតមីននិងក្រុមប្រតិបត្តិការកំទេចគ្រឿងផ្ទុះ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់របស់កងយោធពលខេមរភូមិន្ទ ដែលស្ថិតនៅក្នុងប្រតិបត្តិការរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ។

- **គោលដៅទី៥៖ លើកកម្ពស់កិច្ចសហប្រតិបត្តិការនិងជំនួយអន្តរជាតិ ក្នុងសកម្មភាពមីន រួមបញ្ចូលទាំងកិច្ចសហប្រតិបត្តិការត្បូង-ត្បូង**
  - **យុទ្ធសាស្ត្រ**

    ១. បង្កើតជាស្ថាប័នគ្រប់គ្រងសមត្ថភាពបោសសម្អាតមីន ដែលអាចប្រើប្រាស់ក្នុងការលើកកម្ពស់កិច្ចសហប្រតិបត្តិការនិងជំនួយអន្តរជាតិ។

    ២. គាំទ្រដល់រដ្ឋដទៃដែលរងផលប៉ះពាល់ដោយសារមីននិងស.ផ.ស. តាមរយៈប្រតិបត្តិការបោសសម្អាតមីន និងការចែករំលែកបទពិសោធន៍ល្អៗ និងមេរៀនដែលទទួលបានពីការអនុវត្តរបស់កម្ពុជាក្នុងសកម្មភាពមីន។

**គោលបំណងទី៧៖ បង្កើតឱ្យមានសមត្ថភាពជាតិប្រកបដោយនិរន្តរភាព ដើម្បីដោះស្រាយការគំរាមកំហែងដែលនៅសេសសល់ក្រោយឆ្នាំ២០២៥**

- **គោលដៅទី១៖ ពង្រឹងសមត្ថភាពជាតិដើម្បីគ្រប់គ្រង និងអនុវត្តន៍កម្មវិធីសកម្មភាពមីនឱ្យមានប្រសិទ្ធភាព និងប្រសិទ្ធផល**
  - **យុទ្ធសាស្ត្រ**

    ១. ធ្វើការវាយតម្លៃសេចក្តីត្រូវការផ្នែកការអភិវឌ្ឍសមត្ថភាព និងកសាងផែនការអនុវត្ត។

    ២. ពង្រឹងនិងថែរក្សាឱ្យមាននិរន្តរភាពនូវសមត្ថភាពរបស់អាជ្ញាធរថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិព្រមទាំងអាណត្តិរបស់ពួកគេ។

- **គោលដៅទី២៖ ថែរក្សា កែលម្អ និងចែករំលែកចំណេះដឹងអំពីសកម្មភាពមីន នៅក្នុងវិស័យនេះនិងដល់វិស័យផ្សេងៗទៀត**

- យុទ្ធសាស្ត្រ

១. កសាងយុទ្ធសាស្ត្រសម្រាប់គ្រប់គ្រងចំណេះដឹង រួមមានការបង្កើតចំណេះដឹង ការរក្សាទុក/ការទាញយកប្រើប្រាស់ ការផ្ទេរ និងការអនុវត្ត។

- **គោលដៅទី៣៖ ធ្វើការពិនិត្យឡើងវិញនៅត្រឹមឆ្នាំ២០២០ នូវក្របខ័ណ្ឌច្បាប់ ស្ថាប័ន និងប្រតិបត្តិការ ព្រមទាំងយុទ្ធសាស្ត្រនិងសមត្ថភាព ដែលចាំបាច់សម្រាប់ដោះស្រាយការគំរាមកំហែងដែលនៅសេសសល់**

- យុទ្ធសាស្ត្រ

១. ធ្វើការវាយតម្លៃអំពីក្របខ័ណ្ឌច្បាប់ ស្ថាប័ន និងប្រតិបត្តិការ ព្រមទាំងសមត្ថភាពសម្រាប់ដោះស្រាយការគំរាមកំហែងដែលនៅសេសសល់។

២. កំណត់អំពីការកសាងសមត្ថភាពនិងធនធានចាំបាច់នានា សម្រាប់ដោះស្រាយការគំរាមកំហែងដែលនៅសេសសល់។

- **គោលដៅទី៤៖ កសាង ពង្រឹង និងថែរក្សាសមត្ថភាពជាតិប្រកបដោយនិរន្តរភាព ដើម្បីដោះស្រាយការគំរាមកំហែងដែលនៅសេសសល់ក្រោយឆ្នាំ ២០២៥ ឱ្យមានប្រសិទ្ធភាព**

- យុទ្ធសាស្ត្រ

១. កសាងក្របខ័ណ្ឌច្បាប់និងស្ថាប័នដើម្បីឱ្យសមត្ថភាពជាតិមាននិរន្តរភាព។

២. កសាងក្របខ័ណ្ឌប្រតិបត្តិការ និងផែនការអំពីធនធាននិងសមត្ថភាព សម្រាប់ដោះស្រាយការគំរាមកំហែងដែលនៅសេសសល់។

៣. សម្របសម្រួលនិងអនុវត្តផែនការជាតិ ជាមួយអាជ្ញាធរមានសមត្ថកិច្ចដែលបានចាត់តាំង ដើម្បីដោះស្រាយការគំរាមកំហែងផ្សេងៗដែលនៅសេសសល់។

៤. កសាងប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃដែលស៊ីសង្វាក់គ្នាសម្រាប់ការអនុវត្តផែនការជាតិ។

៥. ពង្រឹងសមត្ថភាពគ្រប់គ្រងព័ត៌មាន ដើម្បីគាំទ្រដល់កិច្ចអន្តរាគមន៍ចំពោះបញ្ហាគំរាមកំហែងដែលនៅសេសសល់។

**គោលបំណងទី៨៖ ធានាថាសកម្មភាពមីនត្រូវបានគាំទ្រដោយប្រព័ន្ធគ្រប់គ្រងគុណភាពល្អប្រសើរ ការគ្រប់គ្រងព័ត៌មានប្រកបដោយប្រសិទ្ធភាព ប្រកបដោយការយកចិត្តទុកដាក់ខ្ពស់អំពីយេនឌ័រ និងការការពារបរិស្ថាន**

- **គោលដៅទី១៖ ពង្រឹងប្រព័ន្ធគ្រប់គ្រងគុណភាព**

- យុទ្ធសាស្ត្រ

១. ពិនិត្យមើលឡើងវិញ ធ្វើបច្ចុប្បន្នភាព និងកសាងស្តង់ដារសកម្មភាពកំចាត់មីនកម្ពុជាដែលពាក់ព័ន្ធ។

២. ពង្រឹង និងរក្សាឱ្យមាននិរន្តរភាពនូវសមត្ថភាពនិងប្រព័ន្ធសម្រាប់ការគ្រប់គ្រងគុណភាព។

- **គោលដៅទី២៖ ពង្រឹងប្រព័ន្ធគ្រប់គ្រងព័ត៌មានថ្នាក់ជាតិ សម្រាប់សកម្មភាពមីន**

- យុទ្ធសាស្ត្រ

១. ពង្រឹងសមត្ថភាពគ្រប់គ្រងព័ត៌មាន និងធានាឱ្យមាននិរន្តរភាពនៃប្រព័ន្ធថ្នាក់ជាតិ។
២. ពិនិត្យឡើងវិញ និងពង្រឹងស្តង់ដារពាក់ព័ន្ធស្តីពីការគ្រប់គ្រងព័ត៌មាន។
៣.ធ្វើពិពិធកម្មការប្រើបច្ចេកវិទ្យាថ្មៃប្រឌិតថ្មីដើម្បីកែលម្អការគ្រប់គ្រងព័ត៌មានឱ្យប្រសើរឡើង។

- **គោលដៅទី៣៖ ជំរុញការបញ្ជ្រាបយេនឌ័រនៅក្នុងសកម្មភាពមីន**
  - **យុទ្ធសាស្ត្រ**

១. កសាងផែនការបញ្ជ្រាបយេនឌ័រក្នុងវិស័យសកម្មភាពមីន(GMAP) និងគោលការណ៍ណែនាំអំពីការបញ្ជ្រាបយេនឌ័រ។
២. ពង្រឹងសមត្ថភាពរបស់អាជ្ញាធរមីន អង្គភាពផែនការសកម្មភាពមីន ប្រតិបត្តិករ អាជ្ញាធរថ្នាក់ក្រោមជាតិ និងអាជ្ញាធរមូលដ្ឋានក្នុងការអនុវត្តគោលការណ៍ណែនាំអំពីការបញ្ជ្រាបយេនឌ័រ។
៣. លើកកម្ពស់ការចូលរួមប្រកបដោយស្មើភាពរបស់ស្ត្រី ក្នុងដំណើរការសកម្មភាពមីន ការផ្តល់សេវាកម្មសម្រាប់អ្នកនៅរស់រានមានជីវិត ការអប់រំកាត់បន្ថយគ្រោះថ្នាក់មីននិងសកម្មភាពស្វែងរកការគាំទ្រមតិ។

- **គោលដៅទី៤៖ បញ្ជ្រាបកិច្ចការពារបរិស្ថានក្នុងសកម្មភាពមីន**
  - **យុទ្ធសាស្ត្រ**

១. កសាងស្តង់ដារសកម្មភាពមីនកម្ពុជាស្តីពីបរិស្ថាន ដោយស្របតាមស្តង់ដារសកម្មភាពមីនអន្តរជាតិស្តីពីបរិស្ថាន។
២. ពង្រឹងសមត្ថភាពរបស់អាជ្ញាធរមីន អង្គភាពធ្វើផែនការសកម្មភាពកម្ចាត់មីន ប្រតិបត្តិករ អាជ្ញាធរថ្នាក់ក្រោមជាតិ និងអាជ្ញាធរមូលដ្ឋានដើម្បីអនុវត្តតាមស្តង់ដារសកម្មភាពកំចាត់មីនកម្ពុជាស្តីពីបរិស្ថាន។

- **គោលដៅទី៥៖ ប្រព័ន្ធត្រួតពិនិត្យសកម្មភាពមីនត្រូវបានអនុវត្ត**
  - **យុទ្ធសាស្ត្រ**

១. កសាងប្រព័ន្ធត្រួតពិនិត្យសកម្មភាពមីនដោយមានការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ។
២. បង្កើតសមត្ថភាព និងអនុវត្តប្រព័ន្ធត្រួតពិនិត្យសកម្មភាពមីន។

# ៦. សកម្មភាពការងារ

បន្ទាប់ពីផ.យ.ជ.ម. ២០១៨-២០២៥នេះ ត្រូវបានអនុម័តរួច អាជ្ញាធរមីននឹងចាប់ផ្តើមសកម្មភាពជាបន្តបន្ទាប់ ដើម្បីអនុវត្តយុទ្ធសាស្ត្រដែលបានកំណត់ប្រកបដោយប្រសិទ្ធភាពនិងប្រសិទ្ធផល។ សកម្មភាពទាំងនោះនឹងជានាការយល់ដឹង និងការចូលរួមជាបន្តបន្ទាប់ពីសំណាក់ភាគីពាក់ព័ន្ធទាំងអស់នៅក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិនេះ។ សកម្មភាពទាំងនេះត្រូវបានចែកចេញជាពីរដំណាក់កាល គឺដំណាក់កាលទី១ ចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២២ និងដំណាក់កាលទី២ ចាប់ពីឆ្នាំ២០២៣ ដល់ឆ្នាំ២០២៥។

**ដំណាក់កាលទី១ (២០១៨-២០២២)**

- ធ្វើប្រកាសផ្សព្វផ្សាយដើម្បីដាក់ឱ្យអនុវត្តនូវយុទ្ធសាស្ត្រជាតិស្តីពីសកម្មភាពកម្ចាត់មីន ២០១៨-២០២៥
- កសាងប្រព័ន្ធត្រួតពិនិត្យសកម្មភាពមីន
- កសាងផែនការអនុវត្តលម្អិត
- កសាងផែនការកៀរគរធនធានដើម្បីគាំទ្រការអនុវត្តយុទ្ធសាស្ត្រ
- រៀបចំសំណើសុំពន្យារពេលជាលើកទី២ ពាក់ព័ន្ធនឹងការកំណត់កាលបរិច្ឆេទសម្រាប់ការបំផ្លាញមីនប្រឆាំងមនុស្សនៅតំបន់ដែលមានមីន ស្របតាមមាត្រា៥ នៃអនុសញ្ញាហាមប្រាមការប្រើប្រាស់មីនប្រឆាំងមនុស្ស ឆ្នាំ២០១៩
- ធ្វើការពិនិត្យឡើងវិញរយៈពេលមធ្យម ដោយផ្តោតលើការឆ្ពោះទៅរកការដោះស្រាយសំណល់ដែលនៅសេសសល់នៅត្រឹមឆ្នាំ២០២០
- កសាងយុទ្ធសាស្ត្រសម្រាប់ដោះស្រាយការគំរាមកំហែងដែលនៅសេសសល់
- កសាងក្របខ័ណ្ឌច្បាប់ និងស្ថាប័នសម្រាប់ដោះស្រាយបញ្ហាគំរាមកំហែងដែលនៅសេសសល់
- កសាងក្របខ័ណ្ឌនិយ័តកម្មនិងប្រតិបត្តិការ សម្រាប់ដោះស្រាយបញ្ហាគំរាមកំហែងដែលនៅសេសសល់ រួមទាំងការសម្របសម្រួល ការធ្វើផែនការនិងការកំណត់អាទិភាព និងប្រព័ន្ធគ្រប់គ្រងព័ត៌មានប្រកបដោយនិរន្តរភាព។

**ដំណាក់កាលទី២ (២០២៣-២០២៥)**

- កសាងសមត្ថភាពសម្រាប់ដោះស្រាយបញ្ហាគំរាមកំហែងនានាដែលនៅសេសសល់ ក្នុងការត្រៀមខ្លួនសម្រាប់ការផ្លាស់ប្តូរពីកម្មវិធីសកម្មភាពមីនចាស់
- កំណត់យុទ្ធសាស្ត្រសម្រាប់កៀរគរធនធាននានាដើម្បីគាំទ្រដល់ការអភិវឌ្ឍសមត្ថភាព ដោះស្រាយបញ្ហាគំរាមកំហែងដែលនៅសេសសល់ និងសកម្មភាពនានានៅពេលអនាគត
- ធ្វើការវាយតម្លៃក្រោយការអនុវត្តអំពីសមិទ្ធផលនិងលទ្ធផល បន្ទាប់ពីការបញ្ចប់យុទ្ធសាស្ត្រនេះនៅឆ្នាំ២០២៥ ដើម្បីវាយតម្លៃការអនុវត្ត មេរៀនបទពិសោធន៍ អនុសាសន៍ដើម្បីលើកកម្ពស់ប្រសិទ្ធភាព និងការកែលម្អសកម្មភាពកម្ចាត់មីនដែលនៅសេសសល់។

# ៧. ក្របខ័ណ្ឌស្ថាប័ន

រចនាសម្ព័ន្ធនៃវិស័យសកម្មភាពមីននៅកម្ពុជា ត្រូវបានបែងចែកដាច់ពីគ្នា រវាងមុខងារគោលនយោបាយ និងនិយ័តកម្មពីមុខងារផ្តល់សេវា ពោលគឺការបំពេញប្រតិបត្តិការនៅមូលដ្ឋានផ្ទាល់ ការធ្វើផែនការនិងការចាត់អាទិភាព និងប្រតិបត្តិការឆ្លើយតបជាអន្តរជាតិ។ ការបែងចែកបែបនេះត្រូវបានចាត់ទុកថាស្របទៅតាមឧត្តមានុវត្តន៍នានាដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ ហើយនឹងត្រូវបន្តអនុវត្តបែបនេះតទៅមុខទៀត។

## ក. អាជ្ញាធរជាតិ

កម្ពុជាបានបង្កើតអាជ្ញាធរមីនឡើង ដើម្បីគ្រប់គ្រងវិស័យនេះ។ អាជ្ញាធរមីនត្រូវបានផ្តល់អាណត្តិដោយព្រះរាជក្រឹត្យ ដោយមាន**សម្តេចនាយករដ្ឋមន្ត្រី** ជាប្រធាន អនុប្រធាន ០២រូប និងអគ្គលេខាធិការ ០១រូប ដែលទទួលខុសត្រូវលើកិច្ចការអនុវត្តប្រចាំថ្ងៃ។

អាជ្ញាធរមីនមានតួនាទីនិងភារកិច្ចធ្វើនិយ័តកម្ម គ្រប់គ្រង ផ្តល់អាជ្ញាប័ណ្ណនិងការទទួលស្គាល់ សម្របសម្រួល និងតាមដានត្រួតពិនិត្យរាល់សកម្មភាពមីនទាំងអស់ រួមមានការបោសសម្អាតមីននិងស.ផ.ស. ផ្តល់ការអប់រំកាត់បន្ថយគ្រោះថ្នាក់មីននិងស.ផ.ស. និងផ្តល់ជំនួយគាំទ្រដល់ជនរងគ្រោះ ក៏ដូចជាកសាងផែនការយុទ្ធសាស្ត្រជាតិស្តីពីសកម្មភាពមីន ដើម្បីសម្រេចបាននូវគោលដៅអាទិភាពដែលកំណត់ដោយគោលនយោបាយអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលកម្ពុជា។

## ខ. ស្ថាប័នធ្វើផែនការ និងកំណត់អាទិភាព

គណៈកម្មាធិការសកម្មភាពមីនខេត្ត(PMAC) និងអង្គភាពធ្វើផែនការសកម្មភាពកម្ចាត់មីន(MAPU) គឺជាអង្គភាពដ៏មានប្រសិទ្ធភាព ដែលមានមធ្យោបាយសម្រាប់ធ្វើការចាត់អាទិភាពក្នុងការងារបោសសម្អាតមីន។ ដោយមានអាជ្ញាធរមូលដ្ឋាននិងអង្គការបោសសម្អាតមីនដែលធ្វើការជាមួយគ្នា ហើយស្ថាប័នទាំងនេះគឺជាយន្តការមួយដែលអាចធានាថា តម្រូវការរបស់សហគមន៍ត្រូវបានយកមកពិចារណាក្នុងអំឡុងពេលនៃការចាត់អាទិភាពលើផែនការសកម្មភាព ហើយដីដែលបានបោសសម្អាតរួចត្រូវបានវាយតម្លៃសម្រាប់យកទៅប្រើប្រាស់តាមការគ្រោងទុក។

## គ. អ្នកផ្តល់សេវា ការបោសសម្អាតមីន កម្មវិធីអប់រំកាត់បន្ថយគ្រោះថ្នាក់មីននិងស.ផ.ស. និងជំនួយគាំទ្រដល់ជនរងគ្រោះ

ជាមួយនឹងបទពិសោធន៍ចាប់តាំងពីឆ្នាំ១៩៩២មក ប្រតិបត្តិករជាតិនិងអន្តរជាតិ ទាំងផ្នែកមនុស្សធម៌ និងផ្នែកពាណិជ្ជកម្ម នឹងបន្តតួនាទីដ៏សំខាន់របស់ខ្លួនក្នុងការធ្វើការស្រាវជ្រាវ និងប្រតិបត្តិការដោះមីននៅទូទាំងប្រទេស។ បច្ចុប្បន្ន មានអ្នកដោះមីនប្រមាណ ៥ ៨៥០នាក់ ប្រកបដោយវិជ្ជាជីវៈច្បាស់លាស់ ដែលកំពុងបំពេញភារកិច្ចក្នុងវិស័យនេះ។ ការអប់រំអំពីហានិភ័យដោយសារមីន និងជំនួយគាំទ្រដល់ជនរងគ្រោះ ត្រូវបានធ្វើឡើងដោយប្រតិបត្តិករដោះមីនមួយចំនួនដែលមានការទទួលស្គាល់ ព្រមទាំងកាកបាទក្រហមកម្ពុជា ក្រសួង

អប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ជំនួយគាំទ្រដល់ជនរងគ្រោះ) និងអង្គការមិនមែនរដ្ឋាភិបាលជាច្រើនទៀត។

### ឃ. អង្គការជំនាញ

អង្គការសកម្មភាពបោសសម្អាតមីនមួយចំនួន បានផ្តល់ការប្រឹក្សាយោបល់ជំនាញជាទៀងទាត់ដល់កម្ពុជា។ មជ្ឈមណ្ឌលអន្តរជាតិទីក្រុងហ្សឺណែវសម្រាប់បោសសម្អាតមីនមនុស្សធម៌ សាកលវិទ្យាល័យជេមស៍ម៉ាឌីសុន(JMU) និងសេវាកម្មសកម្មភាពកម្ចាត់មីនរបស់អង្គការសហប្រជាជាតិ(UNMAS) បានផ្តល់ការប្រឹក្សាយោបល់ផ្នែកបច្ចេកទេសក្នុងផ្នែកជាច្រើន ដូចជាវិធីសាស្ត្ររំដោះផ្ទៃដី ការបញ្ញាបយេនឌ័រ ស្តង់ដារសកម្មភាពកម្ចាត់មីន និងស្តង់ដាអាអេសអូ(ISO Standard) ជាដើម។ ពួកគេអាចផ្តល់ការវាយតម្លៃលក្ខណៈឯករាជ្យមួយចំពោះវិស័យនេះ។ អង្គការថ្នាក់តំបន់មួយទៀតដែលកំពុងរីកចម្រើន គឺមជ្ឈមណ្ឌលតំបន់អាស៊ានសម្រាប់សកម្មភាពមីន(ARMAC) ដែលត្រូវបានបង្កើតឡើងនៅរាជធានីភ្នំពេញ។ ស្ថាប័ននេះនឹងជានាឱ្យមានកិច្ចសហប្រតិបត្តិការបច្ចេកទេស និងការផ្លាស់ប្តូរព័ត៌មានរវាងរដ្ឋជាសមាជិកអាស៊ានពាក់ព័ន្ធនឹងសកម្មភាពមីន។

### ង. ដៃគូអភិវឌ្ឍន៍

រហូតដល់ពេលនេះ ម្ចាស់ជំនួយទ្វេភាគីនិងពហុភាគី បានដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់នូវធនធានយ៉ាងច្រើនដែលត្រូវការសម្រាប់ការកសាងគោលនយោបាយ និងប្រតិបត្តិការបោសសម្អាតមីននៅទូទាំងប្រទេស។ កម្ពុជាមិនអាចបានសម្រេចបាននូវសមិទ្ធផលដ៏គួរឱ្យកត់សម្គាល់ដូចមាននៅសព្វថ្ងៃនេះឡើយ ប្រសិនបើគ្មានការចូលរួមចំណែកពីម្ចាស់ជំនួយបរទេសទេនោះ។ ការគាំទ្រផ្នែកហិរញ្ញវត្ថុនិងបច្ចេកទេសពីដៃគូអភិវឌ្ឍន៍នៅតែមានភាពចាំបាច់ ដើម្បីជួយឱ្យកម្ពុជាអាចបំពេញកាតព្វកិច្ចរបស់ខ្លួនចំពោះអ.ហ.ផ.ម. និងសម្រេចបាននូវផែនការយុទ្ធសាស្ត្រសកម្មភាពមីនរបស់កម្ពុជា។

# ៨. ក្របខ័ណ្ឌប្រតិបត្តិការ

ការអនុវត្តយុទ្ធសាស្ត្រអាចទទួលបានជោគជ័យ គឺអាស្រ័យលើការរៀបចំប្រតិបត្តិការដែលមានប្រសិទ្ធភាព និងមានលក្ខណៈបំពេញឱ្យគ្នាទៅវិញទៅមក។ គន្លឹះសម្រាប់ការអនុវត្ត ផ.យ.ជ.ម. ២០១៨-២០២៥ ដើម្បីឱ្យទទួលជោគជ័យ មានដូចបានរៀបរាប់នៅខាងក្រោមនេះ។

## ក. ការស្រាវជ្រាវមូលចម្ការមីនមូលដ្ឋាន

ពាក្យ «**ការស្រាវជ្រាវចម្ការមីនមូលដ្ឋាន**» ពិពណ៌នាអំពីសកម្មភាពស្រាវជ្រាវមួយដើម្បីប្រមូល និងវិភាគព័ត៌មានក្នុងមូលដ្ឋាន ដើម្បីកំណត់នូវទំហំនិងចាត់ថ្នាក់លើតំបន់ដែលសង្ស័យថាមានមីននិងស.ផ.ស.។ ការស្រាវជ្រាវមូលដ្ឋាន នាំទៅដល់ការប្រើចំណាត់ថ្នាក់ប្រភេទដីសម្រាប់តំបន់ដែលសង្ស័យថាមានមីននិងស.ផ.ស. ដែលរួមមានចំណាត់ថ្នាក់ A ជាតំបន់ដែលមានមីន និងចំណាត់ថ្នាក់ B (ការគំរាមកំហែងដែលនៅសេសសល់) ជាតំបន់ដែលមានស.ផ.ស. ហើយការស្រាវជ្រាវចម្ការមីនជាមូលដ្ឋានជាបន្តបន្ទាប់មកទៀត (ការស្រាវជ្រាវមិនបច្ចេកទេស) នាំទៅដល់ការចាត់ចំណាត់ថ្នាក់ C (ដីបញ្ចប់ការគំរាមកំហែង) ជាដីដែលត្រូវបានរំដោះរួចរាល់។

លទ្ធផលនៃការស្រាវជ្រាវចម្ការមីនមូលដ្ឋាន គឺជាឧបករណ៍ដ៏មានប្រសិទ្ធភាពសម្រាប់ការធ្វើផែនការនិងចាត់អាទិភាពនៃការបោសសម្អាតមីននិងស.ផ.ស.។ គោលបំណងសំខាន់ គឺត្រូវធ្វើការស្រាវជ្រាវចម្ការមីនមូលដ្ឋានឱ្យបានចប់សព្វគ្រប់នៅទូទាំងប្រទេស។ ដើម្បីសម្រេចបាននូវគោលបំណងនេះ តម្រូវឱ្យមានការធ្វើផែនការប្រកបដោយប្រសិទ្ធភាព និងការខិតខំប្រឹងប្រែងរួមគ្នាបន្ថែមទៀតពីសំណាក់អាជ្ញាធរមីន ម្ចាស់ជំនួយ និងប្រតិបត្តិករនានា។ គុណភាពនៃការស្រាវជ្រាវនឹងត្រូវពឹងផ្អែកលើអ្នកជំនាញផ្នែកស្រាវជ្រាវ ដែលបានទទួលការបណ្តុះបណ្តាលត្រឹមត្រូវដោយមានវិធីសាស្ត្រគ្រប់គ្រាន់ ដូចជាជំនាញទំនាក់ទំនងល្អ បច្ចេកទេសសម្ភាសន៍ ការប្រមូលនិងការកត់ត្រាព័ត៌មាន និងការយល់ដឹងអំពីវិធីសាស្ត្រនានាដែលផ្អែកលើភ័ស្តុតាង។ ដូចនេះ មានតែប្រតិបត្តិករដែលត្រូវបានទទួលស្គាល់ប៉ុណ្ណោះ ដែលនឹងធ្វើការស្រាវជ្រាវគ្រប់ជ្រុងជ្រោយនៅក្នុងតំបន់ទទួលខុសត្រូវនៅតាមបណ្តាភូមិ-ឃុំជាលក្ខណៈប្រព័ន្ធ ដោយអនុលោមតាមស្តង់ដានីតិវិធីប្រតិបត្តិការ ស្របទៅនឹងស្តង់ដារកម្ចាត់មីនកម្ពុជាជំពូកទី១៤ និងរាល់គោលការណ៍ណែនាំដែលចេញដោយអាជ្ញាធរមីន។ ការស្រាវជ្រាវចម្ការមីនមូលដ្ឋាននឹងផ្តល់ទិន្នន័យបច្ចុប្បន្នភាពលើតំបន់ដែលមានមីននិងស.ផ.ស. ដល់អង្គភាពទិន្នន័យ(DBU) នៃអាជ្ញាធរមីន ដែលនឹងធ្វើការយ៉ាងជិតស្និទ្ធជាមួយប្រតិបត្តិករដើម្បីបញ្ជាក់និងពង្រឹងព័ត៌មានថ្មីៗ ជាមួយសំណុំទិន្នន័យដែលមានស្រាប់។ អង្គភាពទិន្នន័យនៃអាជ្ញាធរមីននឹងដើរតួនាទីសំខាន់ក្នុងការវិភាគទិន្នន័យដែលទទួលបានពីការស្រាវជ្រាវចម្ការមីនមូលដ្ឋាន ដើម្បីគាំទ្រដល់គោលនយោបាយបែងចែកធនធាននៅថ្នាក់ជាតិ។ ការស្រាវជ្រាវចម្ការមីនមូលដ្ឋាននឹងត្រូវបញ្ចប់នៅឆ្នាំ២០២០។ ទិន្នន័យនឹងត្រូវបានរក្សាទុក ហើយអាចទាញយកមកប្រើប្រាស់បានពីប្រព័ន្ធទិន្នន័យជាតិ។ លទ្ធផលផ្លូវការនៃការស្រាវជ្រាវចម្ការមីនមូលដ្ឋាននឹងត្រូវបានពន្យល់ ចែករំលែក និងផ្សព្វផ្សាយតាមរយៈសិក្ខាសាលាភាគីពាក់ព័ន្ធដែលរៀបចំដោយអាជ្ញាធរមីន ។

## ខ. ការធ្វើផែនការនិងការចាត់អាទិភាព

ការធ្វើផែនការនិងការចាត់អាទិភាព គឺជាដំណើរការដ៏សំខាន់មួយដែលមានឥទ្ធិពលដោយផ្ទាល់ទៅលើប្រសិទ្ធភាព និងប្រសិទ្ធផលនៃវិស័យនេះ។ ការអនុវត្តនាពេលបច្ចុប្បន្ន សម្រាប់ការធ្វើផែនការនិងការចាត់អាទិភាពនៅក្នុងប្រទេសកម្ពុជា ត្រូវបានធ្វើឡើងតាមរយៈការរួមបញ្ចូលគ្នានៃវិធីសាស្ត្រពីរ គឺ«ពីលើចុះក្រោម» និង «ពីក្រោមឡើងលើ»៖

**វិធីសាស្ត្រ«ពីលើចុះពីក្រោម»៖** ជារៀងរាល់ឆ្នាំ អាជ្ញាធរមីនរៀបចំបញ្ជីឈ្មោះឃុំជាអាទិភាព ដោយផ្អែកលើចំនួនគ្រោះថ្នាក់ដោយសារមីននិងស.ផ.ស.ក្នុងរយៈពេល ៥ឆ្នាំចុងក្រោយ និងទិន្នន័យពីការស្រាវជ្រាវចម្ការមីនមូលដ្ឋាន អនុលោមតាមគោលការណ៍ណែនាំស្តីពីការធ្វើផែនការ និងការចាត់អាទិភាព។ យ៉ាងហោចណាស់ចំនួន ៧៥% នៃធនធាននិងមូលនិធិសម្រាប់សកម្មភាពមីន ត្រូវធ្វើការបែងចែកសម្រាប់ឃុំជាអាទិភាពដែលបានកំណត់ដោយអាជ្ញាធរមីន ហើយនៅសល់ ២៥%ទៀត ទុកសម្រាប់ដោះស្រាយតម្រូវការបោសសម្អាតនៅក្រៅតំបន់អាទិភាព តាមរយៈដំណើរការរបស់អង្គភាពធ្វើផែនការសកម្មភាព កំចាត់មីន។

**វិធីសាស្ត្រ«ពីក្រោមឡើងលើ»៖** នៅក្នុងបណ្តាឃុំអាទិភាពដែលផ្តល់ដោយអាជ្ញាធរមីន អង្គភាពធ្វើផែនការសកម្មភាពកម្ចាត់មីនធ្វើការសម្របសម្រួលនៅកម្រិតថ្នាក់ក្រោមជាតិ ដើម្បីបង្កើតបញ្ជីចម្ការមីនដែលជាអាទិភាពត្រូវធ្វើការបោសសម្អាតមីន សម្រាប់ដាក់ស្នើសុំការអនុម័តពីគណៈកម្មាធិការសកម្មភាពកម្ចាត់មីនរាជធានី ខេត្ត និងការយល់ព្រមពីអាជ្ញាធរមីន។ ដំណើរការនេះត្រូវបានរៀបចំឡើងដើម្បីឱ្យមានតម្លាភាព និងមានការចូលរួមតាមបែបរិមជ្ឈការនិងផ្អែកលើសហគមន៍នីមួយៗ។ តាមរយៈដំណើរការនេះ ការធ្វើផែនការបោសសម្អាតមីនគ្រោងនឹងត្រូវបញ្ចូលទៅក្នុងផែនការវិនិយោគឃុំ-សង្កាត់ប្រកបដោយប្រសិទ្ធភាព។ លក្ខណៈវិនិច្ឆ័យនៃវិធីសាស្ត្រ «ពីក្រោមឡើងលើ»នាពេលបច្ចុប្បន្ននេះ រួមមាន៖ កម្រិតនៃការភ័យខ្លាច តម្រូវការនៃការអភិវឌ្ឍ អ្នកទទួលផលដែលបានកំណត់។

តទៅមុខទៀត ការធ្វើផែនការនិងការចាត់អាទិភាពនឹងត្រូវបានពិនិត្យមើលឡើងវិញ និងកែលម្អដើម្បីឆ្លើយតបប្រកបដោយប្រសិទ្ធភាពចំពោះស្ថានភាពផ្លាស់ប្តូរនៃបញ្ហាមីន ខណៈដែលត្រូវធានាផងដែរថា ការបែងចែកធនធានប្រកបដោយប្រសិទ្ធភាព សម្រាប់បណ្តាភូមិដែលត្រូវការបំផុតមុនគេ។ ដំណើរការនៃអង្គភាពធ្វើផែនការសកម្មភាពកម្ចាត់មីន នឹងនៅតែបន្តដើរតួនាទីសំខាន់នៅក្នុងការធ្វើផែនការនិងចាត់អាទិភាពនៃការបោសសម្អាតមីន។ ដើម្បីកំណត់ភូមិអាទិភាព វិស័យនេះនឹងប្រើលក្ខណៈវិនិច្ឆ័យសម្រាប់ការចាត់អាទិភាពតាមវិធីសាស្ត្រពីលើចុះក្រោម ផ្អែកលើកត្តាមួយចំនួន ដូចជា៖ ដង់ស៊ីតេមីនខ្ពស់ ចំនួនគ្រោះថ្នាក់ ទីតាំងនៃចំណុចដែលមានការគំរាមកំហែងស្ថិតនៅជិតប្រជាជន និងផលប៉ះពាល់សេដ្ឋកិច្ចសង្គមខ្ពស់ (តាមឯកសាររបស់អង្គភាពធ្វើផែនការសកម្មភាពកម្ចាត់មីន)។ ចំពោះលក្ខណៈវិនិច្ឆ័យសម្រាប់ការកំណត់អាទិភាពតាមវិធីសាស្ត្រពីក្រោមឡើងលើ នឹងផ្តោតការយកចិត្តទុកដាក់ទៅលើការបោសសម្អាតចម្ការមីន ដោយផ្អែកលើ៖ កម្រិតនៃការភ័យខ្លាច ការរងគ្រោះ តម្រូវការនៃការអភិវឌ្ឍ និងការប្រើប្រាស់ដីក្រោយការបោសសម្អាត។

អាជ្ញាធរមីននឹងធ្វើការពិនិត្យមើលឡើងវិញដោយទៀតទាត់ ទៅលើការអនុវត្តក្នុងការធ្វើផែនការ និងការចាត់អាទិភាពនៃវិស័យសកម្មភាពមីន ព្រមទាំងទៅលើលក្ខណៈវិនិច្ឆ័យនានាដើម្បីឆ្លើយតបទៅនឹងស្ថានភាពមីនដែលកំពុងវិវត្ត ហើយធានាថាវិស័យនេះនឹងបញ្ចប់ការបោសសម្អាតចម្ការមីនទាំងអស់ដែលបានកំណត់រួចហើយ

ឱ្យបចរាល់ជាស្ថាពរនៅត្រឹមឆ្នាំ២០២៥។ លក្ខណៈវិនិច្ឆ័យដែលលេចឡើងថ្មី នឹងត្រូវបានប្រើប្រាស់សម្រាប់ដំណើរការនៃវិធីសាស្ត្រពីលើចុះក្រោម និងវិធីសាស្ត្រពីក្រោមឡើងលើ។

## គ. និយ័តកម្ម និងការតាមដានត្រួតពិនិត្យ

និយ័តកម្មនិងការតាមដានត្រួតពិនិត្យ គឺជាផ្នែកដ៏សំខាន់នៃការគ្រប់គ្រងវិស័យទាំងមូលនៃរាល់ប្រតិបត្តិការនៅក្នុងសកម្មភាពមីនដែលប្រកបដោយប្រសិទ្ធភាព ហើយគឺជាអាណត្តិរបស់អាជ្ញាធរមីនដែលត្រូវលើកស្ទួយ និងថែរក្សាឱ្យមាននិរន្តរភាព។ និយ័តកម្មនិងការតាមដានត្រួតពិនិត្យ ជួយសម្រួលដល់ការអនុលោមទៅតាមច្បាប់ បទប្បញ្ញត្តិ និងនីតិវិធីស្តង់ដារដែលបានដាក់ចេញដោយអាជ្ញាធរមីន ដើម្បីធានាថាប្រតិបត្តិការសកម្មភាពមីនមានភាពស្របច្បាប់ មានប្រសិទ្ធភាព ប្រសិទ្ធផល និងសុវត្ថិភាព ក៏ដូចជាបំពេញបន្ថែមទៅលើគោលនយោបាយយុទ្ធសាស្ត្រ និងអាទិភាពជាតិដែលបានបង្កើតឡើង។ ការងារនេះរួមមានការផ្តល់អាជ្ញាប័ណ្ណដល់ប្រតិបត្តិករ និងការតាមដានត្រួតពិនិត្យ និងរាយការណ៍អំពីការអនុវត្តរបស់ពួកគេធៀបទៅនឹងស្តង់ដារនិងគោលការណ៍ណែនាំថ្នាក់ជាតិ។ ការធ្វើនិយ័តកម្មនិងការដានត្រួតពិនិត្យដែលមានលក្ខណៈប្រសើរឡើងនិងជាប់ជាប្រចាំ នឹងធ្វើឱ្យការអនុវត្តវិធីសាស្ត្ររំដោះផ្ទៃដីដំណើរការបានល្អប្រសើរបំផុត ក្នុងការគាំទ្រដល់គោលដៅនិងគោលបំណងនៃផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីននេះ។

## ឃ. ការរំដោះផ្ទៃដី

ពាក្យ «ការរំដោះផ្ទៃដី» ពិពណ៌នាអំពីដំណើរការនៃការផ្ទេរផ្ទៃដីដែលសង្ស័យ ឬផ្ទៃដីដែលមានការគំរាមកំហែងកន្លងមកទៅជាផ្ទៃដីដែលបញ្ចប់ការគំរាមកំហែង ហើយដែលប្រជាពលរដ្ឋឬអាជ្ញាធរមូលដ្ឋានជឿជាក់ថាអាចប្រើប្រាស់ផ្ទៃដីទាំងនោះបានដោយគ្មានការបារម្ភពីគ្រោះថ្នាក់។ គោលនយោបាយរំដោះផ្ទៃដីត្រូវបានរៀបចំឡើងដើម្បីកំណត់គោលដៅនៃការប្រើប្រាស់ធនធានដែលមាន សំដៅឆ្ពោះទៅតំបន់ដែលមានតម្រូវការខ្លាំង តាមរយៈការកំណត់ឱ្យបានច្បាស់នូវស្ថានភាពជាក់ស្តែងនៃវត្តមានមីន។ គោលនយោបាយនិងស្តង់ដារស្តីពីការរំដោះផ្ទៃដីអាចត្រូវបានធ្វើការកែលម្អឱ្យដល់កម្រិតមួយ ដែលមានការឯកភាពពីគ្រប់ប្រតិបត្តិករដែលមានអាជ្ញាប័ណ្ណ។ រាល់ប្រតិបត្តិករត្រូវអនុវត្តសកម្មភាពរំដោះផ្ទៃដីដោយមានការចូលរួមយ៉ាងសកម្មពីសហគមន៍ ឬអ្នកប្រើប្រាស់ដីព្រមទាំងភាគីពាក់ព័ន្ធផ្សេងៗទៀតក្នុងសកម្មភាពមីននៅតាមសហគមន៍ផងដែរ។

ដើម្បីធ្វើការកែលម្អលើប្រសិទ្ធភាពការងាររបស់ប្រតិបត្តិការនានា គួរធ្វើការពិចារណាលើចំណុចដូចខាងក្រោម៖

- ការស្រាវជ្រាវមិនបច្ចេកទេសដែលអាចជឿជាក់បាន គឺជាគន្លឹះឆ្ពោះទៅកាន់ដំណើរការប្រកបដោយប្រសិទ្ធភាព។ គោលការណ៍ការណែនាំស្តីពីការប្រើប្រាស់បច្ចេកទេសរំដោះផ្ទៃដីនៅតាមតំបន់ដែលមានមីននិងស.ផ.ស. គួរត្រូវបានសម្រេចឡើងតាមរយៈការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃការលុបចោលផ្ទៃដីសង្ស័យ ការកាត់បន្ថយផ្ទៃដីសង្ស័យ និងការបោសសម្អាត។
- ជៀសវាងការដាក់ពង្រាយធនធានបោសសម្អាតទាំងស្រុងនៅតំបន់សង្ស័យ ខណៈដែលលទ្ធភាពទទួលបានព័ត៌មានគ្រប់គ្រាន់អាចធ្វើទៅបាន។

- ដើម្បីសន្សំសំចៃធនធាននិងពេលវេលា ត្រូវបង្កើនការខិតខំប្រឹងប្រែងឱ្យបានខ្លាំងបន្ថែមទៀតទៅលើសកម្មភាពទាំងឡាយណាដែលមានចំណាយទាប ឧទាហរណ៍ ត្រូវផ្ដោតការយកចិត្តទុកដាក់ទៅលើការវិភាគនិងការអង្កេតឱ្យបានត្រឹមត្រូវ ដើម្បីទទួលបានព័ត៌មានច្បាស់លាស់ពាក់ព័ន្ធនឹងកន្លែងដែលមានវត្តមានមីន នៅមុនពេលអនុវត្តសកម្មភាពដែលមានចំណាយខ្ពស់បំផុត។
- គោលការណ៍ណែនាំច្បាស់លាស់អំពីហានិភ័យនិងការទទួលខុសត្រូវ គួរត្រូវបានរៀបចំឡើងដើម្បីជួយដល់អាជ្ញាធរជាតិ និងប្រតិបត្តិករទាំងអស់ ឱ្យមានទំនុកចិត្តនិងរក្សាការចូលរួមយ៉ាងសកម្មពីសហគមន៍ ជាពិសេសទាក់ទងនឹងការលុបចោលផ្ទៃដីសង្ស័យ។

## ង. ការអប់រំកាត់បន្ថយគ្រោះថ្នាក់មីននិងស.ផ.ស.

ការអប់រំកាត់បន្ថយគ្រោះថ្នាក់មីន/ស.ផ.ស. នៅតែជាសមាសភាគដ៏សំខាន់មួយដើម្បីសម្រេចបាននូវគោលដៅរបស់ផែនការយុទ្ធសាស្ត្រនេះ ក្នុងការកាត់បន្ថយគ្រោះថ្នាក់និងផលប៉ះពាល់អវិជ្ជមានដោយសារមីននិងស.ផ.ស.លើសហគមន៍។ ការអប់រំកាត់បន្ថយគ្រោះថ្នាក់មីន/ស.ផ.ស. ត្រូវបានអនុវត្តនៅក្នុងប្រទេសកម្ពុជាតាំងពីឆ្នាំ១៩៩៣មកម្ល៉េះ។ គោលបំណងសំខាន់នៃការអប់រំអំពីហានិភ័យដោយសារមីន គឺដើម្បីកាត់បន្ថយការប្រព្រឹត្តដែលមានហានិភ័យខ្ពស់របស់អ្នកដែលរស់នៅ ឬធ្វើការនៅក្នុងតំបន់ដែលរងគ្រោះដោយសារមីននិងស.ផ.ស.។

អាជ្ញាធរមីនសម្របសម្រួលសកម្មភាពអប់រំកាត់បន្ថយគ្រោះថ្នាក់មីន/ស.ផ.ស. និងពង្រឹងការផ្ញើសារអំពីហានិភ័យដោយសារមីនទៅដល់ក្រុមគោលដៅ។ កម្មវិធីអប់រំអំពីហានិភ័យដោយសារមីន ត្រូវបានធ្វើឡើងដោយប្រតិបត្តិករដោះមីនជាច្រើនដែលមានការទទួលស្គាល់ជាផ្លូវការដោយក្រសួងអប់រំ យុវជន និងកីឡា និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនទៀត។ សារអប់រំអំពីហានិភ័យដោយសារមីននិងសម្ភារអប់រំ រួមមានអាវយឺត ខិត្តប័ណ្ណ សៀវភៅដែលមានសារអប់រំអំពីគ្រោះថ្នាក់ និងលេខទូរសព្ទទំនាក់ទំនងរបស់នគរបាលនិងប្រតិបត្តិករនានា ត្រូវបានបង្កើតឡើងដើម្បីជួយសម្រួលដល់ការរាយការណ៍ នៅពេលដែលប្រជាជនបានប្រទះឃើញមីននិងស.ផ.ស.។

ផ្អែកលើវិធានការនៃកម្មវិធីអប់រំប្រកបដោយជោគជ័យអំពីហានិភ័យដោយសារមីន កាលពីបណ្ដាឆ្នាំមុនៗកន្លងមក ការពិចារណាគួរផ្ដោតលើក្រុមស្រាវជ្រាវចម្ការមីនមូលដ្ឋាន ក្នុងការផ្ដល់ព័ត៌មានស្ដីពីកម្មវិធីអប់រំអំពីហានិភ័យដោយសារមីន។ វិធីសាស្ត្រផ្អែកលើសហគមន៍និងការឆ្លើយតបតាមតម្រូវការជាក់ស្ដែងនីមួយៗ ក៏នឹងត្រូវបានលើកយកមកពិចារណាផងដែរ។ កម្មវិធីអប់រំកាត់បន្ថយគ្រោះថ្នាក់មីននិងស.ផ.ស. នឹងកំណត់យកជាគោលដៅសំខាន់នៅតំបន់ដែលមានហានិភ័យខ្ពស់ ដូចជាកុមារ មនុស្សពេញវ័យដែលផ្លាស់ទីច្រើន និងប្រជាជនក្រីក្រ ដើម្បីការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាពខ្ពស់។

## ច. កិច្ចជួយសង្គ្រោះជនរងគ្រោះ

ជំនួយគាំទ្រដល់ជនរងគ្រោះ គឺជាផ្នែកមួយនៃវិស័យពិការភាពនិងស្ដារលទ្ធភាពពលកម្មកាយសម្បទាដ៏ទូលំទូលាយដែលត្រូវបានប្រគល់ទៅឱ្យក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីផ្ដល់សេវាស្ដារលទ្ធភាពពលកម្មកាយសម្បទា និងសមាហរណកម្មក្នុងសង្គមឡើងវិញ ដល់មនុស្សពិការទាំងអស់នៅកម្ពុជា។ ក្នុងនាមជារដ្ឋភាគីនៃអ.ហ.ផ.ម. អាជ្ញាធរមីនមានកាតព្វកិច្ចតំណាងប្រទេសកម្ពុជា ដើម្បីផ្ដល់របាយការណ៍អំពី

បច្ចុប្បន្នភាពនិងវឌ្ឍនភាពជាទៀងទាត់ ពាក់ព័ន្ធនឹងជំនួយគាំទ្រដល់ជនរងគ្រោះដែលជាសសរស្តម្ភមួយក្នុងចំណោមសសរស្តម្ភទាំង៥ នៃសកម្មភាពមីន។

នៅក្នុងក្របខ័ណ្ឌអន្តរជាតិពាក់ព័ន្ធនឹងជនពិការ កម្ពុជាបានអនុម័តអនុសញ្ញាហាមប្រាមការប្រើប្រាស់មីនប្រឆាំងមនុស្ស និងអនុសញ្ញាស្តីពីសិទ្ធិជនពិការ។ នៅក្នុងកម្រិតជាតិវិញ កម្ពុជាមានក្របខ័ណ្ឌច្បាប់និងគោលនយោបាយទូលំទូលាយដើម្បីធានាសិទ្ធិ និងដោះស្រាយសេចក្តីត្រូវការរបស់ជនពិការ។

ការធ្វើឱ្យប្រសើរឡើងនូវជីវភាពរស់នៅរបស់ជនពិការនៅក្នុងសហគមន៍ គឺជាសកម្មភាពស្នូលដ៏សំខាន់នៃកម្មវិធីជំនួយគាំទ្រដល់ជនរងគ្រោះ។ សហគមន៍នៅក្នុងភូមិនីមួយៗនឹងត្រូវបានលើកទឹកចិត្តយ៉ាងខ្លាំង ឱ្យធ្វើការប្រាស្រ័យទាក់ទងជាមួយអ្នករស់រានមានជីវិតពីគ្រោះថ្នាក់ដោយសារមីននិងស.ផ.ស. និងជនពិការផ្សេងៗទៀតដោយការគោរព ទទួលស្គាល់នូវសមត្ថភាពរបស់ពួកគេ លើកកម្ពស់សិទ្ធិ និងឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ពួកគេ។

អាជ្ញាធរមីននឹងបន្តលើកកម្ពស់សិទ្ធិរបស់អ្នករស់រានមានជីវិតពីគ្រោះថ្នាក់ដោយសារមីននិងស.ផ.ស. ដោយពង្រីកការសិក្សាពីគុណតម្លៃនៃជីវិតរបស់ពួកគេ(QLS) តាមរយៈការពង្រឹងនិងពង្រីកបណ្តាញអ្នករស់រានមានជីវិតឱ្យបានទៅដល់តំបន់ដាច់ស្រយាលនិងជនបទ ដែលជួបការលំបាកក្នុងការទទួលសេវា។

អាជ្ញាធរមីននឹងចូលរួមនៅក្នុងយន្តការសម្របសម្រួលថ្នាក់ជាតិ ជាមួយក្រសួងសុខាភិបាល ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រុមប្រឹក្សាសកម្មភាពជនពិការ មូលនិធិជនពិការ និងមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទា ស្ថាប័ននិងអង្គការពាក់ព័ន្ធនឹងពិការភាព ដើម្បីធានាថា ជំនួយសង្គ្រោះបន្ទាន់ត្រូវបានផ្តល់ជូន ហើយសិទ្ធិនិងសេចក្តីត្រូវការរបស់អ្នករស់រានមានជីវិតកំពុងត្រូវបានដោះស្រាយនៅក្នុងបរិបទទូលំទូលាយនៃពិការភាព។

តួនាទីដ៏សំខាន់មួយទៀតដែលត្រូវធ្វើនៅក្នុងយុទ្ធសាស្ត្រថ្មីនេះ គឺបន្តការប្រមូលទិន្នន័យដែលមានការបែងចែកទៅតាមប្រភេទផ្សេងៗ ស្តីពីអ្នករស់រានមានជីវិតដែលទទួលបានសេវាពីអ្នកផ្តល់សេវាពាក់ព័ន្ធនានា។ ទិន្នន័យគ្រប់គ្រាន់និងត្រឹមត្រូវអាចជួយដល់បណ្តាភាគីពាក់ព័ន្ធនឹងជនពិការទាំងអស់ ដើម្បីបញ្ចៀសការអនុវត្តភារកិច្ចស្ទួនគ្នា និងធ្វើការបែងចែកធនធានឱ្យមានប្រសិទ្ធភាពនិងប្រសិទ្ធផល។

## ឆ. ការគ្រប់គ្រងព័ត៌មាន

ការគ្រប់គ្រងព័ត៌មានត្រូវបានដាក់បញ្ចូលទៅក្នុងគ្រប់ផ្នែកទាំងអស់នៃសកម្មភាពមីន និងដើរតួនាទីយ៉ាងសំខាន់ក្នុងការកំណត់អាទិភាពប្រកបដោយប្រសិទ្ធភាពនិងប្រសិទ្ធផល ការធ្វើផែនការនិងការអនុវត្តរាល់សកម្មភាពជាតិក្នុងការបោសសម្អាតមីន។ ទិន្នន័យពេញលេញ ត្រឹមត្រូវ ទាន់ពេលវេលា និងមានសង្គតិភាព ពិតជាមានសារៈសំខាន់ណាស់ក្នុងការគាំទ្រដល់ការធ្វើសេចក្តីសម្រេចចិត្តនៅថ្នាក់ជាតិនិងថ្នាក់ខេត្ត។ មូលដ្ឋានទិន្នន័យជាតិគឺជាធនាគារទិន្នន័យចម្បងអំពីរាល់កម្មវិធីសកម្មភាពមីនទាំងអស់នៅក្នុងកម្ពុជា ហើយត្រូវបានគ្រប់គ្រងដោយអង្គភាពទិន្នន័យនៃអាជ្ញាធរមីន។ អង្គភាពទិន្នន័យទទួលខុសត្រូវក្នុងការប្រមូល រក្សាទុក វិភាគ និងផ្សព្វផ្សាយទិន្នន័យដែលគាំទ្រដល់ការធ្វើផែនការនិងការចាត់អាទិភាព និងសកម្មភាពបោសសម្អាតមីនទាំងអស់។ ទិន្នន័យទាំងនេះរួមមាន៖ ការស្រាវជ្រាវចម្ការមីនមូលដ្ឋាន ការរំដោះផ្ទៃដី គ្រោះថ្នាក់និងជនរងគ្រោះ កិច្ចជួយសង្គ្រោះ

ជនរងគ្រោះ ការអប់រំកាត់បន្ថយគ្រោះថ្នាក់មីននិងស.ផ.ស. ការពិនិត្យផ្ទៃដីចម្ការមីននិងស.ផ.ស.បោសសម្អាតរួច ការបំផ្លាញគ្រាប់យុទ្ធភណ្ឌមិនទាន់ផ្ទុះ ប្រព័ន្ធត្រួតពិនិត្យសកម្មភាពមីន និងការគ្រប់គ្រងគុណភាព។

យុទ្ធសាស្ត្រគ្រប់គ្រងព័ត៌មានរបស់ផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន មានគោលបំណងធានាឱ្យមានព័ត៌មានស្តីពីសកម្មភាពមីនប្រកបដោយសង្គតិភាព ហើយសមត្ថភាពគ្រប់គ្រងព័ត៌មានត្រូវបានថែរក្សា និងធ្វើការកែលម្អតាមរយៈការប្រើប្រាស់បច្ចេកវិទ្យាថ្មីកាន់តែច្រើន។ យន្តការរាយការណ៍ដែលត្រូវបានកែលម្អរួច នឹងអាចឱ្យប្រទេសកម្ពុជាបង្ហាញនូវវឌ្ឍនភាព និងសមិទ្ធផលវិជ្ជមាននានារបស់ខ្លួន ធៀបទៅនឹងគោលដៅជាយុទ្ធសាស្ត្រនៅក្នុងផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន។

## ជ. យេនឌ័រ និងនិរន្តរភាពបរិស្ថាន

គោលការណ៍ណែនាំផ្នែកយេនឌ័រសម្រាប់កម្មវិធីសកម្មភាពមីន ដែលត្រូវបានកសាងឡើងដោយអង្គការសហប្រជាជាតិមុនឆ្នាំ២០១០ បានបង្ហាញថា ការបញ្ជ្រាបយេនឌ័រនៅក្នុងសកម្មភាពមីននាំឱ្យមានលទ្ធផលល្អប្រសើរនៅក្នុងសកម្មភាពមីន។ ជាពិសេស ការបញ្ជ្រាបយេនឌ័រនឹងផ្តល់សេវាល្អប្រសើរជាងមុនដល់អ្នកទទួលផលទាំងអស់នៅក្នុងសហគមន៍ ធានាថាសកម្មភាពមីនមានផលប៉ះពាល់ជាវិជ្ជមានសម្រាប់ស្ត្រី កុមារី កុមារ និងបុរស ហើយធានាថាពួកគេមានលទ្ធភាពកាន់តែប្រសើរក្នុងការដើរតួនាទីជាអ្នកធ្វើសេចក្តីសម្រេចចិត្តទាក់ទងនឹងការចាត់អាទិភាពនៃសកម្មភាពមីន។

ក្រុមការងារបញ្ជ្រាបយេនឌ័ររបស់អាជ្ញាធរមីន (GMT) ត្រូវបានបង្កើតឡើងដើម្បីសម្របសម្រួលជាមួយក្រុមការងារបច្ចេកទេសយេនឌ័រ(TRGG) ដែលជាក្រុមការងារបច្ចេកទេសមួយ ក្នុងចំណោមក្រុមការងារបច្ចេកទេសទាំង៥ ក្នុងការធានាដល់ការសម្របសម្រួលនៃវិស័យនេះ។ TRGG កំពុងមានដំណើរការ និងមានសមាសភាពតំណាងមកពី UNDP ក្រសួងកិច្ចការនារី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អង្គភាពធ្វើផែនការកម្ចាត់មីន(MAPU) ប្រតិបត្តិករនានា ក៏ដូចជាអង្គការជាតិនិងអន្តរជាតិដែលបំពេញការងារពាក់ព័ន្ធនឹងផ្នែកកិច្ចជួយសង្គ្រោះជនរងគ្រោះ និងការអប់រំកាត់បន្ថយគ្រោះថ្នាក់មីន/ស.ផ.ស.។

ផ.យ.ជ.ម. ២០១៨-២០២៥នេះ នឹងដោះស្រាយបញ្ហាប្រឈមនានាដែលបានចង្អុលបង្ហាញដោយរបាយការណ៍នៃការវាយតម្លៃលើផែនការបញ្ជ្រាបយេនឌ័រក្នុងសកម្មភាពមីនឆ្នាំ២០១៦ និងការពិនិត្យឡើងវិញអំពីវិស័យសកម្មភាពមីនឆ្នាំ២០១៦។ វាមានគោលបំណងពង្រឹងការធ្វើផែនការ និងការអនុវត្តនៃការងារបញ្ជ្រាបយេនឌ័រប្រកបដោយប្រសិទ្ធភាពនៅក្នុងគ្រប់ទិដ្ឋភាពទាំងអស់នៃវិស័យសកម្មភាពមីននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

## ឈ. ការអភិវឌ្ឍសមត្ថភាព

ការកែលម្អជាបន្តបន្ទាប់លើសមត្ថភាព ជានិច្ចកាលគឺជាអាទិភាពមួយ ហើយនឹងត្រូវថែរក្សាឱ្យបាន។ កម្ពុជាត្រូវការអ្នកបច្ចេកទេសនិងអ្នកគ្រប់គ្រងដ៏ល្អបំផុតលំដាប់ពិភពលោក។ ការស្រាវជ្រាវនិងការអភិវឌ្ឍការប្រើប្រាស់ឧបករណ៍ សម្ភារ និងជំនាញបោសសម្អាតមីនសមស្រប ការចងក្រងឯកសារបានល្អប្រសើរ ការប្រមូលនិងរៀបចំទិន្នន័យបានកាន់តែល្អប្រសើរនិងទាន់ពេលវេលា ការគ្រប់គ្រងព័ត៌មាន ការបញ្ជ្រាបយេនឌ័រ ការអប់រំអំពីហានិភ័យដោយសារមីន ការផ្តល់ជំនួយគាំទ្រដល់ជនរងគ្រោះ ការធ្វើផែនការ និងការចាត់អាទិភាពសម្រាប់

ការងារបោសសម្អាតមីននិងស.ផ.ស. ការគ្រប់គ្រងគុណភាព និងការគ្រប់គ្រងវិស័យនេះទាំងមូលសុទ្ធសឹងតែមានសារៈសំខាន់។

ការកសាងសមត្ថភាពជាបន្តបន្ទាប់ដែលត្រូវបានធ្វើឡើងដោយអ្នកជំនាញការជាតិ តំបន់ និងអន្តរជាតិនៅក្នុងវិស័យទាំងនេះ នៅតែមានសារៈសំខាន់ក្នុងការជួយដល់សហគមន៍សកម្មភាពមីននៅកម្ពុជា ឱ្យសម្រេចបានសមិទ្ធផលកាន់តែច្រើនថែមទៀត ដោយប្រើប្រាស់ធនធានកាន់តែតិចជាងមុន។ ចំណេះដឹងជាក់ស្តែងដែលទទួលបានពីការងារអនុវត្តផ្ទាល់ ក៏បានធ្វើឱ្យអ្នកជំនាញកម្ពុជាបង្កើនទំនុកចិត្តរបស់ខ្លួន ក្នុងការចែករំលែកជំនាញរបស់ពួកគេជាមួយអ្នកអនុវត្តផ្សេងៗទៀតនៅក្នុងបណ្តាប្រទេសដែលរងផលប៉ះពាល់ដោយមីននិងស.ផ.ស.។

ប្រការនេះរួមបញ្ចូលនូវការកសាងស្មារតីកិច្ចសហប្រតិបត្តិការ ឱ្យកាន់តែរឹងមាំក្នុងចំណោមប្រតិបត្តិការសកម្មភាពមីនទាំងអស់ ដើម្បីចែករំលែកចំណេះដឹងតាមរយៈកិច្ចសហប្រតិបត្តិការត្បូង-ត្បូង។ សមត្ថភាពនឹងត្រូវបានពង្រឹងតាមរយៈទំនាក់ទំនងរឹងមាំជាមួយដៃគូក្នុងតំបន់និងអន្តរជាតិ ការផ្លាស់ប្តូរបទពិសោធន៍និងកិច្ចសហប្រតិបត្តិការ។

## ៣. និសញ្ញាវុធការក្នុងតំបន់និងអន្តរជាតិ

នៅលើឆាកអន្តរជាតិ ប្រទេសកម្ពុជាជាប្រទេសមួយដែលមានការទទួលខុសត្រូវនិងមានការប្តេជ្ញាចិត្តចំពោះវិស័យសកម្មភាពកម្ចាត់មីនលក្ខណៈមនុស្សធម៌ និងជាប្រទេសហត្ថលេខីនៃអ.ហ.ផ.ម. អនុសញ្ញាសញ្ញាវុធធម្មតាមួយចំនួន (ពិធីសារផ្សេងៗជាច្រើន) និងជាអ្នកសង្កេតការណ៍នៃអនុសញ្ញាស្តីពីគ្រាប់បែកចង្កោម។ ដូចដែលបានលើកឡើងខាងលើ កម្ពុជាប្តេជ្ញាបំពេញកាតព្វកិច្ចរបស់ខ្លួនតាមអនុសញ្ញាផ្សេងៗ ព្រមទាំងចូលរួមអនុវត្តទៅតាមអនុសញ្ញានានាដោយសុឆន្ទៈ ទោះបីប្រទេសកម្ពុជាមិនទាន់ក្លាយជាប្រទេសហត្ថលេខីក៏ដោយ។

កម្ពុជាបានចូលរួមយ៉ាងសកម្មក្នុងប្រតិបត្តិការរក្សាសន្តិភាព និងបោសសម្អាតមីនជាអន្តរជាតិក្រោមឆ័ត្ររបស់អង្គការសហប្រជាជាតិ។ ក្នុងស្មារតីនៃកិច្ចសហប្រតិបត្តិការ កម្ពុជានឹងបន្តចូលរួមក្នុងគំនិតផ្តួចផ្តើមស្តីពីការកសាងសមត្ថភាពក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការត្បូង-ត្បូង។ ប្រការនេះអាចរួមបញ្ចូលនូវកម្មវិធីផ្លាស់ប្តូរបទពិសោធន៍ទៅវិញទៅមក ដើម្បីផ្តល់ការបណ្តុះបណ្តាលទទួលធ្វើជាម្ចាស់រៀបចំទស្សនកិច្ចសិក្សា និងផ្តល់ព័ត៌មានអំពីស្ថាប័ននិងគោលនយោបាយ ជាមួយអង្គការសកម្មភាពកម្ចាត់មីនផ្សេងៗទៀតទាំងក្នុងតំបន់ និងនៅលើពិភពលោក។ កម្ពុជានឹងបន្តធ្វើសកម្មភាពដោយសុឆន្ទៈ និងស្របតាមឧត្តមប្រយោជន៍ជាតិ នៅក្នុងកិច្ចខិតខំប្រឹងប្រែងបោសសម្អាតមីនដែលបម្រើឱ្យកិច្ចការបោះបង្គោលព្រំដែន និងការដោះស្រាយបញ្ហាព្រំដែនដែលនៅសេសសល់ ដើម្បីជានាស្ថិរភាពក្នុងតំបន់។

ស្របទៅតាមសមត្ថភាពដែលខ្លួនមាន កម្ពុជានឹងបន្តជួយគាំទ្រដល់សកម្មភាពមីននិងគំនិតផ្តួចផ្តើមនិសញ្ញាវុធការនានាដែលធ្វើឡើងដើម្បីជំរុញស្ថិរភាពក្នុងតំបន់ និងអន្តរជាតិ។

កម្ពុជាមានការប្តេជ្ញាចិត្តយ៉ាងម៉ឺងម៉ាត់ ចំពោះកិច្ចសហប្រតិបត្តិការក្នុងតំបន់និងអន្តរជាតិ ហើយនឹងបន្តចូលរួមក្នុងការអនុវត្តគោលនយោបាយនានារបស់ខ្លួននាពេលបច្ចុប្បន្ននេះតទៅមុខទៀត។

# ៩. យន្តការសម្របសម្រួល

## ក្រុមការងារបច្ចេកទេសចម្រុះរាជរដ្ឋាភិបាល-ដៃគូអភិវឌ្ឍ លើវិស័យមីន (ក.ប.ម.)

ក.ប.ម. ដែលដឹកនាំដោយអាជ្ញាធរមីន គឺជាយន្តការពិគ្រោះយោបល់មួយ រវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ដើម្បីពិភាក្សាអំពីបញ្ហាគោលនយោបាយនានា ក្នុងគោលបំណងធ្វើឱ្យការងារសម្របសម្រួលជាទូទៅមានភាពកាន់តែប្រសើរឡើង លើកកម្ពស់ការតម្រែតម្រង់ទិសឱ្យស៊ីសង្វាក់គ្នា និងសុខដុមនីយកម្មនៃជំនួយសម្រាប់វិស័យសកម្មភាពមីនទាំងមូល។ បេសកកម្មរបស់ ក.ប.ម. គឺដើម្បីគាំទ្រតួនាទីឈានមុខរបស់រាជរដ្ឋាភិបាលក្នុងការសម្របសម្រួលលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាល ក្រុមការងារបច្ចេកទេសចម្រុះពីវិស័យផ្សេងៗ ព្រមទាំងធនធាន និងសកម្មភាពដែលអនុវត្តដោយដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល និងជំរុញប្រសិទ្ធភាពជំនួយ ស្របតាមសេចក្តីប្រកាសរបស់ប្រទេសកម្ពុជាស្តីពីការបង្កើនប្រសិទ្ធភាពជំនួយ និងផែនការសកម្មភាពរបស់រាជរដ្ឋាភិបាលស្តីពីសុខដុមនីយកម្ម ការតម្រែតម្រង់ទិសឱ្យស៊ីសង្វាក់គ្នា និងលទ្ធផល។ ក.ប.ម. មានអនុប្រធានទី១ អាជ្ញាធរមីនជាប្រធាននៃក្រុមការងារនេះ មានគោលបំណងជួបប្រជុំយ៉ាងហោចណាស់ឱ្យបានពីរដងក្នុងមួយឆ្នាំ។

## គណៈកម្មាធិការសម្របសម្រួលសកម្មភាពកម្ចាត់មីន (MACC)

ប្រសិទ្ធភាពនិងប្រសិទ្ធផលនៃសកម្មភាពមីន ភាគច្រើនអាស្រ័យទៅលើការសម្របសម្រួលបានល្អប្រសើរក្រោមការដឹកនាំរបស់អាជ្ញាធរជាតិ ពោលគឺអាជ្ញាធរមីន។ ដើម្បីសម្រេចការងារនេះ អាជ្ញាធរមីនបានបង្កើតគណៈកម្មាធិការសម្របសម្រួលសកម្មភាពកម្ចាត់មីន ដែលបានជួបប្រជុំយ៉ាងទៀងទាត់ជាច្រើនលើកជារៀងរាល់ឆ្នាំ។ យន្តការគណៈកម្មាធិការសម្របសម្រួលសកម្មភាពកម្ចាត់មីននេះមិនត្រូវបានប្រើប្រាស់ទេ នៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ នៅក្នុងការបោះជំហានឆ្ពោះទៅមុខរបស់ខ្លួន អាជ្ញាធរមីនមានគម្រោងដាក់ឱ្យដំណើរការឡើងវិញនូវយន្តការនេះ ដើម្បីធ្វើការសម្របសម្រួលវិស័យនេះឱ្យកាន់តែមានប្រសិទ្ធភាព។ អាជ្ញាធរមីនមានគម្រោងរៀបចំកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលសកម្មភាពកម្ចាត់មីននេះ ឱ្យបានយ៉ាងហោចណាស់បីដងក្នុងមួយឆ្នាំ។

## ក្រុមការងារបច្ចេកទេស (TRG)

នៅកម្រិតបច្ចេកទេស អាជ្ញាធរមីនបានរៀបចំឱ្យក្រុមបង្គោលបច្ចេកទេសចំនួន ៥ ដើម្បីផ្តល់ភាពងាយស្រួលក្នុងការងារសម្របសម្រួលដោះស្រាយបញ្ហាបច្ចេកទេសជាមួយគ្រប់ប្រតិបត្តិករទាំងអស់ ដែលកំពុងបំពេញភារកិច្ចក្នុងវិស័យនេះ។ ក្រុមការងារបច្ចេកទេសទាំង ៥នោះ គឺ៖ ១-ការស្រាវជ្រាវនិងបោសសម្អាតមីន ២-ការគ្រប់គ្រងព័ត៌មាន ៣-ការអប់រំកាត់បន្ថយគ្រោះថ្នាក់មីននិងស.ផ.ស. ៤-កិច្ចជួយសង្គ្រោះជនរងគ្រោះ និង ៥-យេនឌ័រ។

# ១០. និរន្តរភាព

ផ.យ.ជ.ម. ២០១៨-២០២៥ រួមបញ្ចូលនូវដំណាក់កាលអន្តរកាល និងដំណាក់កាលនៃការចាកចេញសម្រាប់កម្មវិធីជំនួយអន្តរជាតិ ការអនុវត្តនៅការបំផ្លាញចោលយុទ្ធភណ្ឌនិងការដោះស្រាយការគំរាមកំហែងផ្សេងៗដែលនៅសេសសល់។ ជាជំហានដំបូង កម្ពុជាបានកំណត់កាលបរិច្ឆេទបញ្ចប់ត្រឹមឆ្នាំ២០២៥ ដើម្បីរំដោះផ្ទៃដីដែលដឹងថាមានមីននៅក្នុងប្រទេសទាំងអស់ ស្របតាមផែនការសកម្មភាពម៉ាពុយតូ។ ផែនការយុទ្ធសាស្ត្រនេះបានកំណត់នូវគោលដៅចុងក្រោយ (ពោលគឺការអនុវត្តពេញលេញតាមមាត្រា៥ នៃ អ.ហ.ផ.ម.) សម្រាប់កម្មវិធីសកម្មភាពមីនថ្នាក់ជាតិ តាមរយៈយន្តការការងារបច្ចុប្បន្នរបស់ខ្លួន។

ការរៀបចំយន្តការការងារសម្រាប់ក្រោយឆ្នាំ២០២៥ ត្រូវបានគិតគូរជាមុន។ យុទ្ធសាស្ត្រចាកចេញជាអន្តរកាលនឹងត្រូវបានរៀបចំដោយមានការពិចារណានិងផ្អែកលើគោលការណ៍មួយចំនួនដូចខាងក្រោម៖

- ការត្រៀមខ្លួន៖ ការបង្កើត ឬការពង្រឹងជាបន្តបន្ទាប់នូវស្ថាប័នថ្មី ឬដែលមានស្រាប់ ឱ្យត្រៀមខ្លួនរួចជាស្រេចដើម្បីទទួលបន្ទុកដោះស្រាយបញ្ហាសំណល់ជាតិផ្ទុះដែលនៅសេសសល់។
- ការអនុវត្ត៖ ការចាកចេញបន្តិចម្តងៗនៃប្រតិបត្តិករអន្តរជាតិ នៅពេលដែលតំបន់មានមីនបានថយចុះ។
- ផ្ទេរភារកិច្ចក្នុងការដោះស្រាយការគំរាមកំហែងផ្សេងៗដែលនៅសេសសល់ ទៅឱ្យស្ថាប័ននិងប្រតិបត្តិករកម្ពុជា។
- ផ្ទេរទ្រព្យសម្បត្តិ បរិក្ខារ សម្ភារ និងបុគ្គលិកទៅឱ្យស្ថាប័នដែលចូលមកជំនួស។

បន្ទាប់ពីការបោសសម្អាតមីនបានបញ្ចប់ជាស្ថាពរនៅឆ្នាំ២០២៥ ហានិភ័យដែលនៅសេសសល់នឹងនៅតែមាន ពីព្រោះការបោសសម្អាតឱ្យបានទាំងស្រុងនូវរាល់បំណែកទាំងអស់នៃគ្រាប់យុទ្ធភណ្ឌ ពិតជាមិនអាចធ្វើទៅបានឡើយ។ សមត្ថភាពជាតិ គឺជាការចាំបាច់ដើម្បីដោះស្រាយបញ្ហានានាបណ្តាលមកពីគ្រាប់យុទ្ធភណ្ឌដែលបង្កជាការរំខាននៅក្នុងមូលដ្ឋាន។

ការពិនិត្យឡើងវិញនៅឆ្នាំ២០២០ អំពីក្របខ័ណ្ឌច្បាប់និងស្ថាប័នរបស់កម្ពុជា នឹងកំណត់អំពីស្ថាប័នដែលកម្ពុជាត្រូវការ ក៏ដូចជាកំណត់អំពីតួនាទីភារកិច្ចផងដែរសម្រាប់ស្ថាប័នទាំងនោះ ដើម្បីបន្តដោះស្រាយការគំរាមកំហែងដែលនៅសេសសល់។ ការពិនិត្យឡើងវិញនេះនឹងផ្តោតលើឧត្តមានុវត្តន៍នានា នៅក្នុងបណ្តាប្រទេសផ្សេងៗ។ ឆ្លើយតបទៅនឹងការពិនិត្យឡើងវិញនេះ រាជរដ្ឋាភិបាលនឹងបង្កើតឱ្យមានសមត្ថភាព និងក្របខ័ណ្ឌស្ថាប័នប្រកបដោយប្រសិទ្ធភាពនៅត្រឹមឆ្នាំ២០២១។ ដើម្បីសម្រេចគោលដៅនេះ កម្ពុជានឹងកសាងប្រព័ន្ធគ្រប់គ្រងព័ត៌មាន ដែលនឹងរួមចំណែកដល់ការចងក្រងឯកសារសមស្របអំពីហានិភ័យ និងធ្វើការដោះស្រាយបញ្ហាគំរាមកំហែងផ្សេងៗដែលនៅសេសសល់ប្រកបដោយប្រសិទ្ធភាព។

នៅត្រឹមឆ្នាំ២០២៥ កម្ពុជានឹងមានក្របខ័ណ្ឌច្បាប់ ស្ថាប័ន និងប្រតិបត្តិការ ព្រមទាំងធនធាន និងសមត្ថភាពដែលមានលក្ខណៈសមស្របសម្រាប់ដោះស្រាយការគំរាមកំហែងដែលនៅសេសសល់។ ការកំណត់ឱ្យបានច្បាស់លាស់អំពីក្របខ័ណ្ឌបែបណាមួយនោះ នៅមិនទាន់អាចធ្វើទៅបានទេ នាដំណាក់កាលនេះ។ ទោះជាយ៉ាងណា ចាំបាច់ត្រូវមានទីភ្នាក់ងារកណ្តាលដែលមានការទទួលខុសត្រូវស្នូល និងកិច្ចសហការពីអាជ្ញាធរផ្សេងៗទៀត។

## ១១. ធនធានហិរញ្ញវត្ថុ

រហូតមកដល់បច្ចុប្បន្ននេះ ភាពជាដៃគូក្នុងសកម្មភាពមីនលក្ខណៈមនុស្សធម៌នៅកម្ពុជា ពិតជាមានសារៈសំខាន់ណាស់សម្រាប់ភាពជោគជ័យនៃវិស័យនេះ និងបានដើរតួនាទីស្នូលចូលរួមចំណែកយ៉ាងធំធេងក្នុងការជួយសង្គ្រោះជីវិតប្រជាជន និងគាំទ្រដល់កំណើនសេដ្ឋកិច្ចកម្ពុជា។

កម្ពុជាបានទទួលការឧបត្ថម្ភគាំទ្រពីដៃគូអន្តរជាតិនានា ជាពិសេសប្រទេសជប៉ុន សហរដ្ឋអាមេរិក ចក្រភពអង់គ្លេស អូស្ត្រាលី សហភាពអឺរ៉ុប អាល្លឺម៉ង់ ន័រវេ៉ កាណាដា បារាំង បែលហ្ស៊ិក ដាណឺម៉ាក ហូឡង់ នូវែលហ្សេឡង់ ស្វ៊ីស ស៊ុយអែត អេស្ប៉ាញ ចិន និងអង្គការសហប្រជាជាតិ ព្រមទាំងបុគ្គលនិងអង្គការសប្បុរសធម៌នានា ក្នុងការដោះស្រាយបញ្ហាមីននិងស.ផ.ស. នៅក្នុងប្រទេសចាប់តាំងពីឆ្នាំ១៩៩២មក។

នៅក្នុងរយៈពេល ១០ឆ្នាំចុងក្រោយនេះ រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់វិភាគទានជាង ១១០លានដុល្លារអាមេរិក ដល់សកម្មភាពបោសសម្អាតមីន ដើម្បីគាំទ្រដល់គម្រោងបោសសម្អាតមីនដែលគាំទ្រការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ដូចជារោងចក្រវារីអគ្គិសនី ប្រព័ន្ធធារាសាស្ត្រ ផ្លូវថ្នល់ និងស្ពានជាដើម។ បន្ថែមពីលើនេះ រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់ថវិកាដល់ការគ្រប់គ្រងនៃស្ថាប័ននានាដែលមានភារកិច្ចគ្រប់គ្រង និងធ្វើសកម្មភាពបោសសម្អាតមីននៅក្នុងប្រទេសផងដែរ។ ចំណែកក្នុងលក្ខណៈប្រយោលវិញ ការលើកលែងពន្ធលើឧបករណ៍បរិក្ខារបម្រើឱ្យសកម្មភាពមីន ក៏បានរួមចំណែកយ៉ាងសំខាន់ដល់ប្រតិបត្តិការបោសសម្អាតមីនលក្ខណៈមនុស្សធម៌ផងដែរ។

ការវិភាគដែលធ្វើឡើងដោយអាជ្ញាធរមីន ផ្អែកលើការចំណាយជាមធ្យមផ្តល់ដោយប្រតិបត្តិករទាំងអស់ដែលបានរួមបញ្ចូលគ្នា បានបង្ហាញថា ប្រតិបត្តិការបោសសម្អាតមីននៅកម្ពុជាមានប្រសិទ្ធភាពខ្ពស់ធៀបនឹងការចំណាយ។ ការព្យាករហិរញ្ញវត្ថុផ្អែកលើការចំណាយជាមធ្យមសម្រាប់ការបោសសម្អាតមីននិងស.ផ.ស.ក្នុងផ្ទៃដីមួយម៉ែត្រការ៉េទៅតាមចំណាត់ថ្នាក់ប្រភេទដីនីមួយៗ បង្ហាញឱ្យឃើញថា ក្នុងរយៈពេល ៨ឆ្នាំ គិតដល់ឆ្នាំ២០២៥ កម្ពុជាត្រូវការថវិកាមានចំនួនប្រមាណ **១៩៤លានដុល្លារអាមេរិក** សម្រាប់រំដោះផ្ទៃដីដែលដឹងថាមានមីនទាំងអស់ ហើយប្រមាណ **១២១លានដុល្លារអាមេរិក** សម្រាប់រំដោះផ្ទៃដីដែលដឹងថាមានគ្រាប់បែកចង្កោមដែលជាអាទិភាពខ្ពស់ ប្រមាណ **៣៩លានដុល្លារអាមេរិក** សម្រាប់ដោះស្រាយបញ្ហាស.ផ.ស.ផ្សេងៗ ព្រមទាំង **៥២លានដុល្លារអាមេរិក**ទៀត សម្រាប់ការអប់រំកាត់បន្ថយគ្រោះថ្នាក់មីន/ស.ផ.ស កិច្ចជួយសង្គ្រោះជនរងគ្រោះ ការតស៊ូមតិ និងការគ្រប់គ្រងវិស័យសកម្មភាពមីន។ សម្រាប់ការអនុវត្តផែនការយុទ្ធសាស្ត្រនេះ ការស្រាវជ្រាវចម្ការមីនមូលដ្ឋាននឹងត្រូវបញ្ចប់ក្នុងរយៈពេល ០៣ឆ្នាំដំបូង ហើយត្រូវការថវិកា **០,៦លានដុល្លារអាមេរិក**។[៤]

> ដើម្បីរំដោះផ្ទៃដីដែលដឹងថាមានមីននិងគ្រាប់បែកចង្កោមទាំងអស់ជាអាទិភាព និងដោះស្រាយបញ្ហាសំណល់ជាតិផ្ទុះពីសង្គ្រាមដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រជាតិនេះ ប្រទេសកម្ពុជាត្រូវការថវិកាប្រហែល **៤០៦លានដុល្លារអាមេរិក** សម្រាប់រយៈពេលពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២៥។

[៤] ការព្យាករខាងលើនេះ ផ្អែកទៅលើការសន្មតថា នៅឆ្នាំ២០១៧ ប្រទេសកម្ពុជានឹងរំដោះផ្ទៃដីចំនួន ១៣៦គីឡូម៉ែត្រការ៉េ គឺជាទំហំប៉ុនគ្នានឹងទំហំដែលសម្រេចបានកាលពីឆ្នាំ២០១៦។

ដូចនេះ វិស័យមីននៅកម្ពុជាត្រូវការថវិកាប្រចាំឆ្នាំប្រមាណ ២៤លានដុល្លារអាមេរិកសម្រាប់បញ្ចប់ការបោសសម្អាតមីន ប្រមាណ ១៥លានដុល្លារអាមេរិក សម្រាប់ដោះស្រាយបញ្ហាគ្រាប់បែកចង្កោមជាអាទិភាព និងប្រមាណ ៥លានដុល្លាអាមេរិក សម្រាប់ដោះស្រាយបញ្ហាស.ផ.ស.ផ្សេងទៀត។

ជាមួយនឹងធនធាននេះ កម្ពុជានឹងអាចរំដោះបានផ្ទៃដីប្រមាណ ១ ៧០៩គីឡូម៉ែត្រការ៉េ (ឧបសម្ព័ន្ធ ខ) ស្តីពីការព្យាករអំពីការរំដោះផ្ទៃដី (២០១៨-២០២៥)។ សល់ពីនោះ នឹងត្រូវចាត់ទុកថាជាការគំរាមកំហែងដែលនៅសេសសល់ដែលត្រូវបន្តដោះស្រាយនៅក្រោយឆ្នាំ២០២៥។

រាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់ថា តម្រូវការនៃហិរញ្ញប្បទានអភិវឌ្ឍន៍មានការកើនឡើងនៅក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ។ វិបត្តិដែលកើតមានឡើងនៅមជ្ឈិមបូព៌ា លំហូរជនភៀសខ្លួន ក៏ដូចជាការធ្លាក់ចុះនៃវិស័យសេដ្ឋកិច្ចនៅតាមបណ្តាប្រទេសជាច្រើន ធ្វើឱ្យហិរញ្ញប្បទានជំនួយមានការថយចុះ។ ដូចករណីកម្ពុជា កញ្ចប់ថវិកាអភិវឌ្ឍន៍មានកំណត់ ប៉ុន្តែមានតម្រូវការជាច្រើន។ ការចូលរួមវិភាគទានថវិកានាពេលអនាគត អាចនឹងមិនគ្រប់គ្រាន់សម្រាប់បំពេញតាមតម្រូវការពេញលេញស្របតាមគោលដៅនៃយុទ្ធសាស្ត្រជាតិ ស្តីពីសកម្មភាពកម្ចាត់មីននៅឆ្នាំ២០២៥ឡើយ។ ហេតុដូចនេះ កម្ពុជានឹងប្រកាន់យកវិធីគិតគ្រោងទុកជាមុន នៅក្នុងការធ្វើផែនការសម្រាប់ដំណាក់កាលចុងក្រោយនៃការដោះស្រាយបញ្ហាមីននិងស.ផ.ស.ដែលនៅសេសសល់។ កម្ពុជានឹងកៀរគរធនធានទាំងតាមប្រភពម្ចាស់ជំនួយចាស់និងម្ចាស់ជំនួយថ្មីដទៃទៀត និងពិនិត្យរកប្រភពថវិកាផ្សេងៗបន្ថែមទៀតដើម្បីស្នើសុំជំនួយ ព្រមទាំងស្វែងរកវិធីសាស្ត្រដែលមានប្រសិទ្ធភាពក្នុងការប្រើប្រាស់ធនធាននិងបច្ចេកវិទ្យាដែលមានទាំងអស់របស់ខ្លួន។

ការផ្លាស់ប្តូរពីប្រភពថវិកាពីខាងក្រៅប្រទេស មកជាប្រភពថវិកាពីក្នុងប្រទេសវិញ នឹងធ្វើឱ្យមានការដកថយជាបណ្តើរៗនៃម្ចាស់ជំនួយអន្តរជាតិ ហើយកម្ពុជានឹងត្រូវមានភារកិច្ចទទួលខុសត្រូវកាន់តែច្រើនបន្ថែមទៀតក្នុងការបោសសម្អាតមីននិងស.ផ.ស.ដែលនៅសេសសល់។

វិធីសាស្ត្រដែលកម្ពុជានឹងប្រើប្រាស់ ដើម្បីធានាបាននូវធនធានគ្រប់គ្រាន់សម្រាប់ការលុបបំបាត់មីននិងស.ផ.ស.ឱ្យបានទាំងស្រុង មានដូចតទៅ៖

- ប្រសិទ្ធភាពចំណាយក្នុងវិស័យនេះនឹងត្រូវបានលើកកម្ពស់។ ការកែលម្អវិធីសាស្ត្រសម្រាប់ការធ្វើផែនការ និងសម្រាប់ការដោះស្រាយបញ្ហាមីននិងស.ផ.ស.ដែលមានចែងនៅក្នុងផ្នែកក្របខ័ណ្ឌប្រតិបត្តិការ ការធ្វើផែនការនិងការចាត់អាទិភាពខាងលើនឹងត្រូវបានអនុវត្ត ជាពិសេសពាក់ព័ន្ធនឹងការរំដោះផ្ទៃដី និងការចាត់អាទិភាពការងារ។
- ការសន្ទនាអំពីគោលនយោបាយជាមួយដៃគូអភិវឌ្ឍន៍ និងក្រុមការងារបច្ចេកទេសចម្រុះរាជរដ្ឋាភិបាល-ដៃគូអភិវឌ្ឍ លើវិស័យសកម្មភាពមីននឹងត្រូវបានពង្រឹងតាមរយៈកិច្ចប្រជុំបន្ថែម (យ៉ាងហោចណាស់ពីរ ឬបីដង) ជារៀងរាល់ឆ្នាំ។ កិច្ចប្រជុំទាំងនេះនឹងត្រូវបានប្រើប្រាស់ដើម្បីជំរុញការចូលរួមពីដៃគូអភិវឌ្ឍន៍នានា ប្រមូលទស្សនៈផ្សេងៗរបស់ពួកគេ និងស្តាប់យោបល់និងអនុសាសន៍របស់ពួកគេអំពីយុទ្ធសាស្ត្រដែលល្អប្រសើរបំផុតសម្រាប់កម្មវិធីសកម្មភាពមីន។ ថ្វីត្បិតតែការសម្រេចគោលដៅកាន់តែខិតជិត កម្ពុជានៅត្រូវការជំនួយគាំទ្រពីខាងក្រៅជាបន្តទៀត ទាំងក្នុងទម្រង់ជាម្ចាស់ជំនួយ និងជាប្រតិបត្តិករ ដើម្បីបំពេញភារកិច្ចឱ្យបានចប់សព្វគ្រប់។ ម្ចាស់ជំនួយលក្ខណៈមនុស្សធម៌ដែលមានជាប្រពៃណីនាពេលកន្លងមក នឹងត្រូវបានលើកទឹកចិត្តឱ្យបន្តការគាំទ្រដល់វិស័យនេះតាមលទ្ធភាពដែល

អាចធ្វើទៅបាន ដើម្បីឈានឆ្ពោះទៅសម្រេចឱ្យបាននូវគោលដៅចុងក្រោយដែលបានដាក់ចេញនៅត្រឹមឆ្នាំ២០២៥។

- ម្ចាស់ជំនួយថ្មីៗដែលបានចូលរួមក្នុងគម្រោងហេដ្ឋារចនាសម្ព័ន្ធអភិវឌ្ឍន៍ ឬគម្រោងអប់រំពាក់ព័ន្ធនឹងសកម្មភាពមីន ក៏នឹងត្រូវបានលើកទឹកចិត្តឱ្យជួយផ្តល់ជំនួយគាំទ្រផងដែរ។ បណ្តាប្រទេសនៅអាស៊ីបូព៌ា (ដូចជាប្រទេសចិន និងកូរ៉េខាងត្បូងជាដើម) និងក្នុងតំបន់ឈូងសមុទ្រ គឺជាប្រការដែលគួរយកចិត្តទុកដាក់ជាពិសេសសម្រាប់បញ្ហានេះ។ ការកៀរគរម្ចាស់ជំនួយទាំងចាស់និងថ្មី ឱ្យចូលរួមក្នុងការដោះស្រាយបញ្ហាជាអាទិភាពខ្ពស់ ដូចជាតំបន់ដែលមានដង់ស៊ីតេមីនប្រឆាំងមនុស្សខ្ពស់ ដែលជាការគំរាមកំហែងកម្រិតខ្ពស់ដល់សហគមន៍មូលដ្ឋាន គឺជាចំណុចសំខាន់បំផុតដែលត្រូវផ្តោតការយកចិត្តទុកដាក់។
- សសរស្តម្ភថ្មីមួយទៀតដែលអាចផ្តល់ជាប្រភពថវិកានៃសកម្មភាពមនុស្សធម៌ជាសកល គឺហិរញ្ញប្បទានឯកជន។ កម្ពុជានឹងពិនិត្យពិចារណាដាក់ចេញនូវគោលដៅសំដៅឆ្ពោះទៅរកភាគីពាក់ពន្ធ័ក្នុងវិស័យសប្បុរសធម៌ដោយផ្ទាល់ ឬអាចធ្វើឡើងតាមរយៈតួអង្គអន្តរការីនានា ដូចជាទីប្រឹក្សាពិគ្រោះយោបល់ក្នុងវិស័យសប្បុរសធម៌ជាដើម។
- ពង្រីកមូលដ្ឋានជំនួយមនុស្សធម៌ពីគ្រប់មជ្ឈដ្ឋានជាតិនិងអន្តរជាតិ។ កម្ពុជាក៏នឹងខិតខំកសាងនូវវិធីសាស្ត្រដែលអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិមួយចំនួនធ្លាប់បានប្រើប្រាស់ដោយជោគជ័យ ក្នុងការកៀរគរជំនួយគាំទ្រពីមូលនិធិឯកជនផងដែរ។
- ដោយយល់ច្បាស់អំពីផលអវិជ្ជមាននៃវត្តមានមីននិងស.ផ.ស.ទៅលើការអភិវឌ្ឍជាតិ និងការកាត់បន្ថយភាពក្រីក្រ រាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់ថានៅមានការងារជាច្រើនទៀតដែលត្រូវធ្វើ។ កម្ពុជានឹងបន្តធ្វើការផ្សព្វផ្សាយជាសាធារណៈឱ្យកាន់តែពេញលេញអំពីថវិកាដែលខ្លួន ដែលរួមចំណែកដល់ផ្នែកផ្សេងៗនៃសកម្មភាពមីនឱ្យកាន់តែមានតម្លាភាពនិងគណនេយ្យភាព។ រាជរដ្ឋាភិបាលកម្ពុជានឹងបន្តគាំទ្រដល់មុខងារសម្របសម្រួលថ្នាក់ជាតិនិងនិយ័តកម្មលើសកម្មភាពមីន តាមរយៈអាជ្ញាធរមីន ហើយនឹងគាំទ្រដល់ប្រតិបត្តិករជាតិសម្រាប់ការបោសសម្អាតមីនតាមកិច្ចសន្យា និងសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធធំៗ។
- ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងនានាខាងលើនេះ អាជ្ញាធរមីននឹងកសាងយុទ្ធសាស្ត្រសម្រាប់កៀរគរធនធាននៅបន្ទាប់ពីផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន ២០១៨-២០២៥ នេះ បានបញ្ចប់ទៅ ដោយស្វែងរកការគាំទ្រផ្នែកហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុពីបណ្តាប្រភពនានា ដូចខាងក្រោម៖
  - វិភាគទានរបស់រាជរដ្ឋាភិបាល
  - ដៃគូអភិវឌ្ឍន៍
  - ស្ថាប័នផ្សេងទៀត រួមទាំងសប្បុរសជននានា។

# ១២. ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ

យោងតាមតួនាទីដ៏សំខាន់នៃការងារតាមដានត្រួតពិនិត្យ ការពិនិត្យឡើងវិញនិងការវាយតម្លៃ ក្នុងការធានាបាននូវលទ្ធផលជាវិជ្ជមានពីការអភិវឌ្ឍ កម្ពុជានឹងសង្កត់ធ្ងន់បន្ថែមទៀតទៅលើការធានាឱ្យបាននូវការគ្រប់គ្រងគុណភាព តាមរយៈការពង្រឹងប្រព័ន្ធដែលមានស្រាប់។ បញ្ហាប្រសិទ្ធភាព ការតាមដានត្រួតពិនិត្យលើវឌ្ឍនភាព ការកែលម្អជាប្រចាំ ការធ្វើរបាយការណ៍ និងការធ្វើផែនការដោយការប្រមើលទុកជាមុន ត្រូវបានទទួលស្គាល់ថា មានសារៈសំខាន់បំផុតសម្រាប់ការគ្រប់គ្រងកម្មវិធីសកម្មភាពមីនឱ្យបានល្អប្រសើរ។ វឌ្ឍនភាពនឹងត្រូវបានវាស់វែង ដោយឈរលើការតាមដានត្រួតពិនិត្យនិងការវិភាគលើសូចនាករជាយុទ្ធសាស្ត្រនានានៃ ផ.យ.ជ.ម. ២០១៨-២០២៥ ហើយនឹងត្រូវបានបញ្ជ្រាបចូលទៅក្នុងដំណើរការសកម្មភាពមីននៅកម្ពុជា។

តារាងសូចនាករសកម្មភាព(PIM) ដែលមានបញ្ជាក់នៅក្នុងឧបសម្ព័ន្ធ គ ខាងក្រោមនេះ ធ្វើឡើងដោយផ្អែកលើទស្សនាទាន **«ស្មាត»** (SMART)៖ សាមញ្ញ(simple) អាចវាស់វែងបាន(measurable) អាចសម្រេចបាន (attainable)ភាពពាក់ព័ន្ធ (relevant) និងតាមពេលវេលា(time-bound) ដែលសម្របទៅនឹងស្ថានភាពរបស់កម្ពុជា និងជាពិសេសវិស័យសកម្មភាពមីន។ តារាងនេះមានគោលបំណងផ្តល់នូវមធ្យោបាយសម្រាប់ការវាស់វែងសកម្មភាពមីន នៅក្នុងអំឡុងពេលនៃការអនុវត្តផែនការយុទ្ធសាស្ត្រនេះ (២០១៨-២០២៥)។

របនាសម្ព័ន្ធនៃការតាមដានត្រួតពិនិត្យ ការពិនិត្យឡើងវិញ និងវាយតម្លៃ រួមមានដូចតទៅ៖

- ដំណើរការតាមដានត្រួតពិនិត្យជាប្រចាំទៅលើការប្រមូលទិន្នន័យនៅរៀងរាល់ ៦ខែ និងការពិនិត្យឡើងវិញអំពីវឌ្ឍនភាពធៀបទៅនឹងសូចនាករសកម្មភាព ដែលត្រូវធ្វើឡើងដោយអាជ្ញាធរមីន។ ដំណើរការនេះ នឹងត្រូវឈរលើផែនការការងារប្រចាំឆ្នាំ និងលទ្ធផលនៃការតាមដានត្រួតពិនិត្យការងារប្រចាំឆ្នាំសម្រាប់ផែនយុទ្ធសាស្ត្រជាតិសកម្មភាពមីន ២០១៨-២០២៥។
- ការពិនិត្យឡើងវិញនៅពាក់កណ្តាលគ្រា ដោយយន្តការផ្ទៃក្នុង ឬដោយអ្នកជំនាញពីខាងក្រៅ។
- ការវាយតម្លៃអំពីសមិទ្ធផលនៅពេលក្រោយការអនុវត្តគម្រោង និងលទ្ធផលបន្ទាប់ពីការបញ្ចប់នៃការអនុវត្តយុទ្ធសាស្ត្រនេះនៅឆ្នាំ២០២៥។ ចំណុចនេះនឹងធ្វើការពិនិត្យវាយតម្លៃលើការអនុវត្តបទពិសោធន៍ផ្សេងៗដែលត្រូវបានដកស្រង់និងអនុសាសន៍នានា ដើម្បីប្រសិទ្ធភាពនិងការកែលម្អផ្សេងៗសម្រាប់ការងារសកម្មភាពមីនដែលនៅសេសសល់ ហើយនឹងផ្តល់ជាអនុសាសន៍សម្រាប់ការកែលម្អដំណើរការធ្វើផែនការនាពេលអនាគតផងដែរ។

ដើម្បីជំរុញដំណើរការមួយប្រព្រឹត្តទៅបាន គឺត្រូវមានការតាមដានត្រួតពិនិត្យ ការពិនិត្យមើលឡើងវិញ និងការវាយតម្លៃដែលប្រកបដោយលក្ខណៈបើកចំហរ មានការពិគ្រោះយោបល់ពេញលេញ មានតម្លាភាព និងមានការចូលរួម ហើយផ្អែកលើការប្រមូលនិងវិភាគទិន្នន័យជាប្រចាំ។ នេះជាអភិក្រមរួមសម្រាប់ផ្តល់ការចូលរួមពីដៃគូអភិវឌ្ឍន៍ទាំងអស់ ដែលនឹងធានាបាននូវលទ្ធផលវិជ្ជមាននិងប្រកបដោយប្រសិទ្ធផល។

ដើម្បីធានាបាននូវវិធីសាស្ត្រមួយមានលក្ខណៈជាប្រព័ន្ធសម្រាប់ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃដោយមានការពិគ្រោះយោបល់ជាមួយម្ចាស់ជំនួយ ប្រតិបត្តិករ និងភាគីពាក់ព័ន្ធនានា អាជ្ញាធរមីននឹងបង្កើតឱ្យមានប្រព័ន្ធត្រួតពិនិត្យសកម្មភាពមីន (PMS) ដែលមានលក្ខណៈសម្របសម្រួលស៊ីសង្វាក់គ្នាល្អ។ ប្រការនេះនឹង

ធ្វើឱ្យសកម្មភាពមីនស្ថិតនៅលំដាប់ជួរមុខនៃវិស័យទាំងអស់នៅក្នុងកម្ពុជា ក៏ដូចជាធ្វើឱ្យកម្ពុជាស្ថិតនៅលំដាប់ជួរមុខនៃបណ្តាប្រទេសទាំងអស់ដែលរងគ្រោះដោយសារមីន នៅលើពិភពលោកផងដែរ។

ប្រព័ន្ធត្រួតពិនិត្យសកម្មភាពមីន នឹងធ្វើឱ្យវិស័យសកម្មភាពមីនអាចរាយការណ៍អំពីលទ្ធផលនៃសកម្មភាពមីន តាមរយៈការអនុវត្ត ផ.យ.ជ.ម. ២០១៨-២០២៥ នេះ និងលទ្ធផលនៃការអភិវឌ្ឍ ដូចជាការកាត់បន្ថយភាពក្រីក្រ និងអាទិភាពនៃការអភិវឌ្ឍសេដ្ឋកិច្ចសង្គម។

ដើម្បីបង្កើត អនុវត្ត និងកែលម្អប្រព័ន្ធត្រួតពិនិត្យសកម្មភាពមីននេះ ចាំបាច់ត្រូវបង្កើតឱ្យមានក្រុមការងារបច្ចេកទេសត្រួតពិនិត្យសកម្មភាពមីន(TRG-PMS) ដោយមានការចូលរួមពីអង្គភាពធ្វើផែនការសកម្មភាពមីន ប្រតិបត្តិករ ដៃគូអភិវឌ្ឍន៍ អង្គការអភិវឌ្ឍន៍ជនបទ និងភាគីពាក់ព័ន្ធនានា។ ការត្រួតពិនិត្យតាមដានរបស់ TRG-PMS នឹងធ្វើការពិនិត្យឡើងវិញអំពីការប្រមូល ការវិភាគ និងការធ្វើរបាយការណ៍ទិន្នន័យសេដ្ឋកិច្ចសង្គម រួមជាមួយនឹងផែនការសម្រាប់អនុវត្តនិងពង្រឹងប្រព័ន្ធត្រួតពិនិត្យសកម្មភាពមីនផងដែរ។

# ១៣. ការសន្និដ្ឋាន

ជាមួយនឹងចំនួនជនរងគ្រោះជិត ៦៥ ០០០នាក់ ដែលជាលទ្ធផលនៃគ្រោះថ្នាក់ដោយសារមីននិង ស.ផ.ស. បង្ហាញថាកម្ពុជាបានទទួលបន្ទុកដ៏ធ្ងន់ធ្ងររួចទៅហើយ។ មីននិងស.ផ.សមិនត្រឹមតែបណ្តាលឱ្យមានការបាត់បង់ជីវិតរបស់ប្រជាជនក្រីក្រដែលគ្មានកំហុសនោះទេ ប៉ុន្តែវាថែមទាំងបានបង្កជាឧបសគ្គដល់ការកាត់បន្ថយភាពក្រីក្រ និងបង្កជាបញ្ហាប្រឈមដ៏ធំធេងសម្រាប់ការអភិវឌ្ឍប្រទេសនៅក្នុងស្ថានភាពក្រោយសង្គ្រាម។ កម្មវិធីសកម្មភាពមីនលក្ខណៈមនុស្សធម៌នៅកម្ពុជា បានដើរតួនាទីយ៉ាងសំខាន់ក្នុងការឆ្លើយតបចំពោះបញ្ហាប្រឈមទាំងនេះ។ កម្ពុជាបានរៀបចំផ.យ.ជ.ម. ២០១៨-២០២៥នេះឡើង ដោយឈរលើភាពជោគជ័យពីដំណាក់កាលមុនៗ សំដៅកំណត់ចក្ខុវិស័យនិងបេសកកម្មឱ្យបានច្បាស់លាស់ ដែលគាំទ្រដោយគោលបំណងនិងគោលដៅដែលអាចសម្រេចទៅបាន។ ដើម្បីគាំទ្រដល់យុទ្ធសាស្ត្រជាតិនេះឱ្យសម្រេចបានតាមគោលដៅ និងគោលបំណងដែលបានកំណត់ កម្ពុជាត្រូវការជាចាំបាច់នូវធនធានគ្រប់គ្រាន់ រួមមានបច្ចេកទេស មនុស្ស បរិក្ខារសម្ភារ និងហិរញ្ញវត្ថុ ដើម្បីគាំទ្រដល់សកម្មភាពមីននៅកម្ពុជា ដូចជាការធ្វើផែនទីចម្ការមីនច្បាស់លាស់ ការធ្វើផែនការនិងការចាត់អាទិភាពយ៉ាងហ្មត់ចត់ ការកំណត់អំពីចំនួនចម្ការមីនដែលត្រូវបានបោសសម្អាតមីនរួច ការអប់រំអំពីហានិភ័យដោយសារមីនប្រកបដោយប្រសិទ្ធភាព និងជំនួយគាំទ្រដល់ជនរងគ្រោះដែលមានលក្ខណៈល្អប្រសើរជាដើម។

កម្ពុជាបានទទួលការគាំទ្របច្ចេកទេសនិងហិរញ្ញវត្ថុ ពីសហគមន៍អភិវឌ្ឍន៍សម្រាប់សកម្មភាពមីនលក្ខណៈមនុស្សធម៌តាំងពីឆ្នាំ១៩៩២មក។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលកម្ពុជាក៏បានផ្តល់វិភាគទានគាំទ្រទាំងផ្នែកហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុផងដែរ ព្រមទាំងមានការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការដើរតួនាទីឈានមុខ ដោយមានការគាំទ្រពីសហគមន៍អភិវឌ្ឍន៍ ក្នុងការអនុវត្តតាមរាល់បទប្បញ្ញត្តិទាំងឡាយនៃអ.ហ.ផ.ម. ដើម្បីធានាថាមីនប្រឆាំងមនុស្សត្រូវបានបោសសម្អាតទាំងស្រុងនៅប្រទេសកម្ពុជាត្រឹមឆ្នាំ២០២៥។ ប្រការនេះតម្រូវឱ្យមានការគាំទ្រពីភាគីពាក់ព័ន្ធដទៃទៀត រួមទាំងប្រតិបត្តិករ អាជ្ញាធរថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សហគមន៍មូលដ្ឋាន និងដៃគូអន្តរជាតិ។

ការបន្តពង្រឹងនិងការថែរក្សាបាននូវហេដ្ឋារចនាសម្ព័ន្ធនិងសមត្ថភាពឈានឡើងជាលំដាប់ ដើម្បីឆ្លើយតបទៅនឹងការគំរាមកំហែងផ្សេងៗដែលនៅសេសសល់ នឹងក្លាយជាជំពូកចុងក្រោយនៃដំណើររឿងដ៏ជោគជ័យមួយសម្រាប់កម្ពុជានិងពិភពលោកទាំងមូល។ វិស័យសកម្មភាពមីននៅកម្ពុជាត្រូវតែធ្វើការរួមគ្នាយ៉ាងស្វាហាប់ ដើម្បីសម្រេចបាននូវគោលដៅចុងក្រោយនៃការបោសសម្អាតមីន។ លើសពីនេះទៀត ដោយផ្អែកលើចំណុចខ្លាំង និងបទពិសោធន៍នៅក្នុងសកម្មភាពមីនអស់រយៈពេលជាង ២៥ឆ្នាំកន្លងមកនេះ កម្ពុជានឹងបន្តចែករំលែកជំនាញនេះជាផ្នែកមួយនៃគំនិតផ្តួចផ្តើមពាក់ព័ន្ធនឹងនិសព្វាវុធការនៅជុំវិញពិភពលោក តាមរយៈកិច្ចសហប្រតិបត្តិការត្បូង-ត្បូង ព្រមទាំងបន្តការចូលរួមចំណែកក្នុងប្រតិបត្តិការរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិផងដែរ។

គោលដៅដើម្បីបោសសម្អាតមីនឱ្យអស់ពីប្រទេសកម្ពុជានៅត្រឹមឆ្នាំ២០២៥ អាចសម្រេចទៅបានដោយសារមានសុច្ឆន្ទៈនិងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា និងភាគីពាក់ព័ន្ធទាំងអស់។ ការទទួលខុសត្រូវប្រកបដោយសីលធម៌ទាំងផ្នែកសេដ្ឋកិច្ចនិងសង្គម គឺជាការធានានូវបរិស្ថានមួយប្រកបដោយសុវត្ថិភាពសម្រាប់មនុស្សជំនាន់នេះនិងជំនាន់ក្រោយៗទៀត។ ទីកន្លែងដែលមានសុវត្ថិភាពសម្រាប់ការរស់នៅនិងបំពេញការងារ គឺជាសិទ្ធិមួយក្នុងចំណោមសិទ្ធិមនុស្សជាមូលដ្ឋាននានា។ នេះក៏ជាបុរេលក្ខខណ្ឌសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងការលុបបំបាត់ភាពក្រីក្រផងដែរ។

# ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធ ក៖ ស្តង់ដារចាត់ថ្នាក់ប្រភេទដី

ឧបសម្ព័ន្ធ ខ៖ ការព្យាករអំពីការរំដោះផ្ទៃដី និងថវិកា ២០១៨-២០២៥

ឧបសម្ព័ន្ធ គ៖ តារាងសូចនាករសកម្មភាព

## ឧបសម្ព័ន្ធ ក

# ស្តង់ដារចាត់ថ្នាក់ប្រភេទដី

| ចំណាត់ថ្នាក់ | ចំណាត់ថ្នាក់បន្ទាប់ | | សេចក្តីលម្អិតអំពីចំណាត់ថ្នាក់ | កំណត់សម្គាល់ |
|---|---|---|---|---|
| A<br>( **តំបន់មានមីន** )<br>ដីមានភ័ស្តុតាងថាមានមីន | A1 | ដីមានដង់ស៊ីតេមីនប្រឆាំងមនុស្សច្រើន | ដីមានដាក់មីន ជាលក្ខណៈយុទ្ធសាស្រ្ត ដាក់ការពារដោយមានទ្រង់ទ្រាយច្បាស់លាស់ ដូចជាខ្សែក្រវាត់មីនតាមបណ្តោយផ្លូវតាមព្រំដែន តាមមូលដ្ឋានទ័ព និងតាមហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ | ការពង្រាយកម្លាំងបោសសម្អាតមីនមនុស្សធម៌ គួរផ្តោតសំខាន់លើ A1-A3 ដើម្បីឆ្លើយតបនឹងអាទិភាពរបស់សហគមន៍។ គ្រប់ពហុកោណគួរធ្វើការអង្កេតបន្ថែម ដើម្បីបានដឹងបរិមាណដីមានមីន មុនពេលពង្រាយកម្លាំងដោះមីន។ ការពង្រាយកម្លាំងដោះមីនលើដី A4 គួរកម្រិតចំពោះដីដែលមានការកំណត់ដាក់លាក់សម្រាប់កិច្ចអភិវឌ្ឍន៍ |
| | A2 | ដីមានមីនប្រឆាំងមនុស្សនិង មីនប្រឆាំងរថក្រោះដាក់លាយចម្រុះគ្នា | | |
| | A2.1 | ដីមានដង់ស៊ីតេមីនប្រឆាំងមនុស្ស និងមីនប្រឆាំងរថក្រោះ ដាក់លាយចម្រុះគ្នាច្រើន | | |
| | A2.2 | ដីមានមីនប្រឆាំងមនុស្ស និងមីនប្រឆាំងរថក្រោះនៅរាយប៉ាយ | ដីមិនបានប្រើប្រាស់បង្កបង្កើនផល ដោយមានមីនប្រឆាំងមនុស្ស និងមីនប្រឆាំងរថក្រោះតិចតួច ហើយយើងមិនអាចកំណត់ទីតាំងដាក់មីនបាន | |
| | A3 | ដីមានមីនប្រឆាំងរថក្រោះ | ដងផ្លូវកំពុងប្រើប្រាស់ ឬបោះបង់ចោលដែលមានមីនប្រឆាំងរថក្រោះ | |
| | A4 | ដីមានមីនប្រឆាំងមនុស្សនៅរាយប៉ាយដែលមិនអាចកំណត់ទីតាំងមីនបាន | ដីមិនបានប្រើប្រាស់បង្កបង្កើនផល ដោយមានមីនប្រឆាំងមនុស្សតិចតួច ហើយយើងមិនអាចកំណត់ទីតាំងដាក់មីនបាន | |
| B<br>( **ដីមាននៅសល់ការគំរាមកំហែងតិចតួច** )<br>ដីមានភ័ស្តុតាងថាមានគ្រាប់សំណល់ជាតិផ្ទុះពីសង្គ្រាម ឬមិនអាចកំណត់បានថាមានមីន | B1 | ដីមានគ្រាប់សំណល់ជាតិផ្ទុះពីសង្គ្រាម ( ERW ) (តែពុំមានមីន ) | តំបន់អតីតសមរភូមិដែលមានគ្រាប់សំណល់ជាតិផ្ទុះពីសង្គ្រាម។ តំបន់ប្រភេទនេះមានលក្ខណៈសមស្របសម្រាប់ការបោសសម្អាតគ្រាប់ ( Battle Area Clearance ) | តំបន់អតីតសមរភូមិដែលមានគ្រាប់សំណល់ជាតិផ្ទុះពីសង្គ្រាម។ តំបន់ប្រភេទនេះមានលក្ខណៈសមស្របសម្រាប់ការបោសសម្អាតគ្រាប់ ( Battle Area Clearance )<br>ការពង្រាយកម្លាំងបោសសម្អាតមីន លើដីប្រភេទ B ធ្វើតែចំពោះដីដែលឆ្លើយតបទៅនឹងតម្រូវការរបស់សហគមន៍ប៉ុណ្ណោះ |
| | B1.1 | ដីមានគ្រាប់ទម្លាក់ពីយន្តហោះ | មានទិន្នន័យគ្រាប់ដែលបានទម្លាក់ ឬមានភ័ស្តុតាងគ្រាប់ទម្លាក់ពីយន្តហោះ | |
| | B1.2 | ដីមានគ្រាប់បង្កោម | មានទិន្នន័យពីការទម្លាក់គ្រាប់ ឬមានភ័ស្តុតាងថាតំបន់មួយមានគ្រាប់បង្កោម | |
| | B1.3 | តំបន់ទីតាំងសមរភូមិ | តំបន់ទាំងឡាយដែលមានភ័ស្តុតាងបញ្ជាក់ថាធ្លាប់មានការប្រយុទ្ធ | |
| | B1.4 | ដីដែលមានគំនរគ្រាប់/គ្រាប់កប់ | តំបន់ទាំងឡាយណាដែលនៅមានគ្រាប់កប់ ឬមានគំនរគ្រាប់ | |
| | B1.5 | ទីតាំងយោធាដែលបានបោះបង់ | តំបន់ទាំងឡាយដែលអាចមានការសង្ស័យកម្រិតខ្ពស់ថាមានគ្រាប់រំសេវ | |
| | B2 | ដីមិនអាចកំណត់បានថា មានការគំរាមកំហែងដោយសារមីន | ដីធ្លាប់សង្ស័យថាមានមីន តែត្រូវបានប្រជាពលរដ្ឋទន្ទ្រានយកមកប្រើប្រាស់។ ប្រសិនបើពុំមានគ្រោះថ្នាក់ ឬពុំជួបប្រទះឃើញមីនរយៈពេល ០៣ឆ្នាំ ដីប្រភេទនេះត្រូវចាត់ថ្នាក់ជាដីប្រភេទ C1 | |
| C<br>( **ដីបញ្ចប់ការគំរាមកំហែង** )<br>ដីពុំមានភ័ស្តុតាងបញ្ជាក់ថាមានការគំរាមកំហែង | C1 | ដីត្រូវបានទន្ទ្រានយកមកប្រើប្រាស់ | ដីធ្លាប់សង្ស័យថាមានមីន តែត្រូវបានប្រជាពលរដ្ឋទន្ទ្រានយកមកប្រើប្រាស់ដោយពុំមានគ្រោះថ្នាក់ ឬពុំមានប្រទះឃើញមីនរយៈពេល ០៣ឆ្នាំ ដូចមានចែងក្នុងនយោបាយកាត់បន្ថយផ្ទៃដីចម្ការមីន | មិនគួរពង្រាយកម្លាំងបោសសម្អាតមីនមនុស្សធម៌លើដីប្រភេទនេះទេ |
| | C2 | ដីត្រូវបានកាត់បន្ថយដោយការស្រាវជ្រាវមូលដ្ឋាន ឬការស្រាវជ្រាវបច្ចេកទេស | ដីមានមីន ឬធ្លាប់សង្ស័យថាមានមីនតែត្រូវបានផែកមើលតាមវិធីស្រាវជ្រាវណាមួយដែលបញ្ជាក់ថា ពុំមានភ័ស្តុតាងថានៅមានសេសសល់ការគំរាមកំហែងទៀត | |
| | C3 | ដីបានបោសសម្អាតមីនរួច | ដីបានបោសសម្អាតមីនរួច ដោយប្រតិបត្តិករដែលទទួលបានអាជ្ញាប័ណ្ណពីអាជ្ញាធរមីន ហើយបានអនុវត្តតាមស្តង់ដារជាតិបោសសម្អាតមីន ( CMAS ) | |
| | C4 | ដីពុំមានមីន | ដីពុំមានការបញ្ជាក់ពីប្រជាពលរដ្ឋមូលដ្ឋាន ឬការស្រាវជ្រាវណាមួយថាមានមីនគំរាមកំហែងទេ | |

# ឧបសម្ព័ន្ធ ខ

## ការព្យាករអំពីការរំដោះផ្ទៃដី និងថវិកាឆ្នាំ២០១៨-២០២៥

| ចំណាត់ថ្នាក់ប្រភេទផ្ទៃដីសង្ស័យ | ផ្ទៃដីសន្មតថារំដោះបានឆ្នាំ២០១៧ | ផ្ទៃដីសរុបដែលត្រូវរំដោះចាប់ពីឆ្នាំ២០១៨ | ការចាត់អាទិភាពសម្រាប់រយៈពេល៨ឆ្នាំ | ផ្ទៃដីសរុបត្រូវការរំដោះ (២០១៨-២០២៥) | ផែនការរំដោះផ្ទៃដី ២០១៨-២០២៥ | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | ២០២៥ |
| | គ.ម$^{២}$ | គ.ម$^{២}$ | % | គ.ម$^{២}$ | គ.ម$^{២}$ | គ.ម$^{២}$ | គ.ម$^{២}$ | គ.ម$^{២}$ | គ.ម$^{២}$ | គ.ម$^{២}$ | គ.ម$^{២}$ | គ.ម$^{២}$ |
| ផ្ទៃដីដែលមានមីន | ៦៩ | ៨៧៧ | ១០០ | ៨៧៧ | ១០៩,៦៣ | ១០៩,៦៣ | ១០៩,៦៣ | ១០៩,៦៣ | ១០៩,៦៣ | ១០៩,៦៣ | ១០៩,៦៣ | ១០៩,៦៣ |
| ផ្ទៃដីដែលមានគ្រាប់បែកចង្កោម | ២១ | ៦២៤ | ៨០ | ៤៩៩ | ៦២ | ៦២ | ៦២ | ៦២ | ៦២ | ៦២ | ៦២ | ៦២ |
| ផ្ទៃដីដែលមានផ.ស.ផ.ផ្សេងទៀត | ៤៦ | ៣៣៣ | ១០០ | ៣៣៣ | ៤២ | ៤២ | ៤២ | ៤២ | ៤២ | ៤២ | ៤២ | ៤២ |
| ផ្ទៃដីសរុប | ១៣៦ | ១.៨៣៤ | | ១.៧០៩ | ២១៤ | ២១៤ | ២១៤ | ២១៤ | ២១៤ | ២១៤ | ២១៤ | ២១៤ |
| ថវិកាសម្រាប់រំដោះផ្ទៃដីសរុប(ដុល្លារអាមេរិក) | | | | ៣៥៣.៩៨៨.៩៤៥ | ៤៤.២៤៨.៦១៨ | ៤៤.២៤៨.៦១៩ | ៤៤.២៤៨.៦២០ | ៤៤.២៤៨.៦២១ | ៤៤.២៤៨.៦២២ | ៤៤.២៤៨.៦២៣ | ៤៤.២៤៨.៦២៤ | ៤៤.២៤៨.៦២៥ |
| ថវិកាសម្រាប់ស្រាវជ្រាវចម្ការមីនមូលដ្ឋាន(BLS) (ដុល្លារអាមេរិក) | | | | ៦៥៥.៩២០ | ២១៨.៦៤០ | ២១៨.៦៤១ | ២១៨.៦៤២ | | | | | |
| ថវិកាសម្រាប់គ្រប់គ្រងនិងសម្របសម្រួលវិស័យមីន(ដុល្លារអាមេរិក) | | | | ៥១.៥៦៤.៤៨៧ | ៦.៤៤៦.៧២៦ | ៦.៤៤៦.៧២៧ | ៦.៤៤៦.៧២៨ | ៦.៤៤៦.៧២៩ | ៦.៤៤៦.៧៣០ | ៦.៤៤៦.៧៣១ | ៦.៤៤៦.៧៣២ | ៦.៤៤៦.៧៣៣ |
| តម្រូវការថវិកាសរុប(ដុល្លារអាមេរិក) | | | | ៤០៦.១០៩.៣៥១ | ៥០.៩១៣.៩៨៤ | ៥០.៩១៣.៩៨៥ | ៥០.៩១៣.៩៨៦ | ៥០.៩១៣.៩៨៧ | ៥០.៩១៣.៩៨៨ | ៥០.៩១៣.៩៨៩ | ៥០.៩១៣.៩៩០ | ៥០.៩១៣.៩៩១ |

**កំណត់សម្គាល់៖**

- ទិន្នន័យខាងលើនេះ ត្រូវបានដកស្រង់ចេញពីប្រព័ន្ធគ្រប់គ្រងព័ត៌មាន (IMSMAng) ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៧។
- ដំណើការបន្តបាននិងកំពុងបំពេញបន្ថែមបន្ទាប់ពីការងារស្រាវជ្រាវចម្ការមីនមូលដ្ឋាន។
- យើងសន្មតថាផ្ទៃដីបោសសម្អាតនៅឆ្នាំ២០១៧ មានទំហំដូចគ្នាទៅនឹងទំហំផ្ទៃដីដែលបានបោសសម្អាតកាលពីឆ្នាំ២០១៦ (ទំហំ ១៣៦គ.ម$^{២}$)។

## ឧបសម្ព័ន្ធ គ

# តារាងសូចនាករសកម្មភាព
# ផែនការយុទ្ធសាស្ត្រជាតិស្ដីពីសកម្មភាពកម្ចាត់មីន (២០១៨-២០២៥)

| | |
|---|---|
| **ចក្ខុវិស័យ** | ប្រទេសកម្ពុជាគឺជាប្រទេសដែលគ្មានមីន ការគំរាមកំហែងនៃស.ផ.ស.ត្រូវបានកាត់បន្ថយឱ្យនៅកម្រិតអប្បបរមា ហើយការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងការអភិវឌ្ឍមនុស្សអាចប្រព្រឹត្តទៅដោយសុវត្ថិភាព។ |
| **បេសកកម្ម** | រំដោះផ្ទៃដីដែលដឹងថាមានមីនទាំងអស់និងគ្រាប់បែកចង្កោមជាអាទិភាព និងកាត់បន្ថយហានិភ័យដែលនៅសេសសល់ បណ្ដាលមកពីស.ផ.ស.ផ្សេងទៀតនៅកម្ពុជា និងស្វែងរកការគាំទ្រមតិលើសិទ្ធិនិងផ្ដល់សេវាកម្ម សម្រាប់អ្នករស់រានមានជីវិតពីគ្រោះថ្នាក់ដោយសារមីននិងស.ផ.ស. ក៏ដូចជា ជនរងគ្រោះដោយប្រយោល។ |

| គោលបំណងទី១៖ | រំដោះតំបន់ដែលដឹងថាមានមីនទាំងអស់នៅត្រឹមឆ្នាំ២០២៥ | | | |
|---|---|---|---|---|
| **ផលប៉ះពាល់៖** | តំបន់ដែលដឹងថាមានគ្រាប់មីនត្រូវបានរំដោះ និងដាក់ឱ្យប្រើប្រាស់សម្រាប់ការបង្កបង្កើនផល ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងហេដ្ឋារចនាសម្ព័ន្ធ | | | |
| **គោលដៅ** | **យុទ្ធសាស្ត្រ** | **សូចនាករ** | **មធ្យោបាយសម្រាប់ការផ្ទៀងផ្ទាត់** | **ហានិភ័យ/ការសន្មត** |
| **គោលដៅទី១៖**<br>បញ្ចប់ការស្រាវជ្រាវចម្ការមីនមូលដ្ឋានថ្នាក់ជាតិនៅតាមស្រុកដែលនៅសល់នៅត្រឹមឆ្នាំ២០២០ | **យុទ្ធសាស្ត្រទី១៖**<br>រៀបចំផែនការសម្រាប់ស្រាវជ្រាវចម្ការមីនមូលដ្ឋានលើស្រុកសេសសល់ដែលមានមីននិងស.ផ.ស. | - ផែនការសម្រាប់ស្រាវជ្រាវចម្ការមីនមូលដ្ឋានលើស្រុកសេសសល់ដែលមានមីននិងស.ផ.ស.<br>- បញ្ជីឈ្មោះឃុំ/ស្រុកដែលនៅសល់ត្រូវធ្វើការស្រាវជ្រាវ | - ផែនការសម្រាប់ស្រាវជ្រាវចម្ការមីនមូលដ្ឋានលើស្រុកសេសសល់ដែលមានមីន និងស.ផ.ស. ត្រូវបានអនុម័ត<br>- បញ្ជីឈ្មោះឃុំ/ស្រុកគោលដៅដែលត្រូវបានអនុម័តសម្រាប់ធ្វើការអង្កេត<br>- កំណត់ហេតុនៃកិច្ចប្រជុំនានា | ហានិភ័យ៖<br>- កង្វះការចូលរួមពេញលេញពីភាគីពាក់ព័ន្ធ<br>- តំបន់ដែលមិនអាចចូលទៅដល់<br>- អ្នកផ្ដល់ព័ត៌មានគន្លឹះសម្រាប់ការអង្កេតមិនបានចូលរួម<br>- ការបញ្ជូនទិន្នន័យពីប្រតិបត្តិករនានាមានការយឺតយ៉ាវ<br>ការសន្មត៖<br>- ស្តង់ដារជាតិស្ដីពីការស្រាវជ្រាវមូលដ្ឋានត្រូវបានអនុវត្តយ៉ាងពេញលេញដោយប្រតិបត្តិករទាំងអស់<br>- ទិន្នន័យសម្រាប់ការវាយតម្លៃតាមវិធីសាស្ត្រស្រាវជ្រាវផ្អែកលើឯកសារ |
| | **យុទ្ធសាស្ត្រទី២៖**<br>កៀរគរធនធានសម្រាប់គាំទ្រការស្រាវជ្រាវចម្ការមីនមូលដ្ឋាន | - យុទ្ធសាស្ត្រកៀរគរធនធាន<br>- សម្រាប់គាំទ្រការស្រាវជ្រាវចម្ការមីនមូលដ្ឋានជាផ្នែកមួយនៃយុទ្ធសាស្ត្រកៀរគរធនធានសម្រាប់វិស័យសកម្មភាពមីន | - យុទ្ធសាស្ត្រកៀរគរធនធានសម្រាប់វិស័យសកម្មភាពមីនត្រូវបានអនុម័ត<br>- ថវិកាដែលត្រូវបានកៀរគរសម្រាប់គាំទ្រការស្រាវជ្រាវចម្ការមីនមូលដ្ឋាន | |

| | | | | |
|---|---|---|---|---|
| | **យុទ្ធសាស្ត្រទី៣៖**<br>ធ្វើការស្រាវជ្រាវមូលដ្ឋាននៅគ្រប់ស្រុកទាំងអស់ដែលនៅសេសសល់ ត្រឹមឆ្នាំ២០២០ | - ទិន្នន័យពីការស្រាវជ្រាវចម្ការមីនមូលដ្ឋាននៅគ្រប់ស្រុកទាំងអស់ដែលនៅសល់ | - របាយការណ៍ស្រាវជ្រាវចម្ការមីនមូលដ្ឋាន<br>- ទម្រង់វាយតម្លៃការធានាគុណភាពស្រាវជ្រាវចម្ការមីនមូលដ្ឋាន/ការស្រាវជ្រាវមិនបច្ចេកទេស<br>- មូលដ្ឋានទិន្នន័យថ្នាក់ជាតិ | ពាក់ព័ន្ធត្រូវបានរៀបចំរួចរាល់សម្រាប់ការប្រើប្រាស់ផ្សេងៗ<br>- ការគាំទ្រដល់ការត្រួតពិនិត្យគុណភាពដោយពេញលេញ<br>- ពល់ធាតុចូលនិងឧបករណ៍នៃការ<br>- ស្រាវជ្រាវចម្ការមីនមូលដ្ឋាន ដែលពាក់ព័ន្ធទាំងអស់ត្រូវបានរៀបចំរួចរាល់សម្រាប់ការប្រើប្រាស់ផ្សេងៗ |
| **គោលដៅទី២៖**<br>អនុវត្តការកាត់រំដោះផ្ទៃដីតាមរយៈការស្រាវជ្រាវមិនបច្ចេកទេស លើដីត្រូវបានទន្រ្ទានយកមកប្រើប្រាស់ និងលុបចោលតំបន់សង្ស័យនិងការស្រាវជ្រាវឡើងវិញ ដើម្បីធ្វើបច្ចុប្បន្នភាពទិន្នន័យដីដែលមានមីន | **យុទ្ធសាស្ត្រទី១៖**<br>កសាងឯកសារទស្សនាទាននិងការសិក្សាវិភាគករណីស្តីពីការស្រាវជ្រាវមិនបច្ចេកទេសលើដីត្រូវបានទន្រ្ទានយកមកប្រើប្រាស់ និងលុបចោលតំបន់សង្ស័យ និងការស្រាវជ្រាវឡើងវិញ | - ឯកសារទស្សនាទានស្តីពីការស្រាវជ្រាវមិនបច្ចេកទេសលើដីត្រូវបានទន្រ្ទានយកមកប្រើប្រាស់ និងលុបចោលតំបន់សង្ស័យ និងការស្រាវជ្រាវឡើងវិញត្រូវបានរៀបចំឡើង<br>- ចំនួននៃការសិក្សាវិភាគករណីស្តីពីការស្រាវជ្រាវមិនបច្ចេកទេសលើដីត្រូវបានទន្រ្ទានយកមកប្រើប្រាស់និងលុបចោលតំបន់សង្ស័យ និងការស្រាវជ្រាវឡើងវិញដែលត្រូវបានធ្វើឡើង | - របាយការណ៍នៃសិក្ខាសាលាផ្សព្វផ្សាយ<br>- ឯកសារអនុម័តជាផ្លូវការពីអាជ្ញាធរមីន<br>- របាយការណ៍នៃការសិក្សាវិភាគករណី | ហានិភ័យ៖<br>- ធនធានមានកម្រិតក្នុងការរៀបចំកសាងឯកសារទស្សនទានស្តីពីការស្រាវជ្រាវមិនបច្ចេកទេសលើដីត្រូវបានទន្រ្ទានយកមកប្រើប្រាស់ និងលុបចោលតំបន់សង្ស័យនិងការស្រាវជ្រាវឡើងវិញ<br>- ឯកសារទស្សនទានស្តីពីការស្រាវជ្រាវមិនបច្ចេកទេស លើដីត្រូវបានទន្រ្ទានយកមកប្រើប្រាស់ និងលុបចោលតំបន់សង្ស័យ និងការស្រាវជ្រាវឡើងវិញមិនត្រូវបានអនុវត្តយ៉ាងពេញលេញដោយប្រតិបត្តិករនានា<br>- ការឈប់ពីការងារនៃបុគ្គលិកដែលបានទទួលការបណ្តុះបណ្តាលរួចហើយ<br><br>ការសន្មត៖<br>- គំរូ ឬរូបមន្តនេះ អាចយកទៅប្រើសម្រាប់ពង្រីកនៅទូទាំងប្រទេស |
| | **យុទ្ធសាស្ត្រទី២៖**<br>លើកកម្ពស់និងពង្រីកការអនុវត្តគំនិតផ្តួចផ្តើមស្តីពីការស្រាវជ្រាវមិនបច្ចេកទេសលើដីត្រូវបានទន្រ្ទានយកមក | - ឧត្តមានុវត្តន៍នៃការស្រាវជ្រាវមិនបច្ចេកទេស លើដីត្រូវបានទន្រ្ទានយកមកប្រើប្រាស់ និងលុបចោលតំបន់សង្ស័យ និងការស្រាវជ្រាវឡើងវិញត្រូវបានផ្សព្វផ្សាយ | - របាយការណ៍របស់សិក្ខាសាលាផ្សព្វផ្សាយ<br>- របាយការណ៍របស់ប្រតិបត្តិករនានា និងមូលដ្ឋានទិន្នន័យថ្នាក់ជាតិ | |

| | | | | |
|---|---|---|---|---|
| | ប្រើប្រាស់ និងលុបចោលតំបន់សង្ស័យ និងការស្រាវជ្រាវឡើងវិញ | - ទំហំនៃតំបន់មានមីន ដែលត្រូវបានរំដោះតាមរយៈការស្រាវជ្រាវមិនបច្ចេកទេស លើដីត្រូវបានទន្ទ្រានយកមកប្រើប្រាស់ និងលុបចោលតំបន់សង្ស័យ និងការស្រាវជ្រាវឡើងវិញ<br>- ចំនួនចម្ការមីនថ្មីត្រូវបានរកឃើញតាមរយៈការស្រាវជ្រាវមិនបច្ចេកទេស លើដីត្រូវបានទន្ទ្រានយកមកប្រើប្រាស់ និងលុបចោលតំបន់សង្ស័យ និងការស្រាវជ្រាវឡើងវិញ | | - ធនធាននានាត្រូវបានសម្របសម្រួលយ៉ាងល្អប្រសើរ ដើម្បីពង្រីកការអនុវត្តនូវគំនិតផ្តួចផ្តើមនេះ<br>- ការគាំទ្រពីភាគីពាក់ព័ន្ធមានលក្ខណៈគ្រប់គ្រាន់ |
| | **យុទ្ធសាស្ត្រទី៣៖**<br>ពង្រឹងសមត្ថភាពក្នុងការអនុវត្តការស្រាវជ្រាវមិនបច្ចេកទេស លើដីត្រូវបានទន្ទ្រានយកមកប្រើប្រាស់ និងលុបចោលតំបន់សង្ស័យនិងការស្រាវជ្រាវឡើងវិញ | - ធនធានដើម្បីអនុវត្តការស្រាវជ្រាវមិនបច្ចេកទេស លើដីត្រូវបានទន្ទ្រានយកមកប្រើប្រាស់ និងលុបចោលតំបន់សង្ស័យ និងការស្រាវជ្រាវឡើងវិញត្រូវបានបង្កើន | - ផែនការការងារនិងថវិកាដែលបានអនុម័ត<br>- អនុស្សារណៈយោគយល់គ្នា និងកិច្ចសន្យាផ្សេងៗ | |
| **គោលដៅទី៣៖**<br>រំដោះភូមិអាទិភាពដែលដឹងថាមានមីន នៅត្រឹមឆ្នាំ២០២១ និងភូមិដែលនៅសល់នៅត្រឹមឆ្នាំ២០២៥ | **យុទ្ធសាស្ត្រទី១៖**<br>កសាងផែនការប្រតិបត្តិការរយៈពេល៣ឆ្នាំ ដោយមានការពិនិត្យឡើងវិញប្រចាំឆ្នាំ ដោយផ្អែកលើដំណើរការការចាត់អាទិភាព | - ផែនការប្រតិបត្តិរយៈពេល៣ឆ្នាំដែលត្រូវបានអនុម័ត<br>- របាយការណ៍ស្តីពីការពិនិត្យឡើងវិញប្រចាំឆ្នាំ | - ឯកសារផ្លូវការរបស់អាជ្ញាធរមីន<br>- កំណត់ហេតុនៃកិច្ចប្រជុំនានា | ហានិភ័យ៖<br>- កង្វះការចូលរួមពីភាគីពាក់ព័ន្ធ<br>- ធនធានសម្រាប់ដោះមីនមិនគ្រប់គ្រាន់ដើម្បីសម្រេចគោលដៅដែលបាន<br>- កំណត់សម្រាប់បណ្តាភូមិជាអាទិភាព<br>- ភូមិដែលដឹងថាមានមីនជាអាទិភាព |

| | | | | |
|---|---|---|---|---|
| | **យុទ្ធសាស្ត្រទី២៖**<br>ដាក់ពង្រាយធនធានបោសសម្អាតមីននៅតាមភូមិអាទិភាព ដោយគិតគូរអំពីអាទិភាពរបស់មូលដ្ឋាន នៅត្រឹមឆ្នាំ២០២១ និងភូមិដែលមានមីនដែលនៅសល់ទាំងអស់ ត្រឹមឆ្នាំ២០២៥ | - បញ្ជីភូមិអាទិភាពដែលដឹងថាមានមីនត្រូវបានធ្វើអត្តសញ្ញាណកម្ម<br>- ទំហំនៃដីដែលដឹងថាមានមីនជាអាទិភាព ត្រូវបានរំដោះ | - បញ្ជីឈ្មោះភូមិអាទិភាពដែលបានអនុម័តរួច<br>- របាយការណ៍ស្តីពីទំហំនៃតំបន់ដែលដឹងថាមានមីនជាអាទិភាពដែលត្រូវបានរំដោះរួច | មិនអាចចូលទៅដល់<br>- ធនធានមានកម្រិតសម្រាប់គាំទ្រដល់ក្រុមការងារគ្រប់គ្រងគុណភាពរបស់អាជ្ញាធរមីន<br><br>ការសន្មត៖<br>- គោលការណ៍ណែនាំអំពីការធ្វើផែនការ និងការកំណត់អាទិភាព ត្រូវបានអនុវត្ត<br>- មានឧបករណ៍និងធនធានចាំបាច់នានា<br>- ប្រតិបត្តិករទាំងឡាយប្រតិបត្តិតាមស្តង់ដារសកម្មភាពកម្ចាត់មីនកម្ពុជា |
| | **យុទ្ធសាស្ត្រទី៣៖**<br>ពង្រឹងការអនុលោមតាមប្រព័ន្ធគ្រប់គ្រងគុណភាពនៅក្នុងសកម្មភាពបោសសម្អាតមីន | - ស្តង់ដារសកម្មភាពកម្ចាត់មីនកម្ពុជាត្រូវបានកែសម្រួលនិងអនុវត្តដោយប្រតិបត្តិករ<br>- ចំនួននៃគ្រោះថ្នាក់ដល់អ្នកដោះមីន ថយចុះ | - កំណត់ហេតុនៃកិច្ចប្រជុំត្រួតពិនិត្យឡើងវិញលើ ស្តង់ដារសកម្មភាពកម្ចាត់មីនកម្ពុជា<br>- របាយការណ៍ការគ្រប់គ្រងគុណភាព<br>- របាយការណ៍គ្រោះថ្នាក់ | |
| **គោលដៅទី៤៖**<br>ពិនិត្យឡើងវិញនិងកែលម្អប្រព័ន្ធប្រតិបត្តិការ និងសមត្ថភាពដែលមានស្រាប់ | **យុទ្ធសាស្ត្រទី១៖**<br>ពិនិត្យឡើងវិញនិងកែលម្អប្រព័ន្ធធ្វើផែនការនិងចាត់អាទិភាព | - គោលការណ៍ណែនាំអំពីការធ្វើផែនការនិងការចាត់អាទិភាពត្រូវបានកែសម្រួលរួចសម្រាប់ប្រើប្រាស់ | - គោលការណ៍ណែនាំអំពីការធ្វើផែនការនិងការចាត់អាទិភាពដែលបានអនុម័ត | ហានិភ័យ៖<br>- កង្វះការចូលរួមពីអង្គភាពធ្វើផែនការសកម្មភាពកម្ចាត់មីន និងប្រតិបត្តិករនានា<br>- ធនធានមានកម្រិតដើម្បីអនុវត្តបច្ចេកវិទ្យាច្នៃប្រឌិតថ្មី |
| | **យុទ្ធសាស្ត្រទី២៖**<br>ពិនិត្យឡើងវិញនិងកែលម្អវិធីសាស្ត្ររំដោះផ្ទៃដី | - វិធីសាស្ត្ររំដោះផ្ទៃដីត្រូវបានកែសម្រួលរួចសម្រាប់ប្រើប្រាស់ | - វិធីសាស្ត្រកាត់បន្ថយផ្ទៃដីចម្ការមីន ដែលបានអនុម័ត | |

| | | | | |
|---|---|---|---|---|
| | **យុទ្ធសាស្ត្រទី៣៖**<br>ធ្វើពិពិធកម្មការប្រើប្រាស់បច្ចេកវិទ្យាច្នៃប្រឌិតថ្មីនៅក្នុងសកម្មភាពកម្ចាត់មីន | - ប្រភេទនៃបច្ចេកវិទ្យាច្នៃប្រឌិតថ្មី (ធនធានសម្រាប់ការដោះមីន) ត្រូវបានដាក់ឱ្យប្រើប្រាស់ | - របាយការណ៍នៃការធ្វើតេស្តសាកល្បងលើបច្ចេកវិទ្យាច្នៃប្រឌិតថ្មី | ការសន្មត៖<br>- យន្តការអង្គភាពធ្វើផែនការសកម្មភាពកម្ចាត់មីន នៅតែដំណើរការ<br>- ការធ្វើផែនការនិងការកំណត់អាទិភាពត្រូវឈរលើតម្រូវការជាក់ស្តែង និងប្រជាជន ជាកត្តាសំខាន់បំផុត<br>- ស្តង់ដារសកម្មភាពកម្ចាត់មីនកម្ពុជាស្តីពីការកាត់បន្ថយផ្ទៃដីចម្ការមីនត្រូវបានអនុវត្តដោយប្រតិបត្តិករនានា<br>- បច្ចេកវិទ្យាច្នៃប្រឌិតថ្មីមានលក្ខណៈសមស្របសម្រាប់បរិបទនៃសកម្មភាពកម្ចាត់មីននៅកម្ពុជា |
| **គោលបំណងទី២៖** | **រំដោះផ្ទៃដីដែលដឹងថាមានគ្រាប់បែកចង្កោមជាអាទិភាពនៅត្រឹមឆ្នាំ២០២៥** | | | |
| **ផលប៉ះពាល់៖** | **តំបន់ដែលមានគ្រាប់បែកចង្កោមជាអាទិភាព ត្រូវបានរំដោះ និងដាក់ឱ្យប្រើប្រាស់សម្រាប់ការធ្វើអាជីវកម្ម ការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងហេដ្ឋារចនាសម្ព័ន្ធ** | | | |
| **គោលដៅ** | **យុទ្ធសាស្ត្រ** | **សូចនាករ** | **មធ្យោបាយសម្រាប់ការផ្ទៀងផ្ទាត់** | **ហានិភ័យ/ការសន្មត** |
| **គោលដៅទី១៖**<br>រៀបចំផែនការ និងចាត់អាទិភាពតំបន់ដែលដឹងថាមានគ្រាប់បែកចង្កោម | **យុទ្ធសាស្ត្រទី១៖**<br>ពិនិត្យឡើងវិញលើគោលការណ៍ណែនាំស្តីពីការធ្វើផែនការនិងការចាត់អាទិភាពនាពេលបច្ចុប្បន្ន សម្រាប់អនុវត្តនៅតំបន់ដែលដឹងថាមានគ្រាប់បែកចង្កោម | - គោលការណ៍ណែនាំស្តីពីការធ្វើផែនការនិងការចាត់អាទិភាពសម្រាប់តំបន់ដែលមានគ្រាប់បែកចង្កោម ត្រូវបានកែសម្រួលរួចរាល់ និងដាក់ឱ្យអនុវត្ត | - គោលការណ៍ណែនាំស្តីពីការធ្វើផែនការនិងការចាត់អាទិភាពដែលបានអនុម័ត | ហានិភ័យ៖<br>- កង្វះការចូលរួមពី អង្គភាពធ្វើផែនការសកម្មភាពកម្ចាត់មីន និងប្រតិបត្តិករនានា<br><br>ការសន្មត៖<br>- យន្តការអង្គភាពធ្វើផែនការសកម្មភាពកម្ចាត់មីន នៅតែដំណើរការ<br>- ការធ្វើផែនការនិងការចាត់អាទិភាពត្រូវឈរលើតម្រូវការជាក់ស្តែង |
| | **យុទ្ធសាស្ត្រទី២៖**<br>រៀបចំផែនការនិងធ្វើការចាត់អាទិភាពតំបន់ដែលមានគ្រាប់ | - ផែនការបោសសម្អាតគ្រាប់បែកចង្កោម<br>- បញ្ជីតំបន់ដែលមានគ្រាប់បែក | - ផែនការបោសសម្អាតគ្រាប់បែកចង្កោមត្រូវបានអនុម័ត<br>- បញ្ជីនៃតំបន់ដែលមានគ្រាប់បែក | |

| | | | | |
|---|---|---|---|---|
| | បែកចង្កោម | ចង្កោមជាអាទិភាព ត្រូវបានរៀបចំរួចរាល់ | ចង្កោមជាអាទិភាព ដែលត្រូវបានអនុម័តរួច | និងប្រជាជន ជាកត្តាសំខាន់បំផុត<br>- ការធ្វើផែនការនិងការចាត់អាទិភាពអំពីគ្រាប់បែកចង្កោម ត្រូវបានអនុវត្ត |
